**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Science Economiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការលែងលះនិងផលប៉ះពាល់នៃការលែងលះ

ស្រាវជ្រាវចាប់ពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ហ៊ួ រ័ត្ននៈ**

**ខឿន ពុទ្ធារី**

សាស្ត្រាចារ្យណែនាំ

ឯកឧត្តម **ឆឹង ស៊ីនៀង**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២១

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**
Université Royale de Droit et des Science Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការលែងលះនិងផលប៉ះពាល់នៃការលែងលះ

ស្រាវជ្រាវចាប់ពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **ហ៊ួ រ័ត្ននៈ**
**ខឿន ពុទ្ធារី**

សាស្ត្រាចារ្យណែនាំ
ឯកឧត្តម **ឆឹង ស៊ីនៀង**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី២១

ឆ្នាំចូលសិក្សា ២០១៧
ឆ្នាំសរសេរសារណា ២០២១

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **ហ៊ឺ រ័ត្តន:** គឺជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ជំនាន់ទី ២១ ឆ្នាំសិក្សា ២០១៧-២០២១ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ:

-លោកឪពុក **ងើង ហៃ** និងអ្នកម្ដាយ **អៀម នាព** ដែលលោកទាំងពីរបានបង្កើត រូបរាងកាយ និងចិញ្ចឹមបីបាច់ថែរក្សា ស្រឡាញ់ អប់រំទូន្មាន យកចិត្តទុកដាក់គ្រប់បែបយ៉ាង តាំងពីតូចរហូតដល់ធំ ឲ្យកូនមានឱកាសបានរៀនសូត្រចេះដឹងរហូតមកដល់ពេលបច្ចុប្បន្ន ដែលនេះជាគុណូបការៈយ៉ាងច្រើនអនេកប្បការ និងពិសេសថ្លៃថ្លាបំផុតដែលមិនអាចកាត់ថ្លៃបាន ក្នុងជីវិតកូនមួយនេះ។

នាងខ្ញុំឈ្មោះ **ខឿន ពុទ្ធារី** គឺជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ជំនាន់ទី ២១ ឆ្នាំសិក្សា ២០១៧-២០២១ នៃសាកលវិទ្យាភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ

-លោក **ខៀប ខឿន** និងអ្នកម្ដាយ **ម៉ៅ គប** ដែលលោកទាំងពីរបានបង្កើតរូបរាងកាយ និងចិញ្ចឹមបីបាច់ថែរក្សា ស្រឡាញ់ អប់រំទូន្មាន យកចិត្តទុកដាក់គ្រប់បែបយ៉ាង តាំងពីតូចរហូតដល់ធំ ឲ្យកូនមានឱកាសបានសិក្សារៀនសូត្រចេះដឹងរហូតមកដល់ពេលបច្ចុប្បន្ន ដែលនេះជាគុណូបការៈយ៉ាងច្រើនអនេកប្បការ និងពិសេសថ្លៃថ្លាបំផុតដែលមិនអាចកាត់ថ្លៃបាន ក្នុងជីវិតកូនមួយនេះ។

យើងខ្ញុំសូមថ្លែងអំណរអរគុណដល់ ឯកឧត្តម **លុយ ចាន់ណា** សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលបានខិតខំប្រឹងប្រែង យកអស់ពីសមត្ថភាព និងលទ្ធភាពក្នុងការដឹកនាំគ្រប់គ្រង ស្ថាប័នអោយបានដំណើរការទៅប្រកបដោយនិរន្តភាព និងប្រសិទ្ធភាពខ្ពស់ក្នុងការបណ្តុះបណ្តាលធនធានមនុស្សលើវិស័យច្បាប់ ជាពិសេសគឺជំរុញលើកទឹកចិត្ត និងអនុញ្ញាតឲ្យនិស្សិតក្នុងការសរសេរកិច្ចការ ដូចជារបាយការណ៍សិក្សាក្នុងគោលដៅ ពង្រឹងនូវការយល់ដឹងបន្ថែមទៀតរបស់និស្សិត ។

លើសពីនេះទៅទៀត យើងខ្ញុំសូមថ្លែងអំណរអរគុណដល់ថ្នាក់ដឹកនាំ លោក-លោកស្រី សាស្ត្រាចារ្យទាំងអស់ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំបង្ហាត់បង្រៀន ផ្តល់នូវដំបូន្មាន និងបទពិសោធន៍ជាច្រើនដល់រូបខ្ញុំទាំងអស់គ្នា ដោយមិនខ្វល់ពីការនឿយហត់ ក្នុងគោលបំណងផ្តល់នូវចំណេះដឹងដ៏ច្បាស់លាស់ និងដើម្បីជាស្ពានក្នុងការបំភ្លឺផ្លូវជីវិតហូតទៅថ្ងៃអនាគត ។

-ជាពិសេសលោកសាស្ត្រាចារ្យ **ធីន ស៊ីនៀន** ដែលលោកបានណែនាំ ផ្តល់គំនិតយោបល់ជាច្រើន ក្នុងការសរសេរសារណាមួយនេះ តាំងពីដើម រហូតទទួលបានជោគជ័យ ។

ជាចុងបញ្ចប់ យើងខ្ញុំ សូមបន្ទន់កាយលើកដៃប្រណម្យសំពះ ដល់វត្ថុស័ក្តិសិទ្ធទាំងឡាយទាំងពួង សូមតាមថែរក្សា លោកអ្នកមានគុណទាំងអស់ ឲ្យជួបតែសេចក្តីសុខ សេចក្តីចម្រើននិងសុភមង្គលជានិរន្តរ៍!

# **អារម្ភកថា**

សារណាអំពី " **ការលែងលះនិងផលប៉ះពាល់នៃការលែងលះ**" ដែលអស់លោក-លោកស្រីកំពុងកាន់នៅក្នុងដៃនេះ គឺជាស្នាដៃថ្មីមួយ របស់យើងខ្ញុំ ដែលបានចងក្រងរៀបរៀងឡើងចុងក្រោយនៃការបញ្ចប់ថ្នាក់បរិញ្ញាបត្រនីតិសាស្រ្ត។ វាជាឯកសារជំនួយដ៏សំខាន់មួយ ដើម្បីជួយសម្រួលដល់បណ្ដាអ្នកចូលចិត្តការស្រាវជ្រាវនានា ក៏ដូចជាពលរដ្ឋទូទៅផងដែរ ជាពិសេសនោះ គឺសិស្ស និស្សិតដែលកំពុងសិក្សាជំនាញនីតិសាស្រ្តផ្ទាល់តែម្តង ។

ចំពោះការស្រាវជ្រាវទៅលើប្រធានបទនេះ យើងខ្ញុំប្តេជ្ញាថា នឹងខិតខំព្យាយាម ពុះពារគ្រប់ការលំបាកទាំងឡាយក្នុងការចងក្រងសារណាមួយនេះ ឲ្យបានល្អបំផុត ព្រមទាំងព្យាយាមកែលម្អនូវឃ្លាឃ្លោងពាក្យពេចន៍ដើម្បីបង្កជាលក្ខណៈឲ្យសាធារណៈជនមានភាពងាយស្រួលក្នុងការយល់ពីអត្ថន័យ នៃពាក្យបច្ចេកទេសច្បាប់មួយចំនួនដែលត្រូវបានប្រើប្រាស់នៅក្នុងសារណានេះ។

ជាងនេះទៅទៀត យើងខ្ញុំមានជំនឿ និងក្តីសង្ឃឹមយ៉ាងមុតមាំថា ការតាក់តែងសារណាមួយនេះមិនត្រឹមតែអាចចូលរួមចំណែកក្នុង ការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យច្បាប់តែប៉ុណ្ណោះនោះទេ ថែមទាំងបានចូលរួមអនុវត្តនូវគោលនយោបាយកំណែទម្រង់ និងប្រព័ន្ធយុត្តិធម៌ របស់រាជរដ្ឋាភិបាល ក្នុងបុព្វហេតុមួយ ប្រកបដោយការផ្លាស់ប្តូរនិងប្រសិទ្ធភាពសំដៅឆ្ពោះទៅរកការរួមចំណែកកសាងនីតិរដ្ឋនៅកម្ពុជា ។

ដោយឡែក យើងខ្ញុំនឹងទទួលដោយក្តីសោមនស្សរីករាយនូវការរិះគន់ទាំងឡាយក្នុងន័យស្ថាបនាទៅលើរាល់ពាក្យពេចន៍ទាំងឡាយដែលជាកំហុសអក្ខរាវិរុទ្ធ និងកំហុសអត្ថន័យដោយអចេតនាប្រការណាមួយ ពីព្រោះថា មានតែការរិះគន់ដើម្បីស្ថាបនាទេ ដែលអាចនាំឲ្យយើងឆ្ពោះទៅរកគោលដៅដែលច្បាស់លាស់ និងត្រឹមត្រូវបាន។ ជាចុងក្រោយ យើងខ្ញុំ សូមថ្លែងអំណរគុណចំពោះសាធារណៈជនគ្រប់មជ្ឈដ្ឋានទាំងអស់ ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ស្វែងយល់ និងគាំទ្រនូវស្នាដៃថ្មីមួយនេះរបស់ យើងខ្ញុំ។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ........................................................ ១

**ជំពូកទី១**

**មូលហេតុនៃការលែងលះ ឬការផ្តាច់នីតិសម្ព័ន្ធ**

**ផ្នែកទី១៖ មូលហេតុទូទៅក្នុងគ្រួសារ ដែលនាំឲ្យមានការលែងលះ** ........................ ៤

១.១ ភាពមិនស្មោះត្រង់ ........................................................ ៤

១.២ កង្វះចំណេះដឹង ........................................................ ៥

១.៣ កង្វះការប្តេជ្ញាចិត្ត ........................................................ ៥

១.៤ ការប្រច័ណ្ឌ ........................................................ ៥

១.៥ រៀបការនៅក្មេងពេក ........................................................ ៥

១.៦ រៀបការដោយមិនពេញចិត្ត ........................................................ ៦

១.៧ ការប្រើប្រាស់អំពើហិង្សា ........................................................ ៦

១.៨ ការរស់នៅមិនចុះសម្រុងគ្នា ........................................................ ៦

១.៩ បញ្ហាសេដ្ឋកិច្ច ឬជីវភាព ........................................................ ៦

**ផ្នែកទី២៖ មូលហេតុទូទៅក្នុងសង្គម ដែលនាំឲ្យមានការលែងលះ** ........................ ៦

២.១ ការផ្សព្វផ្សាយគ្រឿងស្រវឹង ........................................................ ៦

២.២ ការបើកកន្លែងកំសាន្តពេលរាត្រី ........................................................ ៧

២.៣ ការប្រើប្រាស់គ្រឿងញៀន ........................................................ ៧

២.៤ ការប្រារព្ធពិធីផ្សេងៗដែលមានការផឹកគ្រឿងស្រវឹង ........................................................ ៧

២.៥ ការសេពគប់មិត្ត ........................................................ ៧

**ផ្នែកទី៣៖ មូលហេតុនៃការលែងលះដែលមានចែងក្នុងច្បាប់** ........................ ៨

៣.១ ការប្រព្រឹត្តអំពើផឹតក្បត់ ទៅលើសហព័ទ្ធ ........................................................ ៨

៣.២ ការបោះបង់សហព័ន្ធចោល ដោយគ្មានមូលហេតុត្រឹមត្រូវ ........ ៨
៣.៣ ការមិនដឹងច្បាស់ថាសហព័ទ្ធស្លាប់ ឬ រស់ អស់រយៈពេលជាង ១ ឆ្នាំ ........ ៨
៣.៤ ការរស់នៅបែកគ្នាជាបន្តបន្តបន្ទាប់ អស់រយៈពេលជាង ១ ឆ្នាំ ........ ៨
៣.៥ ករណីផ្សេងៗទៀត ........ ៩

## ជំពូកទី ២
## នីតិវិធីនៃការលែងលះ ឬការផ្តាច់នីតិសម្ព័ន្ធ

**ផ្នែកទី១៖ នីតិវិធីនៃការលែងលះ ក្នុងករណីគ្មានការព្រមព្រៀង** ........ ១០
១.១. នីតិវិធីនៃបណ្តឹងលែងលះ ........ ១០
១.១.១.ការផ្តើមនៃបណ្តឹងលែងលះ ........ ១០
១.១.២ ការផ្សះផ្សា ........ ១១
១.១.៣ ការចាត់ចែងរក្សាការពារ ........ ១៣
១.២ នីតិវិធីនៃការជម្រះក្តី ........ ១៥
១.២.១ ការពិនិត្យលើពាក្យបណ្តឹង ........ ១៥
១.២.២ ការបញ្ជូនពាក្យបណ្តឹងនៅចុងចម្លើយ ........ ១៦
១.២.៣ ការកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមទាញហេតុផលលើកដំបូង ........ ១៦
១.២.៤ ការលើកពាក្យបណ្តឹងចោល ........ ១៦
១.២.៥ ការបន្ថែម ឬការផ្លាស់ប្តូរកម្មវត្ថុនៃបណ្តឹង ........ ១៧
១.២.៦ ការប្តឹងតបរបស់ចុងចម្លើយ ........ ១៧
១.២.៧ ការស៊ើបអង្កេតរបស់ចៅក្រម និងការជម្រះក្តី ........ ១៧
១.៣ ការសម្រេចសេចក្តី ........ ២៣
១.៣.១. ខ្លឹមសារនៃសាលក្រម ........ ២៣
១.៣.២ ការសម្រេចមិនឲ្យលែងលះ ........ ២៤
១.៣.៣. ការចូលជាស្ថាពររបស់សាលក្រម ........ ២៤
១.៤ អានុភាពនៃការលែងលះដោយគ្មានការព្រមព្រៀង ........ ២៥
១.៤.១ អានុភាពចំពោះទ្រព្យសម្បត្តិ ........ ២៥

១.៤.២. អានុភាពលើកាតព្វកិច្ច ..... ២៧
១.៤.៣. អានុភាពលើស្ថានភាពគ្រួសារ..... ២៧
**ផ្នែកទី២៖ នីតិវិធីនៃការលែងលះ ក្នុងករណីមានការព្រមព្រៀង** ..... ២៨
២.១ កិច្ចព្រមព្រៀងលែងលះ..... ២៩
២.២ ពាក្យសុំលែងលះ ..... ២៩
២.២.១ ពាក្យសុំជាលាយលក្ខណ៍អក្សរ ..... ២៩
២.២.២ ពាក្យសុំដោយផ្ទាល់មាត់ ..... ៣០
២.៣. សមត្ថកិច្ចដោះស្រាយ ..... ៣១
២.៣.១ ក្រុមប្រឹក្សាឃុំ-សង្កាត់ ..... ៣១
២.៣.២. សាលាដំបូងរាជធានី-ខេត្ត ..... ៣១
២.៤. ការចេញដីកាសម្រេច ..... ៣៣
២.៥. អានុភាពនៃកាលែងលះដោយការព្រមព្រៀង ..... ៣៤
២.៥.១ អានុភាពលើទ្រព្យសម្បត្តិ និងកាតព្វកិច្ច ..... ៣៤
២.៥.២ អានុភាពលើស្ថានភាពគ្រួសារ ..... ៣៥

**ជំពូកទី៣**

**ផលប៉ះពាល់ទូទៅនៃការលែងលះ ឬការផ្តាច់នីតិសម្ព័ន្ធ**

**ផ្នែកទី១៖ ផលប៉ះពាល់ក្នុងគ្រួសារ** ..... ៣៧
១.១ ចំពោះកូន ..... ៣៧
១.១.១ ផ្លូវចិត្ត ..... ៣៧
១.១.២ សុខភាព..... ៣៨
១.១.៣ ការសិក្សាអប់រំ ..... ៣៨
១.១.៤ កិត្តិយស ..... ៣៩
១.១.៥ ការបំពានផ្លូវភេទ..... ៣៩
១.២ ចំពោះប្រពន្ធ..... ៣៩

១.២.១ សេដ្ឋកិច្ច ....................................................................................................................៣៩
១.២.២ ការងារ ......................................................................................................................... ៤០
១.២.៣ កិត្តិយស ........................................................................................................................ ៤០
១.២.៤ សុខភាព.......................................................................................................................... ៤០
១.២.៥ ការបំពានលើផ្លូវភេទ .......................................................................................................... ៤០
១.២.៦ ទំនាក់ទំនងរវាងម្តាយនិងកូន ...........................................................................................៤១
១.៣ ចំពោះប្តី .............................................................................................................................៤១
១.៣.១ ការងារ ......................................................................................................................... ៤១
១.៣.២ សេដ្ឋកិច្ច .......................................................................................................................៤១
១.៣.៣ កិត្តិយស.........................................................................................................................៤១
១.៣.៤ សុខភាព..........................................................................................................................៤១
១.៣.៥ ទំនាក់ទំនងរវាងឪពុកនឹងកូន ...........................................................................................៤២
១.៤ ចំពោះសាច់ញាតិសហព័ទ្ធទាំងសងខាង ..................................................................................៤២
**ផ្នែកទី២៖ ផលប៉ះពាល់ក្នុងសង្គម**........................................................................................................៤២
២.១ សង្គមពោរពេញដោយក្មេងកំព្រាច្រើន .....................................................................................៤២
២.២ ស្ត្រីមេម៉ាយ និងពោះម៉ាយច្រើន ..........................................................................................៤២
២.៣ ជាបន្ទុកធ្ងន់សម្រាប់សង្គម........................................................................................................ ៤៣
**សេចក្តីសន្និដ្ឋាន** ............................................................................................................................. ៤៤
**អនុសាសន៍** ................................................................................................................................... ៤៥
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

នៅក្នុងទិដ្ឋភាពច្បាប់នាពេលបច្ចុប្បន្ន នៅពេលដែលគេនិយាយអំពីការលែងលះ គឺគេសំដៅលើការរំលាយនូវចំណងគតិយុត្តរវាងភាគីប្តី និងប្រពន្ធ។ ដោយហេតុថា អាពាហ៍ពិពាហ៍គឺជាកិច្ចសន្យាដែលកើតឡើងពីការសំដែងឆន្ទៈដោយគ្មានវិការៈរវាងភាគីប្តី និងប្រពន្ធ។ ដូច្នេះកិច្ចសន្យានេះ បានក្លាយជាមូលដ្ឋានដ៏ចំបងក្នុងការបង្កើតឲ្យមាននូវចំណងគតិយុត្តដ៏រឹងមាំមួយ។ ចំណងនេះនឹងធានាឲ្យបាននូវការផ្តល់ នូវសុវត្ថិភាពគតិយុត្តគ្រប់គ្រាន់ដល់គូភាគីទាំងសងខាង។ ប្រសិនបើភាគីណាមួយ ឬភាគីទាំងសងខាងនៃចំណងអាពាហ៍ពិពាហ៍នេះមានបំណងចង់រំលាយចោលនូវទំនាក់ទំនងគតិយុត្តមួយនេះឲ្យដាច់ស្រេច ហើយទទួលស្គាល់ទាំងស្រុងដោយច្បាប់ ការរំលាយចំណងនេះចាំបាច់ត្រូវតែគោរពនូវលក្ខខណ្ឌគតិយុត្តមួយចំនួនរួមមានលក្ខខណ្ឌទម្រង់ និងលក្ខខណ្ឌគ្រឹះរបស់វា។ បើក្រឡេកមើលតាមស្ថានភាពជាក់ស្តែងនៃច្បាប់វិញ បើបុរស-នារីណា គ្រាន់តែរៀបអាពាហ៍ពិពាហ៍ តាមបែបប្រពៃណី ទំនៀមទម្លាប់ ដោយមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន នោះមិនអាចចាត់ទុកថាមានចំណងអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ជាប្តី-ប្រពន្ធឡើយ។ ការរួមរស់ជាប្តីប្រពន្ធដោយមិនមានចំណងអាពាហ៍ ពិពាហ៍តាមផ្លូវច្បាប់បែបនេះ ត្រូវបានហៅថា "អនីតិសង្វាស"។ ការរស់នៅជាអនីតិសង្វាស ប្រសិនបើ បុរស-នារីរូបណាអស់មនោសញ្ចេតនាលែងចង់រួមរស់ជាមួយគ្នាទៀត ពួកគេគ្រាន់តែសម្រេចចិត្តដើរចេញ បែកលំនៅឋានគ្នា និងលែងរួមរស់នៅជាមួយគ្នា ដោយគ្រាន់តែមានការដឹងឮពីឃុំ/សង្កាត់ជាការស្រេច តែចំពោះការបែងចែកទ្រព្យសម្បត្តិ និងអំណាចមេបាលើកូនវិញ មិនអាចដោះស្រាយត្រឹមឃុំ/សង្កាត់បានទេ ត្រូវតែដោះស្រាយតាមប្រព័ន្ធតុលាការដដែល។ តែយ៉ាងណាក្នុងសារណារបស់ពួកខ្ញុំមិនបានសិក្សាទៅលើការរស់នៅជាមួយគ្នាបែបអនីតិសង្វាសនេះទេ។ ដោយក្នុងសារណានេះ ពួកយើងលើកយកតែករណីអាពាហ៍ពិពាហ៍ណា ដែលកើតឡើងដោយស្របច្បាប់ប៉ុណ្ណោះ គឺមានន័យថាមានសំបុត្រអាពិហ៍ពិពាហ៍ត្រឹមត្រូវ។

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

នៅក្នុងសង្គមបច្ចុប្បន្នយើងនេះ ករណីលែងលះតែងតែកើតឡើងជារៀងរាល់ថ្ងៃបង្កមកពីមូលហេតុផ្សេងៗគ្នាជាច្រើន។ ដូច្នេះរាជរដ្ឋាភិបាល តែងតែបង្កើតច្បាប់ដើម្បីគ្រប់គ្រងឲ្យទាន់ពេលវេលា និងជាពិសេសនោះដើម្បីការពាគូភាគីទាំងសងខាង កុំឲ្យមានការរំលោភបំពានគ្នាទៅវិញទៅមក។ ថែមពីលើនេះទៀតរាជរដ្ឋាភិបាលតែងតែយកចិត្តទុកដាក់ និងផ្តល់សិទ្ធិទៅដល់ទីកន្លែងជាច្រើនផ្សេងទៀតតាមមូលដ្ឋាន ក្នុងការសម្រប

សម្រួលដល់គូភាគី(ប្តី/ប្រពន្ធ) មុនពេលសម្រេចចិត្តចូលទៅដោះស្រាយតាមផ្លូវតុលាការ ដើម្បីជៀសវាងកុំឲ្យមានការខាតបង់ប្រយោជន៍ធំៗជាច្រើនដល់គូភាគី បណ្តាលមកពីការលែងលះនេះ។ តែបើក្រឡេកមើលអតីតកាលយើងដឹងហើយថា វិស័យគតិយុត្តនៅកម្ពុជា ត្រូវបានបំផ្លិចបំផ្លាញស្ទើរតែទាំងស្រុងដោយសារសង្គ្រាមស៊ីវិល តែទោះជាយ៉ាងនេះក្តី ក៏រាជរដ្ឋាភិបាលកម្ពុជាបច្ចុប្បន្នខិតខំប្រឹងប្រែងលើកស្ទួយវិស័យយុត្តិធម៌នេះឲ្យមានការរីកលូតលាស់ឡើងវិញផងដែរ។ ជាផ្លែផ្កាកើតចេញពីការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ហើយថែមទាំងមានការឧបត្ថម្ភគាំទ្រពីប្រទេសជប៉ុនជាមិត្តផងទៀតនោះ ជាលទ្ធផលកម្ពុជាបានអនុម័តក្រមរដ្ឋប្បវេណី កាលពីថ្ងៃទី ០៥ ខែតុលា ឆ្នាំ ២០០៧ និងត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣ ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ ២០០៧។

ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ មានតួនាទីសំខាន់ណាស់ ព្រោះក្រមមួយនេះ បានកំពុងដើរតួនាទីជាមូលដ្ឋានគ្រឹះក្នុងការដោះស្រាយករណីលែងលះនានាដែលកំពុងកើតឡើងជាបន្តបន្ទាប់នាពេលបច្ចុប្បន្ន។ ក្រៅពីក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ មានច្បាប់ផ្សេងៗទៀតដែលជាច្បាប់ជំនួយ ក្នុងការដោះស្រាយករណីលែងលះរួមមានច្បាប់អាពាហ៍ពិពាហ៍និងគ្រួសារ ឆ្នាំ១៩៨៩ ច្បាប់ស្តីពីឯកពន្ធភាពចុះថ្ងៃទី ០១ កញ្ញា ឆ្នាំ ២០០៦ និងច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ ២០០៦ រួមទាំងច្បាប់នានាផ្សេងៗទៀតដែលពាក់ព័ន្ធ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

បច្ចុប្បន្នប្តីប្រពន្ធជាច្រើនគូ កំពុងមានបញ្ហាលែងលះគ្នាបណ្តាលមកពីកត្តាផ្សេងៗ ដែលធ្វើឲ្យសង្គមមានការព្រួយបារម្ភជាខ្លាំង តែទោះជាយ៉ាងណាក្តី ក៏ពួកគេបានសម្រេចចិត្តហើយថាពួកគេនឹងលែងលះគ្នាឲ្យដាច់ស្រេចទៅតាមផ្លូវតុលាការ ដើម្បីកុំឲ្យមានបញ្ហានៅថ្ងៃក្រោយ។ ការដោះស្រាយតាមផ្លូវតុលាការ ប្តីប្រពន្ធតែងតែមានការភ័យខ្លាច ទៅលើប្រព័ន្ធយុត្តិធម៌ ជាពិសេសស្ថាប័នតុលាការ ខ្លាចស្ថាប័ននេះមានការដោះស្រាយដោយមានភាពលំអៀង មិនស្របតាមនីតិវិធីច្បាប់ និងគ្មានតម្លាភាព ជាហេតុធ្វើឲ្យមានផលវិបាកចំពោះពួកគេក៏ដូចជាសង្គមកាន់តែខ្លាំងឡើង ។ ហេតុផលទាំងនេះក៏ដោយសារស្ថាប័នតុលាការ ធ្វើការនៅខ្វះចន្លោះ ជាពិសេសមន្ត្រីពាក់ព័ន្ធដែលធ្វើការនៅក្នុងករណីលែងលះនេះតែម្តងដែលតែងតែធ្វើការខ្ជីខ្ជារ។ តើមូលហេតុចម្បងធំៗអ្វីខ្លះដែលនាំឲ្យមានលែងលះ? តើដំណើរការនិងនីតិវិធីនៃការលែងលះប្រព្រឹត្តទៅយ៉ាងដូចម្តេច? តើការលែងលះនឹងបង្កឲ្យមានផលប៉ះពាល់អ្វីខ្លះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការសិក្សាស្រាវជ្រាវនេះ គឺដើម្បីចូលរួមចំណែកបង្កើតនូវចំណេះដឹង និងព្រមទាំងដើម្បីសិក្សាស្វែងយល់ឲ្យកាន់តែច្បាស់អំពីករណីលែងលះ និងផលប៉ះពាល់បណ្តាលមកពីការលែងលះ។ មួយវិញទៀតការស្រាវជ្រាវនេះ ក៏បានធ្វើឲ្យក្រុមយើងខ្ញុំបានយល់ដឹងអំពីមូលហេតុ នីតិវិធី និងផលប៉ះពាល់នៃការលែងលះមួយកម្រិតទៀតផងដែរ។ មិនតែប៉ុណ្ណោះ វាក៏ជាឯកសារមួយសម្រាប់តម្កល់ទុកក្នុងសាកលវិទ្យល័យ ដើម្បីឲ្យនិស្សិតជំនាន់ក្រោយបានធ្វើការសិក្សាជាបន្ទាប់បន្សំ។ តែយ៉ាងណាចំពោះគោលបំណងគ្រឹះ និងគោលបំណងចម្បងនៃការសិក្សាស្រាវជ្រាវ គឺផ្តោតយ៉ាងសំខាន់ទៅលើ ការលែងលះ និងផលប៉ះពាល់នៃការលែងលះ។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ការសិក្សារបស់យើងខ្ញុំផ្តោតសំខាន់ ទៅលើមូលហេតុ នីតិវិធី និងផលប៉ះពាល់នៃការលែងលះតែប៉ុណ្ណោះ។ កាលដែលកំណត់អំពីដែនកំណត់ និងវិសាលភាពនៃការសិក្សាស្រាវជ្រាវដែលបានរៀបរាប់ខាងលើនេះធ្វើឲយើងកាន់តែមានភាពងាយស្រួលក្នុងការស្រាវជ្រាវ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ការស្រាវជ្រាវមួយនេះមានសារៈសំខាន់ណាស់សម្រាប់ប្រជាពលរដ្ឋទូទៅ និងអ្នកសិក្សាគ្របមជ្ឈដ្ឋានបានសិក្សាស្វែងយល់ឲកាន់តែស៊ីជម្រៅទៅលើ ករណីលែងលះ ក៏ដូចជាផលប៉ះពាល់នៃការលែងលះ ថែមទាំងទុកជាឯកសារសម្រាប់អ្នកស្រាវជ្រាវ ព្រមទាំងនិស្សិតទាំងឡាយដែលមានបំណងចង់ស្វែងយល់ពីប្រធានបទនេះ។

## ៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

សារណានេះត្រូវបានបែងចែកជាបីដូចខាងក្រោម៖

ជំពូកទី១ ការលែងលះ ឬការផ្តាច់នីតិសង្វាស

ជំពូកទី២ នីតិវិធីនៃការលែងលះ ឬការផ្តាច់នីតិសង្វាស

ជំពូកទី៣ ផលប៉ះពាល់នៃការលែងលះ ឬការផ្តាច់នីតិសង្វាស

# ជំពូកទី១

# មូលហេតុនៃការ

# លែងលះ ឬការ

# ផ្តាច់ជីវិសហ្វាស

# ជំពូកទី១

# មូលហេតុនៃការលែងលះ ឬការផ្តាច់នីតិសម្ពន្ធ

ការលែងលះគ្នា គឺជាការផ្តាច់ចំណងអាពាហ៍របស់ប្តី ប្រពន្ធដែលបានរៀបអាពាហ៍ពិពាហ៍ពេញ ច្បាប់ក្នុងពេលរស់នៅពីរនាក់[1]។ ការផ្តាច់ចំណងអាពាហ៍ពិពាហ៍រវាងប្តី និង ប្រពន្ធ ក្នុងន័យនេះ គឺសំដៅលើការរំដោះខ្លួនឲ្យរួចពីចំណងនៃទំនាក់ទំនងអាពាហ៍ពិពាហ៍ ដែលខ្លួនធ្លាប់ជាសហព័ទ្ធកន្លងមក រួមមាន ករណីយកិច្ចក្នុងការរួមរស់នៅជាមួយគ្នាសហការគ្នា ករណីយកិច្ចសង្គ្រោះគ្នាទៅវិញទៅមក និងមួយទៀតនោះគឺករណីយកិច្ចស្មោះត្រង់ក៏ត្រូវរលត់ទៅតាមការផ្តាច់ចំណងអាពាហ៍ពិពាហ៍នេះដែរ ដែលន័យនេះសំដៅទៅលើសហព័ទ្ធណាម្នាក់អាចរៀបអាពាហ៍ពិពាហ៍ជាថ្មី ជាមួយអ្នកណាម្នាក់ទៀតបាន។ បើក្រឡេកមកមើលរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានចែងយ៉ាងច្បាស់ថា ការងារមេផ្ទះមានតម្លៃស្មើនឹងកម្រៃដែលបានមកពីការងារធ្វើនៅក្រៅផ្ទះ[2] ដែលក្នុងន័យនេះបានលើកម្ពស់ដល់ការងារស្ត្រីជាមេផ្ទះជាខ្លាំង ដែលជួយឲ្យស្ត្រីដឹងថាការងាររបស់ខ្លួនធ្វើប្រចាំថ្ងៃមានតម្លៃដូចការងារខាងក្រៅដែលមិនអាចឲ្យប្តីមើលងាយខ្លួនបាននោះទេ។ ហេតុផលទាំងនេះហើយដែលស្ត្រីគ្រប់រូបត្រូវយល់ដឹង នឹងមិនអាចរស់ក្រោមសម្ពាធផ្លូវចិត្ត ឬមិនហ៊ានដាក់ពាក្យលែងលះទៅតុលាការនោះទេ តែយ៉ាងណា មាត្រានេះហាក់គ្មានគោលបំណងឲ្យស្ត្រីខ្មែររើសយកហេតុផលទាំងនេះ ដើម្បីជាមូលហេតុដំបូងក្នុងការលែងលះនោះទេ។

## ផ្នែកទី១៖ មូលហេតុទូទៅក្នុងគ្រួសារ ដែលនាំឲ្យមានការលែងលះ

### ១.១ ភាពមិនស្មោះត្រង់

ភាពមិនស្មោះត្រង់ ជាកត្តាសំខាន់ដែលបណ្តាលឲ្យសហព័ទ្ធភាគច្រើនឈានទៅដល់ការលែងលះ និងការបែកគ្នាក្នុងសង្គមនាពេលបច្ចុប្បន្ន។ សម្រាប់សហព័ទ្ធទាំងសងខាងអាកប្បកិរិយាមិនស្មោះត្រង់ចំពោះគ្នា គឺជាការពិបាកទទួលយកបំផុត នៅក្នុងការរស់នៅប្រចាំថ្ងៃនៃជីវិតគ្រួសារ។ ភាពមិនស្មោះត្រង់ទាំងនេះ មិនសំដៅទៅលើតែលើទំនាក់ស្នេហាបែបត្រីកោណតែមួយមុខទេ វាអាចជាភាពមិនស្មោះត្រង់លើទ្រព្យសម្បត្តិផងដែរ [3]។

[1] មាត្រា ៣៨ នៃច្បាប់ ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ឆ្នាំ ១៩៨៩

[2] មាត្រា ៣៦ វាក្យខណ្ឌទី៣ ក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ១៩៩៣

[3] https://km.warbletoncouncil.org/causas-divorcio-5432#menu-12

### ១.២ កង្វះចំណេះដឹង

កង្វះចំណេះដឹងរបស់ប្ដីប្រពន្ធទាំងសងខាង ជាកត្តាសំខាន់មួយដែលធ្វើឲ្យប្ដីប្រពន្ធទាំងសងខាង ជួបនៅបញ្ហាលែងលះគ្នា។ ករណីជាក់ស្ដែងដែលយើងមើលឃើញ ក្នុងសង្គមនាពេលបច្ចុប្បន្នទាក់ទងទៅនឹងចំណេះដឹងនេះ គឺប្ដីប្រពន្ធដែលរស់នៅតាមទីជនបទផ្ទាល់តែម្ដង ដែលពួកគាត់មានជីវភាពក្រីក្រ និងមិនបានបន្តការសិក្សាបានជ្រៅជ្រះធ្វើឲ្យពួកគាត់ខ្វះការអំណត់ចិត្ត បង្កជាអំពើហិង្សា រហូតបណ្ដាលឲ្យមានការលែងលះគ្នា។

### ១.៣ កង្វះការប្ដេជ្ញាចិត្ត

កង្វះការប្ដេជ្ញាចិត្ត គឺជាកត្តាដែលកើតមានជាទូទៅក្នុងចំណោមការលែងលះនិងការបែកបាក់គ្នា។ ប្រសិនបើយើងវិភាគលក្ខណៈនៃទំនាក់ទំនងរវាងគូអាពាហ៍ពិពាហ៍ វាបង្ហាញឱ្យឃើញថាការប្ដេជ្ញាចិត្តគឺជាទិដ្ឋភាពដែលមិនអាចខ្វះបាន។ បើគ្មានឆន្ទៈក្នុងការប្ដេជ្ញាចិត្តទេវាពិតជាលំបាកខ្លាំងណាស់ក្នុងការរក្សាទំនាក់ទំនងជាមួយគ្នា។ ដូច្នេះគេសង្កេតឃើញថាគូស្វាមីភរិយាជាច្រើនដែលសម្រេចចិត្តរៀបការដោយមិនមានការតាំងចិត្តគ្រប់គ្រាន់ ស្ទើរតែប្រែទៅជាការលែងលះដោយស្វ័យប្រវត្តិក្នុងឆ្នាំបន្តបន្ទាប់[4]។

### ១.៤ ការប្រច័ណ្ឌ

ការប្រច័ណ្ឌជ្រុលហួសហេតុពេក ដោយមិនយកហេតុផលមកពិចារណាឱ្យបានត្រឹមត្រូវ ងាយនឹងប៉ះពាល់ដល់ការរស់នៅជាមួយគ្នាខ្លាំងណាស់។ ព្រោះកាលណាបើសិនជា មួយថ្ងៃៗ គិតតែពីរករឿង គិតតែពីខឹងគ្នានោះនឹងធ្វើឲ្យសហព័ទ្ធងាយការបែកបាក់គ្នា ងាយរស់នៅផ្សេងគ្នា និងតែងតែមានបញ្ហាក្នុងគ្រួសារ រហូតដល់ឈានដល់ការលែងលះគ្នា ។

### ១.៥ រៀបការនៅក្មេងពេក

សព្វថ្ងៃនេះមានការយល់ស្របខ្ពស់ក្នុងការបញ្ជាក់ថាអាពាហ៍ពិពាហ៍ដែលបង្កើតឡើងក្នុងភាពវ័យក្មេងពេក ត្រូវបានបង្ហាញថាជាកត្តាហានិភ័យនៃការលែងលះ។ ព្រោះសហព័ទ្ធដែលមានភាពវ័យក្មេងពួកគេនៅខ្វះចំណេះដឹងក្នុងការប្ដេជ្ញាចិត្ត និងភាពអត់ធ្មត់ពេលរស់នៅជាមួយគ្នា។ មួយវិញទៀតបទពិសោធន៍ក្នុងសង្គមក៏ហាក់នៅខ្វះខាត ជាពិសេសការងារដែលច្បាស់លាស់មួយ សម្រាប់ចិញ្ចឹមគ្រួសារក៏មិនទាន់មានទៀតផង ដែលជាហេតុនាំឲ្យសេដ្ឋកិច្ចគ្រួសារគ្មានលំនឹងរហូតឈានដល់ការប្រេះឆាក្នុងគ្រួសារកើតឡើង[5]។

[4] https://km.warbletoncouncil.org/causas-divorcio-5432#menu-12
[5] https://km.warbletoncouncil.org/causas-divorcio-5432#menu-12

### ១.៦ រៀបការដោយមិនពេញចិត្ត

នាពេលបច្ចុប្បន្នពាក្យថានំមិនធំជាងនាឡនៅតែបន្តប្រើប្រាស់ទៅលើកូនៗ នៅក្នុងគ្រួសារមួយចំនួនដដែល។ កត្តានេះហើយដែលធ្វើឲ្យ ប្តីប្រពន្ធមួយចំនួន មិនបានយល់ពីគ្នាឲ្យបានស៊ីជម្រៅ មុនពេលសម្រេចចិត្តរៀបការជាមួយគ្នា ដែលជាហេតុនាំឲ្យសហព័ទ្ធងាយនឹងលែងលះគ្នា។

### ១.៧ ការប្រើប្រាស់អំពើហិង្សា

អំពើហិង្សាក្នុងគ្រួសារ សំដៅលើហិង្សាដែលកើតមាន និងអាចកើតមានទៅលើ ប្តី ឬ ប្រពន្ធ កូនក្នុងបន្ទុក ជនទាំងឡាយរស់នៅក្រោមដំបូលផ្ទះ និងក្នុងបន្ទុកគ្រួសារ[6]។ បើក្រឡេកមើលនៅក្នុងជម្លោះរវាងប្តីប្រពន្ធ អំពើហិង្សាក្នុងគ្រួសារបានបង្កឱ្យមានអំពើវាយដំ ប្រើសំដីបរិហារកេរ្តិ៍ គ្នាទៅវិញទៅមក រហូតឈានទៅដល់ការបែកបាក់កូនចៅ ប្តីប្រពន្ធ និងក្រុមគ្រួសារទាំងមូល។

### ១.៨ ការរស់នៅមិនចុះសម្រុងគ្នា

ជាការពិតណាស់ ភាពមិនចុះសម្រុងគ្នាខាងផ្លូវកាយ ផ្លូវចិត្ត និងការខ្វែងគំនិតគ្នា បានធ្វើឱ្យសហព័ទ្ធណាម្នាក់មានអារម្មណ៍ថាមានការឈឺចាប់ រហូតឈានទៅរកការលែងលះ ដើម្បីយកឈ្នះលើភាគីម្ខាងទៀត ឬក៏ដើម្បីចាកចេញពីសម្ពាធផ្លូវចិត្តដែលបណ្តាលមកពីភាពមិនចុះសម្រុងគ្នា។

### ១.៩ បញ្ហាសេដ្ឋកិច្ច ឬជីវភាព

ជីវភាពបានបង្ខំឲ្យសហព័ទ្ធឃ្លាតឆ្ងាយពីគ្នា។ នេះជាស្ថានភាពពិតមួយដែលកំពុងតែពើបប្រទះជារៀងរាល់ថ្ងៃ។ បញ្ហានេះភាគច្រើនត្រូវបានគេសម្គាល់ឃើញថា កើតឡើងចំពោះសហព័ទ្ធបំពើការងារនៅក្នុងវិស័យឧស្សាហកម្មនិងសេដ្ឋកិច្ចក្រៅប្រព័ន្ធជាដើម។ ការរស់នៅបែកគ្នាបែបនេះ នឹងធ្វើឲ្យភាគីណាមួយចាប់ផ្តើមអស់មនោសញ្ចេតនាជាមួយគ្នា រហូតឈានទៅដល់ការសុំលែងលះគ្នាជាក់ជាមិនខាន។ អាពាហ៍ពិពាហ៍ងាយនឹងប្រេះស្រាំណាស់ ប្រសិនបើមាន ការលំបាកផ្នែកហិរញ្ញវត្ថុ។ ទោះយ៉ាងណាក៏ដោយកង្វះភាពយល់ដឹងរវាងប្តីប្រពន្ធក្នុងវិស័យហិរញ្ញវត្ថុទំនងជាបញ្ហាសំខាន់ជាង។

## ផ្នែកទី២៖ មូលហេតុទូទៅក្នុងសង្គម ដែលនាំឲ្យមានការលែងលះ

### ២.១ ការផ្សព្វផ្សាយគ្រឿងស្រវឹង

ការផ្សព្វផ្សាយគ្រឿងស្រវឹង បណ្តាលឲ្យមានបញ្ហាជាច្រើន ក្នុងគ្រួសារ និងសង្គមជាតិទាំងមូល។ ចំពោះការផ្សព្វផ្សាយនេះ បានជំរុញឲ្យមាន ការប្រើប្រាស់នូវគ្រឿងស្រវឹងកាន់តែ ខ្លាំងឡើងៗ ដែលជាហេតុនាំឲ្យសង្គម

[6] មាត្រា ២ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០០៥

គ្រួសារ ដែលកំពុងប្រើប្រាស់គ្រឿងស្រវឹងស្រាប់នោះ មានជីវភាពកាន់តែ ក្រីក្រទៅៗ និងថែមទាំងមានការប្រើប្រាស់ហិង្សាក្នុងគ្រួសារជាញឹកញាប់ទៀតផង ។

### ២.២ ការបើកកន្លែងកំសាន្តពេលរាត្រី

កន្លែងកំសាន្តពេលរាត្រីនាពេលបច្ចុប្បន្នកំពុងតែរីកដុះដាលដូចផ្សិត ស្ទើរតែគ្រប់ទីកន្លែងទៅហើយ។ ហេតុផលមួយនេះ អាចនឹងឲ្យសហព័ទ្ធណាម្នាក់ ជាពិសេសភាគីខាងប្តី ងាយស្រួលមែនទែន ក្នុងការទៅរកកន្លែងកំសាន្តនៅខាងក្រៅរហូតភ្លេចគ្រួសារ នឹងអាចឈានទៅដល់មានដៃគូខាងក្រៅលួចលាក់ប្រពន្ធមិនឲ្យដឹងទៀតផង។ កត្តាទាំងនេះបានបង្កជាជម្លោះក្នុងគ្រួសារជាញឹកញាប់ រហូតឈានដល់ការលែងលះគ្នាក្នុងរង្វង់គ្រួសារ ដែលករណីនេះសម្បូរកើតឡើងណាស់ នាពេលបច្ចុប្បន្ន។

### ២.៣ ការប្រើប្រាស់គ្រឿងញៀន

ក្នុងសង្គមបច្ចុប្បន្នគ្រឿងញៀនគឺជាមូលហេតុធំណាស់ ដែលនាំឲ្យមានការលែងលះគ្នាក្នុងគ្រួសារ ព្រោះគ្រឿងញៀន បានបង្កឲ្យមានផលវិបាកចំពោះគ្រួសារដូចជា បាត់បង់សមត្ថភាពក្នុងការបំពេញការងារ បាត់បង់អាជីពការងារ ចំណូលគ្រួសារថយចុះ ប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារ និងបង្កឲ្យកិត្តិយសគ្រួសារអាប់ឱនជាដើម។ ក្រៅពីផលប៉ះពាល់ចំពោះគ្រួសារ គ្រឿងញៀនបានបង្កឲ្យមានផលវិបាកផ្សេងៗទៀតដល់សហគមន៍ និងសង្គមជាតិដូចជា បង្កឲ្យមានឧក្រិដ្ឋកម្ម ឃាតកម្ម ចោរកម្ម អសន្តិសុខ ធនធានមនុស្សនៃសង្គមជាតិថយចុះ ការអភិវឌ្ឍន៍សង្គមមានការយឺតយ៉ាវ សីលធម៌សង្គមធ្លាក់ចុះទាប ប្រពៃណី វប្បធម៌ជាតិរេចរិល ប្រទេសជាតិទន់ខ្សោយជាដើម។

### ២.៤ ការប្រារព្ធពិធីផ្សេងៗដែលមានការផឹកគ្រឿងស្រវឹង

នៅពេលមានការប្រារព្ធពិធីផ្សេងៗ នៅក្នុងសង្គមយើងសង្កេតឃើញថា ការដាក់គ្រឿងស្រវឹងសម្រាប់ឲ្យភ្ញៀវដែលចូលរួមសម្រាប់ពិសារក្នុងកម្មវិធីហាក់មិនដែលរំលងនោះទេ។ ប្រាកដណាស់ការដាក់គ្រឿងស្រវឹងនៅក្នុងកម្មវិធីផ្សេងៗវាមិនអាក្រក់ទេ តែបើការដាក់នោះច្រើនលើសលប់ពេក ធ្វើឲ្យបុគ្គលដែលចូលរួមពិបាកគេចវេសពីគ្រឿងស្រវឹង រហូតផឹកច្រើនពេកបង្កជាជម្លោះក្នុងគ្រួសារ ។

### ២.៥ ការសេពគប់មិត្ត

ក្នុងសង្គមសម័យទំនើបនេះ ការសេពគប់មិត្តភក្តិ ជារឿងសំខាន់ណាស់ដើម្បីទទួលបានសុភមង្គលក្នុងគ្រួសារទាំងមូល បើយើងយកបុគ្គលបែបណាជាមិត្ត នោះយើងនឹងប្រាកដស្មើដោយមិត្តនោះជាក់ជាមិនខាន។

ព្រោះបើមិត្តយើងជាមនុស្សដែលចូលចិត្តការដើរលេងផឹកស៊ី នោះយូរៗទៅ យើងនឹងក្លាយជាមនុស្សបែបនោះដែរជាមិនខាន ហេតុផលទាំងនេះ នឹងនាំឲ្យមានភាពរកាំរកូសបន្តិចម្តងៗក្នុងរង្វង់គ្រួសារទាំងមូល។

## ផ្នែកទី៣៖ មូលហេតុនៃការលែងលះដែលមានចែងក្នុងច្បាប់

ប្តី ឬប្រពន្ធ អាចលែងលះគ្នាបានដោយលើកមូលហេតុតាមច្បាប់ចែង តែក្នុងករណីដែលចំណុចណាមួយ ក្នុងចំណោមចំណុចខាងក្រោមនេះ ត្រូវបានទទួលស្គាល់តែប៉ុណ្ណោះ ៖

### ៣.១ ការប្រព្រឹត្តអំពើផិតក្បត់ នៅលើសហព័ទ្ធ[7]

បើតាមច្បាប់ស្តីពីឯកពន្ធភាព នៅប្រទេសកម្ពុជាចានចែងថា ត្រូវចាត់ទុកថាផិត គឺជាការរួមសេវនកិច្ចរវាងបុរសដែលមានចំណងអាពាហ៍ពិពាហ៍ពីមុនមិនទាន់រលាយជាមួយស្ត្រីដទៃក្រៅពីប្រពន្ធរបស់ខ្លួន ឬ ការរួមសេវនកិច្ចរវាងស្ត្រីដែលមានចំណងអាពាហ៍ពិពាហ៍មិនទាន់រលាយជាមួយបុរសដទៃក្រៅពីប្តីរបស់ខ្លួន។ [8]

### ៣.២ ការបោះបង់សហព័ន្ធចោល ដោយគ្មានមូលហេតុត្រឹមត្រូវ[9]

ការបោះបង់សហព័ន្ធចោល ដោយគ្មានមូលហេតុត្រឹមត្រូវ នៅត្រង់នេះមានន័យថា សហព័ទ្ធណាមួយ ឬប្តី ប្រពន្ធណាមួយ បានចុះចោលឬចាកចេញដោយគ្មានមូលហេតុដោយផ្ទុយ នឹងគោលបំណងនៃការរៀបអាពាហ៍ពិពាហ៍ ពោលគឺសហព័ទ្ធ ម្ខាងមិនយកចិត្តទុកដាក់ ទៅលើសហព័ទ្ធម្ខាងទៀត ។

### ៣.៣ ការមិនដឹងច្បាស់ថាសហព័ទ្ធស្លាប់ ឬ រស់ អស់រយៈពេលជាង ១ ឆ្នាំ[10]

ប្រសិនបើសហព័ទ្ធណាមួយបានចាកចេញ ឬចុះចោលសហព័ទ្ធម្ខាងទៀតដោយបាត់ដំណឹងសូន្យគ្មានបានផ្តល់ដំណឹងឲ្យសហព័ទ្ធមួយទៀត ឲ្យបានដឹងហើយបានចុះចោលជិតមួយឆ្នាំ សហព័ទ្ធណាមួយអាចអាចដាក់ពាក្យសុំលែងលះ ឬជូនដំណឹងទៅឃុំ សង្កាត់ឲ្យបានដឹងពីរឿងនេះ ។

### ៣.៤ ការរស់នៅបែកគ្នាជាបន្តបន្តបន្ទាប់ អស់រយៈពេលជាង ១ ឆ្នាំ[11]

ការរស់នៅបែកគ្នាជាបន្តបន្តបន្ទាប់ អស់រយៈពេលជាង ១ ឆ្នាំ ត្រង់នេះមានន័យថា សហព័ទ្ធបានរស់នៅបែកគ្នាជាបន្តបន្ទាប់ដោយមិនបានរួមរស់នៅជាមួយគ្នាសោះ អស់រយៈពេលជាង ១ ឆ្នាំ ទោះបីជាបានដំណឹងពី

---

[7] មាត្រា ៩៧៨ កថាខណ្ឌ១ ចំណុច " ក" នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[8] មាត្រា ៧ នៃច្បាប់ស្តីពីឯកពន្ធភាពចុះថ្ងៃទី ០១ កញ្ញា ឆ្នាំ ២០០៦

[9] មាត្រា ៩៧៨ កថាខណ្ឌ១ ចំណុច " ខ" នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[10] មាត្រា ៩៧៨ កថាខណ្ឌ១ ចំណុច " គ" នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[11] មាត្រា ៩៧៨ កថាខណ្ឌ១ ចំណុច " ឃ" នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

គ្នាក៏ដោយ ដែលទាំងនេះផ្ទុយទៅនឹងគោលបំណងនៃអាពាហ៍ពិពាហ៍ នោះសហព័ទ្ធណាមួយអាចដាក់ពាក្យសុំលែងលះបាន។ ក៏ប៉ុន្តែចំពោះការរស់នៅឆ្ងាយដោយសារការងារមិនចាត់ចូលទៅក្នុងចំណុចនេះទេ ។

### ៣.៥ ករណីផ្សេងៗទៀត[12]

នៅក្នុងករណីនៃចំណុចនេះ ហាក់មានន័យទូលំទូលាយណាស់ និយាយជារួមប្រសិនបើ មានមូលហេតុផ្សេងដែលមិនចូលក្នុងចំណុច ១.១ ដល់ ១.៤ នោះអាចនឹងត្រូវបានគេរាប់បញ្ចូលទៅក្នុងចំណុចនេះ។ ស្ថានភាពផ្សេងៗក្នុងចំណុចនេះ ចង់មានន័យថា តុលាការនឹងពិចារណាលើស្ថានភាពមួយចំនួនផ្សេងទៀតរួមមាន សកម្មភាព និងអាកប្បកិរិយារបស់អ្នកទាំងពីរក្នុងអំឡុងអាពាហ៍ពិពាហ៍ មានភាពរកាំរកូសគ្នាខ្លាំងដែរឬទេ? មានអំពើហិង្សាធ្ងន់ធ្ងរឬទេ? ជាពិសេសមើលទៅលើឆន្ទៈរបស់ពួកគេចង់បន្តចំណងអាពាហ៍ពិពាហ៍ឬទេ ?

**បើយោងតាមច្បាប់អាពាហ៍ពិពាហ៍និងគ្រួសារ** ការលែងលះដោយឯកតោភាគីអាចនឹងធ្វើឡើងទៅបានលុះត្រាតែមានមូលហេតុត្រឹមត្រូវ និងគ្រាប់គ្រាន់បញ្ជាក់បានថាសហព័ទ្ធទាំងពីរ ពុំអាចរស់នៅជាមួយគ្នាតទៅទៀតបាន មូលហេតុទាំងនោះរួមមានជាអាទិ៍[13]៖

- ការចុះចោលលំនៅសង្វាសដោយឥតមូលហេតុត្រឹមត្រូវ ហើយឥតមានផ្គត់ផ្គង់ស្បៀងអាហារ និង ទំនុកបំរុងកូនសោះ ។
- វាយដំ ឃោរឃៅ ធ្វើទុក្ខបុកម្នេញ ប្រមាថមើលងាយធ្ងន់ធ្ងរចំពោះសហព័ទ្ធ ឬ បុព្វជាតិរបស់សហព័ទ្ធនោះ ។
- ចរិយាផ្ទុយពីសីលធម៌ និងការប្រព្រឹត្តអានាចារ
- អពលានុភាពនៃលិង្គ
- បែកគ្នាអស់រយៈពេលជាង ១ ឆ្នាំ ។

[12] មាត្រា ៩៧៨ កថាខណ្ឌ១ ចំណុច " ង" នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[13] មាត្រា ៣៩ នៃច្បាប់ ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ឆ្នាំ ១៩៨៩

# ជំពូកទី ២

# នីតិវិធីនៃការលែងលះ ឬការផ្ដាច់នីតិសង្វាស

# ជំពូកទី ២
# នីតិវិធីនៃការលែងលះ ឬការផ្តាច់នីតិសម្ព័ន្ធ

## ផ្នែកទី១៖ នីតិវិធីនៃការលែងលះ ក្នុងករណីគ្មានការព្រមព្រៀង

### ១.១. នីតិវិធីនៃបណ្តឹងលែងលះ

#### ១.១.១.ការផ្តើមនៃបណ្តឹងលែងលះ

នៅក្នុងដំណើរការនីតិវិធី ចំពោះរឿងក្តីលែងលះដោយគ្មានការព្រមព្រៀង គឺត្រូវអនុលោមតាមក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦។ បើភាគីណាមួយដែលជាសហព័ទ្ធ (ប្តី/ប្រពន្ធ) ដែលមានបំណងពិតប្រាកដក្នុងការលែងលះ ដោយផ្អែកលើមូលហេតុត្រឹមត្រូវ អាចដាក់ពាក្យបណ្តឹងទៅតុលាការដែលមានសមត្ថកិច្ចដោយយោងតាមមាត្រា ១០ (សមត្ថកិច្ចជម្រះក្តីពិសេសលើរឿងក្តីលែងលះគ្នា និងរឿងក្តីអំពីបុគ្គភាព) នៃក្រមនីតិរដ្ឋប្បវេណីបាន[14]។ បានន័យថា សមត្ថកិច្ចផ្តាច់មុខរបស់សាលាដំបូងដែលមានសមត្ថកិច្ច នៅលំនៅឋានរបស់ភាគីនៃទំនាក់ទំនងឋានៈបុគ្គលដែលពាក់ព័ន្ធនឹងបណ្តឹងនោះ។ មួយវិញទៀត តុលាការអាចដំណើរការរឿងក្តីនេះបានតាមរយៈការដាក់ពាក្យបណ្តឹងរបស់ដើមបណ្តឹង ហើយនៅក្នុងពាក្យបណ្តឹងត្រូវសរសេរឲ្យបានត្រឹមត្រូវទៅតាមលក្ខខណ្ឌទម្រង់ដែលច្បាប់បានកំណត់។

**ក. ការសរសេរពាក្យបណ្តឹងលែងលះ**

នៅក្នុងការសរសេរពាក្យបណ្តឹងលែងលះ គេត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរដោយត្រូវធ្វើការរៀបរាប់ពីមូលហេតុដែលសហព័ទ្ធសុំលែងលះគ្នា និងត្រូវចុះហត្ថលេខាដោយសហព័ទ្ធដែលជាអ្នកប្តឹង។ សហព័ទ្ធដែលជាអ្នកប្តឹងហៅថា ភាគីដើមបណ្តឹង ឬដើមចោទ ឯសហព័ទ្ធដែលទទួលរងការប្តឹងហៅថា ចុងចម្លើយ។ រាល់ពាក្យបណ្តឹងលែងលះ ត្រូវធ្វើឡើងដោយ សរសេរនូវរាល់ចំណុចដូចដែលមានចែងនៅក្នុងមាត្រា ៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចំពោះការសរសេរពាក្យបណ្តឹងត្រូវធ្វើជាលាយលក្ខណ៍អក្សរ ជូនទៅតុលាការ បញ្ជាក់ពីមូលហេតុ នាមករណ៍ អាសយដ្ឋានជាដើម។

នៅពេលដែលដាក់ពាក្យបណ្តឹងជូនទៅតុលាការ ភាគីដើមបណ្តឹងត្រូវបង់ពន្ធដាក់ពាក្យបណ្តឹងលែងលះ ៥៥០០០ រៀល ហើយបន្ថែមពីនេះទៅទៀត ភាគីដើមចោទត្រូវបង់ប្រាក់ប្រដាប់ក្តីក្រៅពីពន្ធ ដូចជា ចំនួនទឹក

[14] មាត្រា ៩៨២ កថាខណ្ឌ១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

ប្រាក់ចាំបាច់ ដើម្បីឲ្យតុលាការពិនិត្យភស្តុតាងការបញ្ជូនឯកសារ ឬប្រាក់មួយចំនួនសម្រាប់សោហ៊ុយធ្វើដំណើរ ព្រមទាំងការស្នាក់នៅរបស់ចៅក្រម និងក្រឡាបញ្ជីសម្រាប់ដំណើរការនៃការពិនិត្យភស្តុតាង និងសោហ៊ុយផ្សេងទៀតទៅតាមនីតិវិធីក្នុងបណ្ដឹងរដ្ឋប្បវេណី ដើម្បីដំណើរការស៊ើបអង្កេតរឿងនោះ[15]

ជាទូទៅក្នុងបណ្ដឹងរដ្ឋប្បវេណី ច្បាប់តម្រូវឲ្យភាគីនីមួយ ជាអ្នកស្វែងរកភស្តុតាងដាក់ជូនតុលាការដោយខ្លួនឯង នៅក្នុងពាក្យបណ្ដឹង បើភាគីណាមានចំណុចណាដែលត្រូវទាមទារ តុលាការនឹងសម្រេចសេចក្ដីទៅតាមពាក្យសុំត្រង់ចំណុចនោះ ដោយផ្អែកលើភស្តុតាងដែលភាគីបានបង្ហាញដល់តុលាការ។ ចំពោះចំណុចដែលភាគីមិនបានទាមទារ ឬភ្លេចទាមទារ តុលាការមិនធ្វើការសម្រេចសេចក្ដីទៅលើចំណុចនោះឡើយ។

**ខ. កន្លែងដាក់ពាក្យបណ្ដឹង**

ជាទូទៅទីកន្លែងនៃការដាក់ពាក្យបណ្ដឹងលែងលះ គឺគូភាគីនៃបណ្ដឹងជាអ្នកជ្រើសរើសកន្លែងនៃការដាក់ពាក្យ។ ភាគីអាចដាក់ពាក្យបណ្ដឹងដោយផ្ទាល់ទៅតុលាការរាជធានី ឬខេត្ត ឬក្រុមប្រឹក្សាឃុំ-សង្កាត់នៃលំនៅឋានភាគីប្ដី ឬប្រពន្ធ។ ចំពោះករណីដែលលំនៅឋានរបស់ភាគីមិនស្ថិតនៅប្រទេសកម្ពុជា ឬលំនៅឋាននៅប្រទេសកម្ពុជាមិនពិតប្រាកដទេ តុលាការដែលមានសមត្ថកិច្ចជម្រះក្ដីជាអ្នកកំណត់តាមទីសំណាក់របស់ភាគីចុងចម្លើយ បើពុំមានទីសំណាក់ពិតប្រាកដទេ តុលាការត្រូវកំណត់តាមលំនៅឋានចុងក្រោយ[16] ហេតុផលដើម្បីធានាថាចុងចម្លើយនឹងទទួលបានការជូនដំណឹងថា ប្ដី ឬប្រពន្ធរបស់គេបានដាក់ពាក្យបណ្ដឹងសុំលែងលះរូបគេ។

### ១.១.២ ការផ្សះផ្សា

ក្រោយពីក្រុមប្រឹក្សាឃុំ-សង្កាត់ ឬតុលាការទទួលបានពាក្យបណ្ដឹងជាផ្លូវការ ដែលភាគីទាមទារលែងលះគ្នា ក្រុមប្រឹក្សាឃុំ-សង្កាត់និងតុលាការត្រូវមាននីតិវិធីមួយគឺការផ្សះផ្សា។ មុននឹងធ្វើការផ្សះផ្សាត្រូវពិនិត្យមើលសំណុំឯកសារដែលពាក់ព័ន្ធ គឺសំបុត្រអាពាហ៍ពិពាហ៍ ដើម្បីបញ្ជាក់ថាពួកគេពិតជាប្ដី ប្រពន្ធស្របតាមច្បាប់។

**ក. ការផ្សះផ្សានៅថ្នាក់ឃុំ /សង្កាត់**

នៅពេលដែលមានភាគីណាម្ខាង (ប្ដី/ប្រពន្ធ) បានដាក់ពាក្យបណ្ដឹងលែងលះទៅក្រុមប្រឹក្សាឃុំ-សង្កាត់ឲ្យដោះស្រាយមុនដាក់ទៅតុលាការ មន្ត្រីត្រូវសាកល្បងធ្វើការផ្សះផ្សាក្នុងរយៈពេល ១៥ ថ្ងៃក្រោយពីទទួលពាក្យ

[15] មាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

[16] មាត្រា ៨ និង មាត្រា ១០ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

បណ្តឹង។ ប៉ុន្តែបើភាគីទាំងពីរមិនព្រមបន្តការរួមរស់នៅជាមួយគ្នាទេ ក្រុមប្រឹក្សាឃុំ-សង្កាត់ ត្រូវចាត់ទុកថា មានពាក្យបណ្តឹងសុំលែងលះ ហើយត្រូវបញ្ជូនទៅតុលាការជាបន្ទាន់[17]។ បើទោះបីជាក្រមរដ្ឋប្បវេណីពុំបានចែងពីការផ្សះផ្សាត្រូវធ្វើឡើងច្រើនដងឬក៏ដោយ ក៏ការអនុវត្តរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់អាចព្យាយាមធ្វើការផ្សះផ្សាជាច្រើនដងមុននឹងបញ្ជូនរឿងទៅតុលាការ។

**ខ. ការផ្សះផ្សាដោយតុលាការ**

ចំពោះនីតិវិធីនៅតុលាការមានលក្ខណៈដូចគ្នា មិនថាតុលាការទទួលបណ្តឹងដោយផ្ទាល់ពីភាគីដើមចោទ ឬតុលាការទទួលពាក្យបណ្តឹងពីមេឃុំ ចៅសង្កាត់ទេ ក្រោយទទួលពាក្យបណ្តឹងតុលាការត្រូវចាត់តាំងចៅក្រមមួយរូបដើម្បីធ្វើការផ្សះផ្សា។ ទោះបីជាសហព័ទ្ធម្ខាង ទាមទារលែងលះគ្នាខ្លាំងយ៉ាងណា ក៏តុលាការអាចនឹងធ្វើការផ្សះផ្សាដោយឆន្ទានុសិទ្ធិ[18]។ ការផ្សះផ្សា គឺមិនមែនធ្វើឲ្យភាគីសះជាគ្នាដោយការលះបង់ការទាមទារ ឬទទួលស្គាល់ការទាមទារនោះទេ គឺផ្សះផ្សាដើម្បីឲ្យមានការដកពាក្យបណ្តឹងលែងលះវិញ ហើយរួមរស់នៅជាមួយគ្នាជាប្តីប្រពន្ធវិញ។

**គ. ការហាមឃាត់ការផ្សះផ្សាក្នុងករណីអំពើហិង្សា ក្នុងគ្រួសារធ្ងន់ធ្ងរ**

ករណីដែលមានបណ្តឹងលែងលះគ្នា អាជ្ញាធរមានសមត្ថកិច្ចអាចធ្វើការផ្សះផ្សា ករណីដែលបណ្តឹងលែងលះនោះ មិនមានប្រើអំពើហិង្សា ឬករណីមានប្រើអំពើហិង្សាដែលជាបទល្មើសប៉ះពាល់ខាងផ្លូវកាយ ឬផ្លូវចិត្តបទល្មើសមជ្ឈិមស្រាល ឬបទលហុ។ ចំពោះការផ្សះផ្សា ឬការសម្រុះសម្រួលអាចធ្វើទៅបានតាមការយល់ព្រមពីភាគីទាំងសងខាង។

ក្នុងករណីបណ្តឹងលែងលះគ្នាដែលមានលក្ខណៈជាបទឧក្រដ្ឋិ ឬជាបទមជ្ឈិមធ្ងន់ធ្ងរ អាជ្ញាធរមានសមត្ថកិច្ចពុំអាចធ្វើអន្តរាគមន៍ ដើម្បីផ្សះផ្សាឬសម្របសម្រួលបានទេ [19] ។ រីឯអំពើហិង្សាដែលមានចរិតជាបទល្មើសព្រហ្មទណ្ឌ ដែលមានលក្ខណៈជាបទឧក្រិដ្ឋ ឬជាបទមជ្ឈិមធ្ងន់ធ្ងរ ត្រូវតែជាកម្មវត្ថុនៃបណ្តឹងអាជ្ញាទោះបីជាអំពើហិង្សានេះ បានកន្លងទៅហើយក៏ដោយ។

---

[17] មាត្រា ៩៨២ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[18] មាត្រា ៩៨៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[19] មាត្រា ១៧ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០០៥

### ១.១.៣ ការចាត់ចែងរក្សាការពារ

ពេលខ្លះការលែងលះគ្នា គឺត្រូវការពេលវេលាមួយយ៉ាងវែង ជាពិសេសពេលមានការសាកល្បងជាច្រើនលើក ដើម្បីផ្សះផ្សាសហព័ទ្ធទាំងពីរ។ នៅពេលមានករណីដូច្នេះ តុលាការអាចនឹងចេញវិធានការបណ្តោះអាសន្ន វិធានការនេះចែងការពារ ដើម្បីដោះស្រាយបញ្ហាខ្លះរវាងសហព័ទ្ធទាំងពីរ ក្នុងពេលដែលគេរង់ចាំសាលក្រមស្ថាពរនៃការលែងលះ ។ វិធានការនេះ គឺជាការណែនាំ ឬបញ្ជារបស់តុលាការបង្គាប់ទៅភាគីសហព័ទ្ធ ហើយចៅក្រមត្រូវចុះក្នុងកំណត់ត្រារបស់តុលាការ ។ យោងតាមមាត្រា ៩៨៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ អនុញ្ញាតអោយតុលាការចេញនូវវិធានការចាត់ចែងរក្សាការពារដូចជា៖ វិធានការដាក់អោយសហព័ទ្ធរស់នៅបែកគ្នា វិធានការដាក់អោយមានការថែរក្សាកូនបណ្តោះអាសន្ន វិធានការទាក់ទងដល់ការថែរក្សាទ្រព្យសម្បត្តិជាបណ្តោះអាសន្ន វិធានការទាក់ទងទៅនឹង ការគ្រប់គ្រងសហព័ទ្ធ ឬផ្គត់ផ្គង់កូន និងវិធានការរឹបអូសជាបណ្តោះអាសន្ន ។

#### ក. វិធានការដាក់អោយសហព័ទ្ធរស់នៅបែកគ្នា

ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ អនុញ្ញាតអោយតុលាការចេញវិធានការអោយភាគីទាំងអស់រស់នៅបែកគ្នាបណ្តោះអាសន្ន ក្នុងអំឡុងពេលនៃនីតិវិធីលែងលះគ្នា ក្នុងករណីភាគីទាំងពីរមានប្រើអំពើហិង្សាក្នុងគ្រួសារ។

មាត្រា ១៤ នៃច្បាប់ស្តីពីការទប់ស្កាត់អំពីហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះបានផ្តល់សិទ្ធិអំណាចទៅដល់មេឃុំ ចៅសង្កាត់ អាចចាត់វិធានការបណ្តោះអាសន្នដែលមានដូចជា ៖

_ ហាមប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារដោយខ្លួនឯងផ្ទាល់ ឬដោយអ្នកផ្សេង។

_ ហាមបំផ្លាញទ្រព្យសម្បត្តិ ឬណែនាំកុំអោយចាត់ចែងទ្រព្យសម្បត្តិរួម ឬរបស់ជនរងគ្រោះ ឬរបស់ញាតិរបស់ជនរងគ្រោះ ។

_ ហាមជនមានមុខសញ្ញាចូលជិត ឬចូលទៅក្នុងទីលំនៅរួមទីកន្លែងស្នាក់នៅ ឬកន្លែងធ្វើការរបស់ជនរងគ្រោះបើគ្មានការអនុញ្ញាតពីជនរងគ្រោះ និងអាជ្ញាធរមានសមត្ថកិច្ច។

_ ចាត់វិធានការស្របច្បាប់ផ្សេងទៀតដែលចាំបាច់ សម្រាប់ការពារសុវត្ថិភាពជនរងគ្រោះ និងសមាជិកគ្រួសារ ឬជនបានដែលពាក់ព័ន្ធ ។

ទន្ទឹមនឹងការធ្វើអន្តរាគមន៍របស់អាជ្ញាធរមានសមត្ថកិច្ច ជនរងគ្រោះអាចធ្វើបណ្តឹងទៅតុលាការរាជធានីខេត្ត ដើម្បីសុំចេញដីកាការពារ។ តុលាការដែលទទួលបណ្តឹងអាចចេញដីកាការពារដោយមានវត្តមាន ឬពុំ

ចាំបាច់មានវត្តមានសហព័ទ្ធដែលបានប្រើអំពើហិង្សា។ ចំពោះប្តីដែលតែងតែប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារ ក្នុងអំឡុងពេលមានចំណងអាពាហ៍ពិពាហ៍ ហើយប្រពន្ធបានដាក់ពាក្យប្តឹងលែងលះ ដែលធ្វើឲប្តីកាន់តែប្រព្រឹត្តអំពើហិង្សានោះកាន់តែខ្លាំងឡើងៗ។ ចំពោះករណីនេះ ដើម្បីការពារសុវត្ថិភាពប្រពន្ធ កូន ច្បាប់បានតម្រូវឲ្យប្តីដែលប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារ រស់នៅបែកពីប្រពន្ធ។

**ខ. វិធានការដាក់ឲរាយមានការថែរក្សាកូនបណ្តោះអាសន្ន**

ប្រសិនបើភាគីទាំងពីរ មិនព្រមព្រៀងគ្នាលើការថែរក្សាកូនក្នុងអំឡុងពេល នៃនីតិវិធីលែងលះគ្នា ចៅក្រមអាចចេញវិធានការកំណត់ថា តើឪពុក ឬម្តាយដែលត្រូវថែរក្សាកូនជាបណ្តោះអាសន្ន។ ដូចដែលយើងនឹងពិភាក្សាជាលំអិតនៅពេលក្រោយ ឪពុកម្តាយដែលទទួលភារកិច្ច ថែរក្សាកូន ជាទូទៅមានន័យថា ជាឪពុកម្តាយដែលមានអំណាចធ្វើសេចក្តីសម្រេចទាក់ទងនឹងកូន ដែលច្បាប់ហៅថា ឪពុកម្តាយមានអំណាចមេបា ហើយជាឪពុកម្តាយដែលរស់នៅ ជាមួយកូននោះ។

ចំពោះក្រមរដ្ឋប្បវេណីមិនបានចែងច្បាស់ថា ចៅក្រមជាអ្នកត្រូវសម្រេចឲ្យឪពុក ឬម្តាយថែរក្សាកូនជាបណ្តោះអាសន្នក្នុងអំឡុងពេលនីតិវិធីនៃការលែងលះទេ។

ទោះបីជាមិនមានចែងនៅក្នុងក្រមរដ្ឋប្បវេណីក៏ដោយ ក៏មានប្រភពផ្សេងៗទៀតដែលចៅក្រមអាចយកមកធ្វើជាមូលដ្ឋានសម្រាប់ការពិចារណាបាន៖

- ទី ១ ចៅក្រមអាចពិនិត្យមើលទៅលើ ប្រពៃណីទំនៀមទំលាប់ ដើម្បីអាចធ្វើជាប្រភព នៃគោលការណ៍ណែនាំមួយ។
- ទី ២ ចៅក្រមអាចពិនិត្យមើលទៅលើបទដ្ឋានគតិយុត្ត ដែលប្រទេសដទៃទៀតធ្លាប់បានធ្វើ។
- ទី ៣ ចៅក្រមអាចពិនិត្យមើលទៅលើច្បាប់អន្តរជាតិ ដូចជាអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ។

**គ. វិធានការទាក់ទងដល់ការថែរក្សាទ្រព្យសម្បត្តិជាបណ្តោះអាសន្ន**

ចៅក្រមមានអំណាចចេញវិធានការបណ្តោះអាសន្នស្តីពីការថែរក្សា ការពារ និងប្រើប្រាស់ទ្រព្យសម្បត្តិក្នុងអំឡុងពេលនីតិវិធីនៃការលែងលះ។ វិធានការនេះមានសារៈសំខាន់ ពីព្រោះសហព័ទ្ធមួយអាចព្យាយាមយកឬក៏លក់ ឬផ្ទេរទ្រព្យសម្បត្តិ មុនពេលដែលតុលាការមានឱកាសស៊ើបអង្កេតនិងធ្វើការបែងចែកទ្រព្យសម្បត្តិដោយយុត្តិធម៌។ មួយវិញទៀត ក៏ជួយមិនឲ្យភាគីម្ខាងទៀត យកទៅលក់ ធ្វើឲ្យខូចខាត ឬបំផ្លិចបំផ្លាញទ្រព្យសម្បត្តិនោះ។ ប្រសិនបើសហព័ទ្ធទាំងពីរជាម្ចាស់ផ្ទះ ចៅក្រមអាចសម្រេចថា អ្នកណានឹងរស់នៅផ្ទះនោះ ក្នុងអំឡុងពេលនៃដំណើរការនីតិវិធីការលែងលះគ្នានោះ។

**ឃ. វិធានការទាក់ទងទៅនឹង ការគ្រប់គ្រងសហព័ទ្ធ ឬផ្គត់ផ្គង់កូន**

តុលាការមានសិទ្ធិអំណាចក្នុងការចេញវិធានការបណ្តោះអាសន្នស្តីពីការផ្គត់ផ្គង់កូនបណ្តោះអាសន្ន ហើយក្នុងករណីចាំបាច់ តុលាការក៏អាចសម្រេចឲ្យមានការផ្គត់ផ្គង់ដល់សហព័ទ្ធ។

ជាទូទៅនៅក្នុងប្រទេសកម្ពុជា និងនៅប្រទេសដទៃទៀត តុលាការនឹងពិចារណាលើកត្តា ៣ យ៉ាង ដូចជាៈ

- សេចក្តីត្រូវការរបស់កូន
- លទ្ធភាពខាងហិរញ្ញវត្ថុរបស់ឪពុក ឬម្តាយដែលត្រូវបានគេស្នើឲ្យសុំប្រាក់ផ្គត់ផ្គង់
- ស្ថានភាពហិរញ្ញវត្ថុរបស់ឪពុក ឬម្តាយដែលកូនត្រូវរស់នៅជាមួយ។

តុលាការក៏អាចផ្តល់ការផ្គត់ផ្គង់បណ្តោះអាសន្ន ដល់សហព័ទ្ធដែលត្រូវការប្រាក់ ក្នុងអំឡុងពេលនីតិវិធីនៃការលែងលះគ្នា។ ជាទូទៅតុលាការចេញវិធានការបណ្តោះអាសន្ន បើអាចធ្វើបានដើម្បីរក្សាកម្រិតជីវភាពសហព័ទ្ធដែលធ្លាប់ទទួលបានការផ្គត់ផ្គង់ដូចក្នុងពេលមានចំណងអាពាហ៍ពិពាហ៍។ វិធានការស្តីពីការផ្គត់ផ្គង់សហព័ទ្ធជាបណ្តោះអាសន្ននេះ មិនអនុវត្តជាចាំបាច់ចំពោះការផ្គត់ផ្គង់ជាអចិន្ត្រៃយ៍នោះទេ។

**ង. វិធានការរឹបអូសជាបណ្តោះអាសន្ន**

នៅក្នុងករណីមានបណ្តឹងលែងលះគ្នា តុលាការក៏អាចចេញវិធានការឲ្យធ្វើការរឹបអូសជាបណ្តោះអាសន្ននូវទ្រព្យសម្បត្តិដែលជាចលនទ្រព្យ ឬអចលនទ្រព្យរបស់សហព័ទ្ធ ឬវត្ថុតាងណាមួយដោយឆន្ទានុសិទ្ធិបានដែរ ទោះបីភាគីមិនបានស្នើសុំក៏ដោយ។ នេះពិតមានការសំខាន់យ៉ាងខ្លាំង ដើម្បីថែរក្សាទ្រព្យសម្បត្តិ ឬភស្តុតាងនានាដើម្បីបង្ការ កុំឲ្យសហព័ទ្ធម្ខាងទៀតបំផ្លាញ ឬធ្វើឲ្យមានការខូចខាតទ្រព្យសម្បត្តិ ឬមានការចាត់ចែងផ្សេងដូចជាការលក់ដូរ ការជួល ឬបញ្ចាំ ការធ្វើអំណោយជាដើម។

## ១.២ នីតិវិធីនៃការជម្រះក្តី

នីតិវិធីនៃការជម្រះក្តីក្នុងរឿងក្តីរដ្ឋប្បវេណី សម្រាប់អាពាហ៍ពិពាហ៍ដែលស្របច្បាប់ដែលមានចែង នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីដែលមានលក្ខណៈលម្អិតជាងពេលមុន ដែលទាមទារឲ្យប្រើពេលវេលាយូរ និងមាននីតិវិធីសាំញ៉ាំជាងមុន។

### ១.២.១ ការពិនិត្យលើពាក្យបណ្តឹង

ក្រោយពេលតុលាការបានទទួលពាក្យបណ្តឹងហើយត្រូវចាត់ការត្រួតពិនិត្យលើពាក្យបណ្តឹងនោះករណីចៅក្រមឃើញថាក្នុងពាក្យបណ្តឹងនោះមានភាពខ្វះខាត ដូចជាការមិនបានបង់ពន្ធជាដើម តុលាការត្រូវកំណត់

ពេលសមរម្យ និងបង្គាប់ដើមចោទឲ្យធ្វើការកែតម្រូវចំណុចខ្វះខាតទាំងនោះ[20]។ ប៉ុន្តែក្រមនីតិវិធីរដ្ឋប្បវេណី មិនបានកំណត់ជាក់ច្បាស់អំពីថេរវេលាប៉ុន្មានដែលតុលាការត្រូវពិនិត្យលើពាក្យបណ្តឹងថា មានខ្វះចន្លោះត្រង់ណាដែលនាំឲ្យដំណើរការប្រើរយៈយូរ និងជាហេតុដែលនាំឲ្យភាគីនោះជួបការលំបាក។

### ១.២.២ ការបញ្ជូនពាក្យបណ្តឹងទៅចុងចម្លើយ

ប្រសិនបើពាក្យបណ្តឹងមានលក្ខណៈត្រឹមត្រូវហើយ តុលាការត្រូវបញ្ជូនពាក្យបណ្តឹងទៅអោយចុងចម្លើយឲ្យបានដឹង ហើយធ្វើការឆ្លើយតប ឬទប់ទល់វិញ។ ការបញ្ជូននេះជាការធ្វើឲភាគីម្ខាងទៀតបានដឹងអំពីបណ្តឹងថា បុគ្គលណាជាអ្នកប្តឹង កម្មវត្ថុនៃបណ្តឹងជាអ្វី និងមធ្យោបាយតទល់របស់អ្នកប្តឹងជាដើម ហើយវាជាការផ្តល់ឱកាសឲ្យភាគីម្ខាងទៀតឆ្លើយដោះសារ និងរៀបចំមធ្យោបាយការពារខ្លួន។ ពេលពាក្យបណ្តឹងបានបញ្ជូនដល់ចុងចម្លើយហើយទើបចុងបណ្តឹងនោះត្រូវបានចាត់ការ។

### ១.២.៣ ការកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមទាញហេតុផលលើកដំបូង

នៅពេលពាក្យបណ្តឹងដែលត្រូវបានដាក់នោះ វាមានគ្រប់លក្ខណៈហើយ តុលាការត្រូវកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលយ៉ាងឆាប់រហ័ស។

នៅពេលពាក្យបណ្តឹងដែលត្រូវបានដាក់នោះ មានគ្រប់លក្ខណៈហើយតុលាការត្រូវកំណត់កាលបរិច្ឆេទនៃនីតិវិធីនេះត្រៀមសម្រាប់ការទាញហេតុផលយ៉ាងឆាប់រហ័ស។ សម្រាប់នីតិវិធីត្រៀមទាញហេតុផលលើកដំបូង តុលាការត្រូវកំណត់រយៈពេល ៣០ ថ្ងៃ គិតចាប់ពីថ្ងៃដែលពាក្យបណ្តឹងត្រូវបានដាក់ដល់តុលាការ ដោយរាប់ពីថ្ងៃដែលតុលាការតម្រូវអោយធ្វើការកែតម្រូវនូវពាក្យបណ្តឹង។ ក៏ប៉ុន្តែ នៅក្នុងករណីមានហេតុផលពិសេសដែលតុលាការមិនអាចធ្វើបាន តុលាការអាចទុករយៈពេលយូរជាងនេះបាន[21]។

### ១.២.៤ ការលើកពាក្យបណ្តឹងចោល

ក្នុងករណីពាក្យបណ្តឹងលែងលះគ្នាដែលភាគីដើមចោទ បានដាក់ពាក្យបណ្តឹងទៅតុលាការអាចត្រូវបានតុលាការលើកចោលពាក្យបណ្តឹងនោះមិនយកមកសម្រេចសេចក្តីដោយដីកាសម្រេចរបស់តុលាការក្នុងករណីមានមូលហេតុណាមួយដូចខាងក្រោម[22]៖

[20] មាត្រា ៧៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

[21] មាត្រា ៨០ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

[22] មាត្រា ៨១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

-ដើមចោទមិនបានមកកែតម្រូវលើពាក្យបណ្តឹងដែលភាគីដើមចោទ បានដាក់ពាក្យបណ្តឹងតាមការណែនាំរបស់ចៅក្រមលើចំណុចខ្វះខាតនៃពាក្យបណ្តឹងនោះ។

-ពាក្យបណ្តឹងមានលក្ខណៈផ្ទុយនឹងច្បាប់។

**១.២.៥ ការបន្ថែម ឬការផ្លាស់ប្តូរកម្មវត្ថុនៃបណ្តឹង**

ភាគីដើមចោទធ្វើបណ្តឹងលែងលះគ្នា អាចបន្ថែម ឬអាចផ្លាស់ប្តូរនូវកម្មវត្ថុ ឬមូលហេតុនៃបណ្តឹងទាមទារបាន រហូតដល់ពេលចប់នីតិវិធីនៃការទាញហេតុផលផ្ទាល់មាត់។ ការបន្ថែម ឬការផ្លាស់ប្តូរកម្មវត្ថុនៃបណ្តឹង ត្រូវធ្វើជាលាយលក្ខណ៍អក្សរ។ ទើបតុលាការទទួលយកមកពិចារណា ហើយតុលាការក៏អាចបដិសេធមិនទទួលយកការបន្ថែម ឬការផ្លាស់ប្តូរកម្មវត្ថុនៃបណ្តឹងបានដែរ បើតុលាការយល់ឃើញថា ចាំបាច់តាមការសម្រេចដោយឆន្ទានុសិទ្ធិបាន[23]។

**១.២.៦ ការប្តឹងតបរបស់ចុងចម្លើយ**

ភាគីចុងចម្លើយ អាចប្តឹងតបទៅភាគីដើមចោទវិញបានផងដែរ នៅពេលដែលតុលាការកំពុងចាត់ការបណ្តឹងរបស់ដើមចោទរហូតដល់ពេលចប់នីតិវិធីទាញហេតុផលផ្ទាល់មាត់ នៃការជម្រះក្តីលើកទី១ ឬការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍។ ការធ្វើបណ្តឹងតបនេះបាន លុះត្រាតែការទាមទារដែលជាកម្មវត្ថុនៃបណ្តឹងតបនេះមានការទាក់ទងនឹងការទាមទារដែលជាកម្មវត្ថុនៃបណ្តឹងដើម ឬជាមធ្យោបាយការពារខ្លួនសម្រាប់តទល់ទៅនឹងបណ្តឹងរបស់ដើមចោទ។ ការធ្វើបណ្តឹងតបនឹងចុងចម្លើយ ច្បាប់មិនអនុញ្ញាតឲ្យធ្វើឡើយបើការទាមទារជាកម្មវត្ថុនៃបណ្តឹងនោះ ស្ថិតនៅក្នុងសមត្ថកិច្ចផ្តាច់មុននៃតុលាការដទៃទៀតតាមការកំណត់របស់ច្បាប់ ឬករណីដែលការប្តឹងតបនោះវា នឹងធ្វើឲ្យមានការយឺតយ៉ាវខ្លាំងនៅក្នុងនីតិវិធីនៃបណ្តឹង។

**១.២.៧ ការស៊ើបអង្កេតរបស់ចៅក្រម និងការជម្រះក្តី**

នៅពេលដែលការផ្សះផ្សារបស់តុលាការ មិនអាចនាំឲ្យសហព័ទ្ធព្រមព្រៀងគ្នាបន្តរស់នៅជាមួយគ្នាបានទេ តុលាការនឹងចេញដីកាកោះហៅសហព័ទ្ធឲ្យមកបង្ហាញខ្លួនដើម្បីស៊ើបអង្កេត និងវិនិច្ឆ័យពីបណ្តឹងលែងលះ។

នៅក្នុងករណីលែងលះដែលស្នើឡើងដោយភាគីទាំងពីរ តុលាការអាចសម្រេចឲ្យលែងលះ លុះត្រាតែការស៊ើបអង្កេតរបស់តុលាការរកឃើញថាសហព័ទ្ធទាំងពីរបានស្នើសុំលែងលះដោយស្ម័គ្រចិត្ត។ គោលបំណងសំខាន់នៃការស៊ើបអង្កេតរបស់តុលាការ គឺត្រូវរកឲ្យឃើញថា តើសហព័ទ្ធមួយត្រូវបានការបង្ខិតបង្ខំឲ្យលែងលះគ្នា ឬអត់ ឬភាគីបានព្រមព្រៀងដោយស្ម័គ្រចិត្ត។

[23] មាត្រា ៨៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

នៅក្នុងករណីដែលមានតែភាគីមួយ បានស្នើសុំលែងលះគ្នាតុលាការអាចសម្រេចឲ្យលែងលះបាន ប្រសិនបើក្រោយការស៊ើបអង្កេត តុលាការបានរកឃើញស្ថានភាពរវាងប្ដីប្រពន្ធមានកំហុសធ្ងន់ធ្ងរបង្ហាញថា ភាគីទាំងពីរមិនអាចរួមរស់ជាមួយគ្នាបាន[24]។ គោលបំណងនៃការស៊ើបអង្កេត គឺដើម្បីកំណត់ថាតើមូលហេតុនោះសមស្រប និងត្រឹមត្រូវតាមច្បាប់ដើម្បីសម្រេចផ្តល់ការលែងលះតាមច្បាប់ដែរ ឬទេ។

ដើម្បីធ្វើការស៊ើបអង្កេតការលែងលះគ្នា ក្នុងក្រមនីតិវិធីរដ្ឋប្បវេណីថ្មីមានដំណាក់កាលជាច្រើនដូចជា៖

- **ដំណាក់កាលទី១** ដំណើរការទាញហេតុផលផ្ទាល់មាត់ៈ ដើម្បីកំណត់អំពីអង្គហេតុ និងអង្គច្បាប់ឲ្យមានភាពច្បាស់លាស់ទាក់ទងនឹងបណ្ដឹងតុលាការត្រូវបង្គាប់ឲ្យភាគីទាំងពីរ ជូនភស្តុតាងចាំបាច់នានាដល់តុលាការ និងអញ្ជើញសាក្សីឲ្យចូលមកបំភ្លឺរឿងនេះដល់តុលាការ ដើម្បីឲ្យភាគីអះអាង ឬបញ្ជាក់ភស្តុតាងនានាដល់តុលាការ[25]។

នៅក្នុងដំណាក់កាលនៃការទាញហេតុផលផ្ទាល់មាត់ ច្បាប់មិនបានកំណត់អំពីកាលបរិច្ឆេទនោះទេ។ ភាគីអាចដាក់ជូនតុលាការនូវមធ្យោបាយការពារខ្លួន ឬមធ្យោបាយតទល់ជាមួយភាគីម្ខាងទៀតបាន ដែលជាមូលដ្ឋានសម្រាប់ការពិចារណា និងការចេញសាលក្រមរបស់តុលាការ។ មធ្យោបាយតទល់ ឬការពារខ្លួន ត្រូវដាក់ឲ្យតុលាការនៅពេលណាមួយសមរម្យទៅតាមដំណើរនៃបណ្ដឹង [26] ។ មធ្យោលបាយតទល់ គឺជាអ្វីៗទាំងឡាយណាដែលភាគីដើមចោទដាក់ជូនតុលាការ ដើម្បីឲ្យតុលាការយកមកធ្វើជាមូលដ្ឋាននៃពាក្យបណ្ដឹង មធ្យោបាយការពារខ្លួន គឺជាអ្វីៗទាំងឡាយណាដែលចុងចម្លើយដាក់ជូនតុលាការយកមកធ្វើជាមូលដ្ឋាននៃពាក្យសុំប្រឆាំងតបវិញ។ នៅក្នុងបណ្ដឹងរដ្ឋប្បវេណី តុលាការអាចលើកចោលមធ្យោបាយការពារខ្លួន ឬមធ្យោបាយតទល់នោះបាន តាមពាក្យស្នើសុំរបស់ភាគី ឬសម្រេចដោយឆន្ទានុសិទ្ធិរបស់ចៅក្រមផ្ទាល់ ប្រសិនបើចៅក្រមយល់ឃើញថាការដាក់មធ្យោបាយនោះនាំឲ្យយឺតយ៉ាវក្នុងការបញ្ចប់នៃនីតិវិធីបណ្ដឹង [27] ។ដោយសារភាគីដាក់នូវមធ្យោបាយការពារខ្លួន ឬមធ្យោបាយតទល់យឺតយ៉ាវ និងមិនត្រូវសមរម្យនឹងពេលវេលាដោយសារចេតនា ឬដោយកំហុសធ្ងន់ធ្ងររបស់ភាគី ឬដោយសារអត្ថន័យមិនច្បាស់លាស់ជាដើម។

[24] មាត្រា ៩៧៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦
[25] មាត្រា ៩០ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦
[26] មាត្រា ៩៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦
[27] មាត្រា ៩៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

ក្នុងករណីដែលភាគីណាមួយមិនបានអះអាងអំពីអង្គហេតុដែលខ្លួនមាន ប្រាប់ទៅតុលាការទេ តុលាការអាចយកអង្គហេតុដែលខ្លួនបានដឹង មកធ្វើជាមូលដ្ឋាននៃការសម្រេចសេចក្តីបាន ព្រោះនៅក្នុងរឿងក្តីបណ្តឹងលែងលះគ្នា ភាគីជាអ្នកអះអាងអង្គហេតុស្វែងរកភស្តុតាង និងជាអ្នកបង្ហាញភស្តុតាងជូនតុលាការដោយខ្លួនឯង ព្រះរាជអាជ្ញានិងតុលាការ ដែលជាអ្នកចូលរួមការអះអាងពីភស្តុតាង អាចស្រាវជ្រាវអង្គហេតុដោយឆន្ទានុសិទ្ធិបាន[28]។

នៅក្នុងបណ្តឹងរដ្ឋប្បវេណីជាទូទៅ ក្នុងករណីដែលភាគីណាមួយមិនបានបង្ហាញច្បាស់លាស់ នូវឆន្ទៈតវ៉ាអំពីអង្គហេតុដែលភាគីម្ខាងទៀតបានអះអាង នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងការទាញហេតុផលផ្ទាល់មាត់ទេ ច្បាប់ចាត់ទុកថាភាគីនោះបានសារភាពចំពោះអង្គហេតុ។ សម្រាប់បណ្តឹងលែងលះគ្នា ឬបណ្តឹងទាក់ទងនឹងឋានៈបុគ្គលត្រូវបានលើកលែងផងដែរ ដោយតុលាការមិនអាចសំអាងថា ភាគីមួយទៀតនោះមិនបានតវ៉ា ឬឆ្លើយតប ត្រូវចាត់ទុកថាបានសារភាពនោះទេ។ តុលាការត្រូវតែស្វែងរកការពិតដោយការសាកសួរទៅភាគីនោះ ឬស្វែងរកភស្តុតាងតាមមធ្យោបាយផ្សេងទៀត[29]។

- **ដំណាក់កាលទី២** ឯកសារត្រៀមៈ នៅពេលធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងការទាញហេតុផលផ្ទាល់មាត់ តុលាការអាចបង្គាប់ឲ្យភាគីដាក់ឯកសារត្រៀមបាន។ សម្រាប់ឯកសារត្រៀម ភាគីត្រូវសរសេរអំពីមធ្យោបាយតទល់ ឬការពារខ្លួន និងសេចក្តីថ្លែងការណ៍ចំពោះមធ្យោបាយតទល់ ឬការពាររបស់ភាគីម្ខាងទៀត។ ក្នុងឯកសារត្រៀមដែលចុងចម្លើយដាក់ទៅតុលាការលើកដំបូង ត្រូវសរសេរអំពីការឆ្លើយតបចំពោះខ្លឹមសារនៃសាលក្រមដែលដើមចោទបានសរសេរទាមទារក្នុងពាក្យបណ្តឹង និងការទទួលស្គាល់អង្គហេតុ ឬមិនទទួលស្គាល់អង្គហេតុដែលមានសរសេរនៅក្នុងបណ្តឹង និងអង្គហេតុដើម្បីតវ៉ាចំពោះអង្គហេតុដែលមានសរសេរនៅក្នុងពាក្យបណ្តឹង[30]។ ទាក់ទងទៅនឹងពេលវេលាគឺតុលាការ ជាអ្នកកំណត់ថាពេលវេលាណា សមស្របសម្រាប់ការដាក់ឯកសារត្រៀមរបស់ដើមចោទ និងឯកសារតទល់ ឬការពារខ្លួន និងសេចក្តីថ្លែងការណ៍ចំពោះមធ្យោបាយតទល់ ឬកាពារខ្លួនរបស់ភាគីចុងចម្លើយ។ ប៉ុន្តែក្នុងច្បាប់ក៏មិនបានកំណត់ពេលវេលាច្បាស់លាស់សម្រាប់ការដាក់ឯកសារត្រៀមទេ ដោយទុកឲ្យចៅក្រមជាអ្នកមានឆន្ទានុសិទ្ធិកំណត់។

---

[28] មាត្រា ៤ និង មាត្រា ១៤ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គលឆ្នាំ ២០១០

[29] មាត្រា ៩១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦ និងមាត្រា ១៤នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គលឆ្នាំ ២០១០

[30] មាត្រា ១០១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

- **ដំណាក់កាលទី៣** នីតិវិធីត្រៀមសម្រាប់ត្រៀមទាញហេតុផលៈ គោលបំណង គឺឲ្យតុលាការរៀបចំសេចក្តីអះអាងរបស់ភាគី បំភ្លឺចំណុចវិវាទនៃរឿងក្តីដែលភាគីយល់ថា មិនយល់ស្រប ឬរៀបចំភស្តុតាងដែលទាក់ទងទៅនឹងចំណុចរឿងក្តី ដើម្បីអាចធ្វើការវិនិច្ឆ័យរឿងក្តី នៅក្នុងនីតិវិធីនៃការទាញហេតុផលឲ្យបានល្អិតល្អន់ [31] ។ នីតិវិធីសម្រាប់ត្រៀមទាញហេតុផល ខុសពីនីតិវិធីសម្រាប់ត្រៀមទាញហេតុផលដោយផ្ទាល់មាត់ពីព្រោះថានីតិវិធីសម្រាប់ត្រៀមការទាញហេតុផលមិនចាំបាច់ធ្វើនៅក្នុងសាលសវនាការទេ គឺអាចធ្វើនៅក្នុងបន្ទប់ធម្មតាណាមួយ ហើយតុលាការជាអ្នកកំណត់កាលបរិច្ឆេទសមរម្យដែលភាគីទាំងពីរអាចចូលរួមបាន ដើម្បីគោរពគោលការណ៍ចំពោះមុខតុលាការរបស់ភាគី ដែលនឹងបើកឲ្យភាគីចូលរួមទាំងសងខាង។ នៅក្នុងនីតិវិធីនេះតុលាការក៏អាចចេញដីកាសម្រេចដែលទាក់ទងនឹងការស្នើសុំពិនិត្យភស្តុតាង ដូចជា ដីកាសម្រេចបង្គាប់ឲ្យដាក់ឯកសារ ការស្នើសុំឲ្យផ្ញើឯកសារ ឬការប្រគល់កិច្ចការកោសលវិច័យ ដីកាសម្រេចយក ឬមិនយក ភស្តុតាងដែលភាគីស្នើសុំឲ្យពិនិត្យជាដើម។ តុលាការក៏អាចចេញដីកាសម្រេចផ្សេងទៀតដូចជា ការអនុញ្ញាតឲ្យ ឬមិនអនុញ្ញាតបន្ថែម ឬប្តូរកម្មវត្ថុនៃបណ្តឹង ការសម្រេចសេចក្តីស្តីអំពីការអនុញ្ញាតការចូលរួមអន្តរាគមន៍ឬមិនអនុញ្ញាតជាដើម។ ក្រោយពេលបានបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ភាគីមិនអាចដាក់មធ្យោបាយតទល់បាន ឬការពារខ្លួនថ្មីបានទៀតទេ។ ក្នុងករណីខ្លះតុលាការមានឆន្ទានុសិទ្ធិ និងធ្វើការស្រាវជ្រាវដោយខ្លួនឯង នៅពេលដែលការដាក់មធ្យោបាយថ្មីនោះមិនធ្វើឲ្យមានការយឺតយ៉ាវដល់នីតិវិធីនៃបណ្តឹង ឬករណីដែលភាគីបានធ្វើសេចក្តីបញ្ជាក់ពីដំបូងថា ខ្លួនមិនអាចដាក់មធ្យោបាយនោះ នៅមុនពេលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបានទេ។ សម្រាប់បណ្តឹងលែងលះ ភាគីដើមចោទនៃបណ្តឹងលែងលះគ្នា នៅតែអាចបន្ថែម ឬផ្លាស់ប្តូរនៃការទាមទារ ឬមូលហេតុនៃការទាមទារបាន បើទោះជាក្រោយពេលបានបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះហើយក៏ដោយ ចុងចម្លើយអាចប្តឹងតបបាន រហូតដល់ពេលចប់ការទាញហេតុផលផ្ទាល់មាត់នៃការជម្រះក្តីលើកទី១ ឬការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍។ នៅពេលដែល នីតិវិធីសម្រាប់ត្រៀមទាញហេតុផលចប់ តុលាការត្រូវកំណត់កាលបរិច្ឆេទ សម្រាប់ការទាញហេតុផលផ្ទាល់មាត់ ដោយត្រូវកោះហៅគូភាគីទាំងពីរមកចូលរួម[32]។

-**ដំណាក់កាលទី៤** ការទាញហេតុផលផ្ទាល់មាត់ៈ ដើម្បីចេញសាលក្រមលើបណ្តឹងលែងលះគ្នា តុលាការចាំបាច់ត្រូវឆ្លងកាត់នូវការទាញហេតុផលដោយផ្ទាល់មាត់។ ចំពោះរឿងក្តី ឬចំណុចណាដែលត្រូវ

[31] មាត្រា ១០៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

[32] មាត្រា ១១៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

សម្រេចដោយដីកាសម្រេចតុលាការត្រូវកំណត់ថា ត្រូវធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ឬមិនធ្វើ។ ក្នុងករណីដែលតុលាការសម្រេចមិនធ្វើការទាញហេតុផលផ្ទាល់មាត់ តុលាការអាចសាកសួរភាគីបាន[33]។ ការទាញហេតុដោយផ្ទាល់មាត់ត្រូវធ្វើឡើងនៅកាលបរិច្ឆេទដែលភាគីអាចមានវត្តមានបាន។ ការទាញហេតុផលដោយផ្ទាល់មាត់នៃបណ្តឹងទាក់ទងឋានៈបុគ្គលមិនត្រូវធ្វើជាសាធារណៈឡើយ[34]។ នៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ ភាគីត្រូវធ្វើសេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដើម្បីឲ្យភាគីអះអាងបន្ថែមទៀតអំពីអង្គហេតុនិងដាក់ភស្តុតាងមកទៀតបាន។ ក្រោយពីបានពិនិត្យភស្តុតាងនៅក្នុងកាលបរិច្ឆេទធ្វើការទាញហេតុផលដោយផ្ទាល់មាត់ហើយ បើយល់ថា ត្រូវការជាចាំបាច់ពិសេស តុលាការអាចធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលជាថ្មីម្តងទៀតបាន ដោយដីកាសម្រេច[35]។

- **ភស្តុតាង**

មុនពេលដែលតុលាការសម្រេចសេចក្តី តុលាការត្រូវស្វែងរកភស្តុតាងនានា ដើម្បីជាមូលដ្ឋានសម្រាប់ការសម្រេចសេចក្តី។ អង្គហេតុដែលភាគីសារភាពចំពោះមុខតុលាការ និងអង្គហេតុដែលតុលាការយល់ឃើញថាមានភាពជាក់ស្តែងពុំចាំបាច់ទទួលស្គាល់អង្គហេតុនោះដោយផ្អែកលើភស្តុតាង។ ការស្វែងរកភស្តុតាងមានដូចជា៖

- **ភស្តុតាងចេញពីការទាញហេតុផលផ្ទាល់មាត់**

ក្នុងដំណើរការនីតិវិធីការទាញហេតុផលផ្ទាល់មាត់ចៅក្រមអាចពិចារណាអំពីស្ថានភាពនៃការទាញហេតុផលដោយផ្ទាល់មាត់ និងការទទួលស្គាល់អង្គហេតុ ដោយពឹងផ្អែកលើភស្តុតាងបាន។

តុលាការក៏អាចពិនិត្យភស្តុតាង តាមការស្នើសុំរបស់ភាគី។ ប្រសិនបើតុលាការពុំអាចសម្រេចថាត្រូវទទួលស្គាល់ ឬមិនទទួលស្គាល់នូវការអះអាងអំពីអង្គហេតុ ដោយភស្តុតាងដែលគូភាគីបានស្នើសុំអោយពិនិត្យ ឬបើយល់ឃើញថាមានការចាំបាច់ផ្សេងទៀតនោះតុលាការអាចពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិបាន[36]។

- **ភស្តុតាងសាក្សី**

[33] មាត្រា ១១៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

[34] មាត្រា ១៦ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គលឆ្នាំ ២០១០

[35] មាត្រា ១១៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

[36] មាត្រា ១២៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

ដើម្បីតុលាការអាចប្រមូលភស្តុតាងគ្រប់គ្រាន់ និងគ្រប់ជ្រុងជ្រោយដោយចៅក្រមអាចសាកសួរជនណាមួយជាសាក្សីក៏បាន។ ក្នុងករណីដែលសាក្សីមិនព្រមចូលខ្លួន ដោយគ្មានមូលហេតុត្រឹមត្រូវ តុលាការអាចពិន័យជាប្រាក់។

តុលាការក៏អាចសាកសួរសាក្សីនៅខាងក្រៅតុលាការបានដែរ ហើយសាក្សីត្រូវធ្វើសម្បថមុននឹងនិយាយទៅតុលាការ។ ក្នុងករណីដែលសាក្សីធ្វើសម្បថរួចហើយ ហើយបានផ្តល់សក្ខីកម្មក្លែងក្លាយនឹងត្រូវផ្តន្ទាទោសនៅពេលតុលាការរកឃើញថាបានផ្តល់សក្ខីកម្មក្លែងក្លាយ[37]។

- **ភស្តុតាងភាគី**

តុលាការអាចធ្វើការសាកសួរភាគីបាន ហើយអាចឲ្យភាគីនោះធ្វើសម្បថមុននឹងនិយាយទៅកាន់តុលាការ ហើយប្រសិនបើភាគីដែលបានធ្វើសម្បថបានក្លែងបន្លំសេចក្តីថ្លែងការណ៍តុលាការអាចពិន័យជាប្រាក់។ ការពិន័យជាប្រាក់មិនលើសពី ២ លានរៀល។

នៅក្នុងការសាកសួរភាគី បើភាគីនោះមិនចូលខ្លួន ឬបដិសេធការធ្វើសម្បថ ឬផ្តល់ចម្លើយដោយគ្មានមូលហេតុត្រឹមត្រូវ នោះតុលាការអាចទទួលស្គាល់ថា សេចក្តីអះអាងអំពីចំណុចសាកសួររបស់ភាគីម្ខាងទៀត ជាការពិត[38]។ ករណីដែលតុលាការយល់ឃើញថាចាំបាច់តុលាការអាចធ្វើការសាកសួរ ស្របពេលគ្នាជាមួយភាគីម្ខាងទៀត និងជាមួយសាក្សីក្នុងពេលដំណាលគ្នាក៏បាន។

- **ភស្តុតាងកោសលវិច័យ**

ពេលដំណើរការនៃការស៊ើបអង្កេត តុលាការអាចបង្គាប់ឲ្យធ្វើកោសលវិច័យតាមពាក្យសុំរបស់ភាគីបាន។ ក្នុងការធ្វើកោសលវិច័យ តុលាការជាអ្នកចាត់តាំងអ្នកជំនាញសម្រាប់ធ្វើកោសលវិច័យ ដូចជាជនដែលមានចំណេះវិជ្ជា និងបទពិសោធន៍ចាំបាច់ក្នុងការធ្វើកោសលវិច័យ។ នៅមុនពេលដែលអ្នកធ្វើកោសលវិច័យចេញសេចក្តីសន្និដ្ឋាន ភាគីម្ខាងទៀតមានសិទ្ធិបដិសេធ ការធ្វើកោសលវិច័យបាន ប្រសិនបើភាគីមានភស្តុតាង ធ្វើឲ្យរារាំងដល់សច្ចភាពចេញកោសលវិច័យ[39]។

- **ភស្តុតាងឯកសារ**

---

[37] មាត្រា ១៣៧ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

[38] មាត្រា ១៤០ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

[39] មាត្រា ១៤៣ ,១៤៤,១៤៥ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

ការស្នើសុំពិនិត្យភស្តុតាងជាឯកសារ ត្រូវធ្វើឡើងដោយផ្តល់នូវឯកសារដែលភាគីមាន ឬដោយដាក់ពាក្យសុំទៅតុលាការឲ្យបង្គាប់ឲ្យម្ចាស់ឯកសារផ្តល់ឯកសារនោះមក។ ក្នុងករណីដែលយល់ឃើញថាចាំបាច់ តុលាការអាចឃាត់ទុកនូវឯកសារដែលបានផ្តល់មក ឬដែលបានផ្ញើមកបាន។ ម្ចាស់ឯកសារ ពុំអាចបដិសេធនូវការផ្តល់ឯកសារដែលបានស្នើសុំទៅតុលាការបានទេ។ ក្នុងករណីដែលភាគីជាម្ចាស់ឯកសារ មិនព្រមផ្តល់ឯកសារតាមការទាមទារទេ តុលាការអាចសន្និដ្ឋានថា សេចក្តីអះអាងរបស់ភាគីម្ខាងទៀតចំពោះឯកសារនោះជាការពិត ហើយចំពោះតតិយជនដែលជាម្ចាស់ឯកសារមិនព្រមផ្តល់ឯកសារតាមការទាមទាររបស់តុលាការ គឺតុលាការអាចពិន័យជាប្រាក់ចំនួនមិនលើសពី ២ លានរៀលដោយដីកាសម្រេច[40]។

ដូចនេះក្រោយពីការពិនិត្យភស្តុតាងនៅក្នុងកាលបរិច្ឆេទធ្វើការទាញហេតុផលផ្ទាល់មាត់ហើយ បើយល់ថា ត្រូវការជាចាំបាច់ពិសេស តុលាការអាចធ្វើនីតិវិធីត្រៀមការទាញហេតុផលម្តងទៀតបានដោយដីកាសម្រេច។

### ១.៣ ការសម្រេចសេចក្តី

ក្រោយពេលដែលតុលាការបានបញ្ចប់ការស៊ើបអង្កេតរួច ត្រូវធ្វើការវិនិច្ឆ័យដល់អង្គសេចក្តីដោយតុលាការត្រូវចេញសាលក្រម។ សាលក្រមគឺជាសេចក្តីសម្រេចដែលតុលាការធ្វើលិខិតសាលក្រមដែលមានលក្ខណៈគ្រប់គ្រាន់ដែលច្បាប់បានកំណត់[41]។ ផ្អែកលើការទាញហេតុផលដោយផ្ទាល់មាត់ តាមរយៈសាលក្រមនេះ តុលាការកំណត់ថា តើចំណងអាពាហ៍ពិពាហ៍ត្រូវរំលាយ ឬបន្ត?

#### ១.៣.១. ខ្លឹមសារនៃសាលក្រម

ការសម្រេចសេចក្តីរបស់តុលាការក្នុងរឿងក្តីរដ្ឋប្បវេណីទូទៅ មានលក្ខណៈខុសគ្នាពីការសម្រេចសេចក្តីរបស់តុលាការក្នុងរឿងក្តីនៃបណ្តឹងដែលទាក់ទងនឹងការលែងលះគ្នា។ ការសម្រេចសេចក្តីនៅក្នុងសាលក្រម ឬសាលដីកា របស់តុលាការក្នុងរឿងក្តីរដ្ឋប្បវេណីទូទៅ តុលាការត្រូវសម្រេចទៅតាមការទាមទាររបស់ភាគី តែតុលាការមិនអាចសម្រេចលើចំណុចដែលភាគីមិនបានទាមទារឡើយ [42] ។ តែនៅក្នុងករណីរឿងក្តីរដ្ឋប្បវេណីទាក់ទងនឹងអាពាហ៍ពិពាហ៍ ច្បាប់បានផ្តល់សិទ្ធិទៅឲ្យតុលាការសម្រេចលើចំណុចដែលភាគីមិនបានស្នើសុំដោយឆន្ទានុសិទ្ធិបាន ប្រសិនបើចៅក្រមយល់ឃើញថាចាំបាច់ និងមានប្រយោជន៍ដល់ភាគី[43]។ នៅក្នុងករណីពិសេសដែលបណ្តឹងស្តីពីទំនាក់ទំនងអាពាហ៍ពិពាហ៍ ប្រសិនបើតុលាការចេញសាលក្រម ឬសាលដីកា ដែល

[40] មាត្រា ១៥៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

[41] មាត្រា ១៧៩ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

[42] មាត្រា ១៨២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

[43] មាត្រា ២២ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គលឆ្នាំ ២០១០

ទទួលស្គាល់ការទាមទាររបស់ដើមចោទនៅក្នុងបណ្ដឹងទាមទារលុបចោលនូវចំណងអាពាហ៍ពិពាហ៍ ឬលែងលះគ្នា តុលាការត្រូវធ្វើការសម្រេចសេចក្ដីអំពីការកំណត់អ្នកមានអំណាចមេបាដោយឆន្ទានុសិទ្ធិ ហើយបើមានពាក្យសុំរបស់ភាគី ត្រូវធ្វើការសម្រេចសេចក្ដីអំពីការចាត់ចែងទាក់ទងនឹងការបីបាច់ថែរក្សាកូន ឬការចាត់ចែងទាក់ទងនឹងការបែងចែកទ្រព្យសម្បត្តិ។ សាលក្រមអាចសម្រេចដោះស្រាយផងដែរ លើបញ្ហាអាហារកិច្ច បញ្ហាបីបាច់រក្សាកូន បញ្ហាផ្គត់ផ្គង់កូន និងការបង្គាប់ភាគីឲ្យប្រគល់កូន ឬការផ្ដល់តាវកាលិកផ្សេងៗទៀត។ ចំពោះករណីយកិច្ចដែលភាគីណាមួយត្រូវទទួលបន្ទុកប្រាក់ប្រដាប់ក្តី តុលាការត្រូវកំណត់ដោយខ្លួនឯង ទោះបីភាគីមិនបានសុំក៏ដោយ។

### ១.៣.២ ការសម្រេចមិនឲ្យលែងលះ

ទោះមានមូលហេតុត្រឹមត្រូវតាមពាក្យបណ្ដឹង សម្រាប់ការសម្រេចសេចក្ដីឲ្យលែងលះគ្នាក៏ដោយ បើការសម្រេចឲ្យលែងលះនោះអាចបណ្ដាលឲ្យការទ្រទ្រង់ជីវភាពរបស់សហព័ទ្ធ ឬកូនជួបការលំបាកខ្លាំង ឬមានការឈឺចាប់ដែលមិនអាចទ្រាំបាន តុលាការអាចច្រានចោលការលែងលះនោះដោយឆន្ទានុសិទ្ធិ ដោយធ្វើការពិចារណាទៅលើស្ថានភាពទាំងនោះបាន។ ប្រសិនបើតុលាការយល់ឃើញថា ការទាមទារនោះផ្ទុយនឹងភាពសុចរិត ដោយជនដែលទាមទារឲ្យលែងលះគ្នានោះធ្វេសប្រហែសខ្លាំងក្នុងការសហប្រតិបត្តិ និងជួយសង្គ្រោះចំពោះសហព័ទ្ធ តុលាការអាចច្រានចោលការទាមទារលែងលះគ្នានោះដោយឆន្ទានុសិទ្ធិបាន[44]។

### ១.៣.៣. ការចូលជាស្ថាពររបស់សាលក្រម

សាលក្រមរបស់តុលាការមានអានុភាពបាន លុះត្រាតែសាលក្រមនោះត្រូវបានប្រកាសជាផ្លូវការ និងជាសាធារណៈដោយប្រធានក្រុមប្រឹក្សាជំនុំជំម្រះ ឬចៅក្រម ដែលជាអ្នកអានសេចក្ដីសម្រេចបញ្ចប់។ ការប្រកាសសាលក្រមអាចធ្វើបានទោះបីគ្មានវត្តមានរបស់គូភាគីនៅក្នុងសាលសវនាការក៏ដោយ[45]។

ជាទូទៅតុលាការត្រូវប្រកាសសាលក្រមនៅក្នុងរយៈពេល ១ ខែ ដោយគិតចាប់ពីថ្ងៃដែលបានបញ្ចប់ការទាញហេតុផលមាត់ ប៉ុន្តែចំពោះរឿងក្ដីដែលមានភាពស្មុគស្មាញខ្លាំងឬ មានកាលៈទេសៈផ្សេងទៀត តុលាការអាចទុករយៈពេលសម្រាប់ប្រកាសសាលក្រមយូរជាងនេះបាន [46] ។ លិខិតសាលក្រមត្រូវបញ្ជូនទៅឲ្យភាគីក្នុងអំឡុងពេល ២ សប្ដាហ៍ ដោយគិតចាប់ពីថ្ងៃដែលតុលាការបានប្រកាសសាលក្រមនោះ[47]។ សាលក្រមរបស់

[44] មាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[45] មាត្រា ១៨៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

[46] មាត្រា ១៨៧ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

[47] មាត្រា ១៩០ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

តុលាការ អាចក្លាយទៅជាសាលក្រមស្ថាពរបាន លុះត្រាតែកន្លងផុតអំឡុងពេលដែលច្បាប់អនុញ្ញាតឲ្យប្តឹងឧទ្ធរណ៍ ឬផុតរយៈពេលសម្រាប់ប្តឹងទាស់ហើយពុំមានភាគីណាមួយប្តឹងឧទ្ធរណ៍ ឬប្តឹងទាស់។ ក្នុងករណីដែលភាគីធ្វើបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ឬពាក្យបណ្តឹងទាស់ ចំពោះសាលក្រមដែលចូលជាស្ថាពរត្រូវបានផ្អាក ហើយនីតិវិធីរឿងក្តីលែងលះត្រូវដំណើរការបន្តទៀត។ ប្រសិនបើគ្មានការប្តឹងផ្តល់ទៀតទេ ហើយអំឡុងពេលដែលអនុញ្ញាតឲ្យប្តឹង ត្រូវបានផុតកាលកំណត់ នោះសាលក្រមនឹងចូលជាស្ថាពរ ពោលគឺមានអានុភាពនៃអាជ្ញាអស់ជំនុំត្រូវបានកើតឡើង[48]។ អាជ្ញាអស់ជំនុំ មានន័យថា នៅពេលដែលសាលក្រមចូលជាស្ថាពរហើយភាគីលែងលះមិនអាចលើកឡើងនូវទឡ្ហីករណ៍នានា មកសុំប្តឹងបន្តនីតិវិធីបានទៀតទេ ព្រោះតុលាការបានជំនុំជម្រះចប់សព្វគ្រប់ ហើយតុលាការក៏អស់ភារៈកិច្ចក្នុងការដោះស្រាយរឿងក្តីនោះទៀតដែរ គឺសាលក្រមស្ថាពរនោះត្រូវបានយកមកប្រើប្រាស់ជាផ្លូវការ និងដោយស្របច្បាប់។

## ១.៤ អានុភាពនៃការលែងលះដោយគ្មានការព្រមព្រៀង

### ១.៤.១ អានុភាពចំពោះទ្រព្យសម្បត្តិ

#### ក.ទ្រព្យសម្បត្តិអកម្ម

បំណុលផ្ទាល់ខ្លួន៖ ក្នុងច្បាប់បានចែងថាប្តីប្រពន្ធមានការទទួលខុសត្រូវដោយសាមគ្គីភាពចំពោះបំណុល ពេលស្ថិតក្នុងចំណងអាពាហ៍ពិពាហ៍ ឬពេលលែងលះក៏ដោយ តែក៏មានសកម្មភាពមួយចំនួនមិនបានចាត់ជាបំណុលរួមរបស់គ្រួសារឡើយដូចជា ការផឹកស្រា ការលេងល្បែងស៊ីសង ជំពាក់បំណុលគេ បើទោះបំណុលនោះមុន ឬក្រោយអាពាហ៍ពិពាហ៍ក៏ដោយ បំណុលនោះមិនចាត់ចូលជាបំណុលរួមគ្រួសារទេ វាគឺជាបំណុលផ្ទាល់ខ្លួនរបស់សហព័ទ្ធ។

បំណុលរួម៖ គឺជាបំណុលដែលកើតឡើងដោយផលប្រយោជន៍គ្រួសារ។ ចំពោះការបែងចែកទ្រព្យអកម្មចៅក្រមត្រូវធ្វើការបែងចែកបំណុលជាពីរដោយឲ្យសហព័ទ្ធក្លាយជាកូនបំណុល ហើយធ្វើការសងបំណុលរួមគ្នាដោយវាជាការទទួលខុសត្រូវដោយសាមគ្គីភាពរវាងប្តីប្រពន្ធចំពោះម្ចាស់បំណុល។

#### ខ.ទ្រព្យសម្បត្តិរបស់សហព័ទ្ធតាមកិច្ចសន្យា

ប្តីប្រពន្ធ នៅមុន ឬក្រោយពេលរៀបអាពាហ៍ពិពាហ៍អាចនាំគ្នាទៅចុះកិច្ចសន្យាទ្រព្យសម្បត្តិនៅក្រសួងយុត្តិធម៌ ដើម្បីងាយស្រួលសម្រាប់ប្តីប្រពន្ធពេលខាងមុខ។ នៅពេលលែងលះនឹងមានការបែងចែកទ្រព្យសម្បត្តិ

[48] មាត្រា ១៩៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

នាំឲ្យចៅក្រមមិនពិបាកឡើយក្នុងការសម្រេច ដោយអនុលោមតាមកិច្ចសន្យាប្តីប្រពន្ធ។ ប្រសិនបើប្តីប្រពន្ធនោះមិនបានធ្វើកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធតាមកិច្ចសន្យាទេ តុលាការអាចឲ្យភាគីប្តីប្រពន្ធពិភាក្សាគ្នាក្នុងការបែងចែកទ្រព្យសម្បត្តិបាន បើភាគីមិនអាចពិភាក្សាគ្នាបាន តុលាការនឹងធ្វើការបែងចែក ដោយកំណត់ទៅតាមច្បាប់។

**គ.ទ្រព្យសម្បត្តិរបស់សហព័ទ្ធកំណត់ដោយច្បាប់**

ច្បាប់បានបែងចែកទ្រព្យសម្បត្តិប្តីប្រពន្ធជា ២ប្រភេទគឺ ៖

- ទ្រព្យសម្បត្តិដោយឡែក
- ទ្រព្យសម្បត្តិរួម

ករណីដែលសហព័ទ្ធមិនបានសម្រេចការព្រមព្រៀងគ្នា ការបែងចែកទ្រព្យសម្បត្តិច្បាប់បានផ្តល់សិទ្ធិអំណាចដល់តុលាការ ដើម្បីសម្រេចបែងចែកទ្រព្យសម្បត្តិនោះ។

មាត្រា ៩៨០ នៃក្រមរដ្ឋប្បវេណី បានផ្តល់អំណាចដល់តុលាការដើម្បីសម្រេចបែងចែកទ្រព្យសម្បត្តិតាមវិធី ៣ យ៉ាងដូចតទៅៈ

ទី១ សហព័ទ្ធនីមួយៗត្រូវទទួលបាននូវទ្រព្យសម្បត្តិដោយឡែកៈ មានដូចជា

-ទ្រព្យសម្បត្តិដែលសហព័ទ្ធមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍

-ទ្រព្យសម្បត្តិដែលសហព័ទ្ធទទួលបាន ដោយប្រទានកម្ម សន្តតិកម្ម អច្ច័យទាន នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍

-ទ្រព្យសម្បត្តិជាតម្លៃតបដែលបានពីការចាត់ចែងទ្រព្យសម្បត្តិដោយឡែកសហព័ទ្ធ នៅពេលមានចំណងអាពាហ៍ពិពាហ៍។

ទី២ មានសិទ្ធិទទួលយកពាក់កណ្តាលនៃទ្រព្យសម្បត្តិរួមៈ សហព័ទ្ធនីមួយៗមានសិទ្ធិទទួលយក ១ ភាគ ២ នៃទ្រព្យសម្បត្តិរួមដែលសហព័ទ្ធរកស៊ីបានជាមួយគ្នា។

ទី៣ ការបែងចែកទ្រព្យសម្បត្តិរួមដោយករណីពិសេសៈ តុលាការក៏អាចបែងចែកទ្រព្យសម្បត្តិរួម ដោយពិចារណាទៅលើស្ថានភាពដូចជា ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗ ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗចំពោះលទ្ធកម្មនៃទ្រព្យសម្បត្តិ ការថែរក្សា ឬការបង្កើតទ្រព្យ ក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ កម្រិតជីវភាពរស់នៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ អាយុស្ថានភាពផ្លូវចិត្ត ផ្លូវកាយ វិជ្ជាជីវៈ ប្រាក់ចំណូល លទ្ធភាពធ្វើការងាររបស់ភាគី និងផលប្រយោជន៍របស់កូនជាដើម។

### ១.៤.២. អានុភាពលើភាតព្វកិច្ច

#### ក.ការបញ្ចប់កាតព្វកិច្ចរួមរស់នៅជាមួយគ្នា

ដើម្បីកសាងគ្រួសារមួយឲ្យមានសុភមង្គល សហព័ទ្ធទាំងសងខាងមានករណីកិច្ចស្រឡាញ់គ្នា គោរពគ្នា មើលថែគ្នាទៅវិញទៅមក ប៉ុន្តែដោយសារអានុភាពនៃការលែងលះកាតព្វកិច្ចរួមរស់ជីវភាពជាមួយគ្នា ការសហការគ្នា និងសង្គ្រោះគ្នាទៅវិញទៅមកត្រូវបានបញ្ចប់[49]។

#### ខ.កាតព្វកិច្ចសងជំងឺចិត្តអាចកើតមាន

ក្នុងករណីលែងលះ ភាគីគ្មានកំហុសហើយត្រូវបានភាគីម្ខាងទៀតបំពាន ភាគីដែលទទួលរងនូវការបំពានអាចទាមទារសំណងនៃការខូចខាតបាន។ សំណងនៃការខូចខាត ដោយផ្អែកលើអំពើនីត្យានុកូល ត្រូវទទួលស្គាល់ក្នុងករណីលែងលះ និងអាចទាមទារនៅក្នុងបណ្តឹងលែងលះបាន។

#### គ.កាតព្វកិច្ចបង់អាហារកិច្ច

ការទាមទារអាហារកិច្ចត្រូវទទួលស្គាល់ក្នុងករណី ភាគីគ្មានកំហុសដោយមានការខ្វះខាតនៅក្នុងជីវភពរស់នៅ អាចទាមទារអាហារកិច្ចពីភាគីម្ខាងទៀតបាន។

### ១.៤.៣. អានុភាពលើស្ថានភាពគ្រួសារ

#### ក.ការបញ្ចប់ទំនាក់ទំនងញាតិពន្ធ

ទំនាក់ទំនងញាតិពន្ធ គឺសំដៅទៅលើទំនាក់ទំនងរវាងញាតិសាច់ថ្លៃ ខាងប្តី ឬខាងប្រពន្ធនោះ។ នៅពេលដែលចំណងអាពាហ៍ពិពាហ៍មិនទាន់រលាយ ទំនាក់ទំនងញាតិនៅល្អ ការរាប់អានប្រាស្រ័យទាក់ទងគ្នាមានភាពស្និទ្ធស្នាលធម្មតា ប្រែជាបញ្ចប់ទំនាក់ទំនងញាតិនឹងគ្នាដោយសារតែអានុភាពនៃការលែងលះគ្នា។

#### ខ.ការបញ្ចប់ភាពជាសន្តតិជន

នៅក្នុងក្រមរដ្ឋប្បវេណី សហព័ទ្ធដែលស្ថិតនៅក្នុងចំណងអាពាហ៍ពិពាហ៍ បានទទួលស្គាល់ថា ជាសហព័ទ្ធរបស់មរតកជន ត្រូវក្លាយជាសន្តតិជនជានិច្ច[50]។ ប៉ុន្តែទាំងអស់នេះត្រូវបានបញ្ចប់ដោយអានុភាពនៃការលែងលះ។

[49] មាត្រា ៩៦៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[50] មាត្រា ១១៦១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

**គ. នាមត្រកូលអាចត្រូវបានបញ្ចប់**

ប្តី ឬប្រពន្ធ ដែលបានប្តូរនាមត្រកូលថ្មី ដោយអាពាហ៍ពិពាហ៍ អាចប្រើនាមត្រកូលដែលមាន នៅមុនពេលរៀបអាពាហ៍ពិពាហ៍វិញបាន ឬអាចប្រើនាមត្រកូលដែលបានប្រើនៅពេលលែងលះគ្នាក៏បាន។

**ឃ. អ្នកមានអំណាចមេបា**

ក្រោយពីការលែងលះ តុលាការនឹងធ្វើការសម្រេចពីអំណាចមេបាលើកូនឲ្យទៅភាគីណាម្ខាង អាចជាឪពុក ឬម្តាយ។ ការប្រគល់អំណាចមេបា គឺប្រគល់សិទ្ធិគ្រប់គ្រងការចិញ្ចឹមបីបាច់ ថែរក្សា អប់រំ ទៅភាគីណាមួយក្រោយពីលែងលះ។ ពេលលែងលះ ត្រូវកំណត់យកឪពុក ឬម្តាយណាម្ខាង ជាអ្នកមានអំណាចមេបា តាមការពិភាក្សារបស់ឪពុកម្តាយ ។ ក្នុងករណីដែលឪពុកម្តាយបានលែងលះមុនកំណើតរបស់កូន ម្តាយជាអ្នកមានអំណាចមេបាលើកូនដែលកើតមកនោះ តែក្រោយកំណើតរបស់កូន អាចកំណត់យកឪពុកជាអ្នកគ្មានអំណាចមេបា តាមការពិភាក្សារបស់ឪពុកម្តាយ។ ប្រសិនបើកូននោះអាចយល់ដឹង មានវ័យសមល្មម អាចជ្រើសរើសឪពុក ឬម្តាយជាអ្នកមានអំណាចមេបារបស់កូនដោយការពិភាក្សាគ្នា[51]។

**ង.អានុភាពនៃអត្តាធីនភាពនៅតែមាន**

ចំពោះអនីតិជនដែលបានរៀបអាពាហ៍ពិពាហ៍ហើយ ត្រូវទទួលបានអត្តាធីនភាពដោយមិនចាំបាច់មានការប្រកាសពីតុលាការទេ អនីតិជននោះត្រូវបានចាត់ទុកថាបានដល់នីតិភាព។ តែក្នុងករណីដែលប្តី ឬប្រពន្ធដែលជាអនីតិជនមានចំណងអាពាហ៍ពិពាហ៍ ក្នុងករណីមានការលែងលះអានុភាពនៃអត្តាធីនភាពនៅតែមានពុំបានបញ្ចប់តាមអានុភាពនៃការលែងលះនោះទេ។

## ផ្នែកទី២៖ នីតិវិធីនៃការលែងលះ ក្នុងករណីមានការព្រមព្រៀង

នៅក្នុងនីតិវិធីនៃការលែងលះដោយមានការព្រមព្រៀង ចំពោះភាគីទាំងពីរ គឺត្រូវតែមានឆន្ទៈ ក្នុងការលែងលះ។ សម្រាប់នីតិវិធីនៃការលែងលះដោយមានការព្រមព្រៀង គឺមានតែភាគីប្តីប្រពន្ធទេ ដែលជាអ្នកចាប់ផ្តើមដំណើរការ។ នីតិវិធីដំបូងតាមរយៈការដាក់ពាក្យសុំលែងលះទៅតុលាការ មិនមែនជារឿងក្តីដែលតុលាការអាចចាប់ផ្តើមនីតិវិធីបណ្តឹងដោយឆន្ទានុសិទ្ធិឡើយ មានន័យថា កម្មវត្ថុនៃការសម្រេច និងការចេញដីកា គឺភាគីជាអ្នកកំណត់នៅក្នុងពាក្យសុំ ហើយតុលាការអាចចាប់ផ្តើមជម្រះក្តីបានទាល់តែទទួលបានពាក្យសុំជាមុនសិន ដោយនៅក្នុងពាក្យសុំភាគីត្រូវមានកិច្ចព្រមព្រៀងលែងលះភ្ជាប់មកជាមួយផងដែរ។

[51] មាត្រា ១០៥១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

## ២.១ កិច្ចព្រមព្រៀងលែងលះ

ដើម្បីបញ្ជាក់ពីឆន្ទៈត្រូវគ្នា ភាគីទាំងសងខាងនៃចំណងអាពាហ៍ពិពាហ៍ត្រូវតែធ្វើកិច្ចព្រមព្រៀងលែងលះ។ កិច្ចព្រមព្រៀងលែងលះ គឺជាលិខិតមួយដែលគូភាគីទាំងពីរបានព្រមព្រៀងគ្នាធ្វើដោយឆន្ទៈ ដោយពុំមានការបង្ខិតបង្ខំពីភាគីណាម្ខាងឡើយ។ នៅក្នុងការព្រមព្រៀងលែងលះ គេអាចធ្វើបានតាមទម្រង់ពីរគឺ តាមទម្រង់ជាលាយលក្ខណ៍អក្សរ និងតាមទម្រង់ផ្ទាល់មាត់។

ទម្រង់ជាលាយលក្ខណ៍អក្សរ៖ ជាទូទៅកិច្ចព្រមព្រៀងនេះ ភាគច្រើនសរសេរនូវខ្លឹមសារចម្បង គឺឆន្ទៈនៃការព្រមព្រៀងលែងលះ និងជាយថាហេតុ ការបែងចែកសិទ្ធិអំណាចមេបាលើកូន បន្ទុកចំណាយដើម្បីចិញ្ចឹមថែរក្សាកូន ការចូលជួបប្រាស្រ័យទាក់ទងជាមួយកូន ការបែងចែកទ្រព្យសម្បត្តិរួម និងការនាំយកពាក្យសុំទៅដាក់នៅតុលាការមានសមត្ថកិច្ច ដើម្បីទទួលបានដីកាសម្រេចជាអាទិ៍។

ទម្រង់ដោយផ្ទាល់មាត់៖ ទម្រង់នេះភាគច្រើនគេប្រើប្រាស់ដោយប្រជាជនដែលមិនសូវយល់ដឹងពីច្បាប់ និងមិនមានលទ្ធភាពពឹងពាក់មេធាវី។ តាមរយៈទម្រង់នេះ នៅពេលប្ដីប្រពន្ធសម្រេចថាលែងលះគ្នា ពួកគាត់នាំគ្នាទៅតុលាការហើយថ្លែងការណ៍អំពីឆន្ទៈនៃការព្រមព្រៀងលែងលះរបស់ខ្លួន នៅចំពោះមុខក្រឡាបញ្ជីដែលទទួលពាក្យសុំនោះ តំណាលគ្នានឹងពាក្យសុំ។

តាមទ្រឹស្ដីពិតរបស់ច្បាប់ ឆន្ទៈនៃការព្រមព្រៀងរបស់ប្ដីប្រពន្ធគឺជារឿងដ៏សំខាន់បំផុតដែលចៅក្រមត្រូវការវែកញែក និងស្រាវជ្រាវដើម្បីទទួលស្គាល់ ថាតើការព្រមព្រៀងនោះបានការពារផលប្រយោជន៍រៀងៗខ្លួនរបស់ភាគីដោយយុត្តិធម៌ ឬនៅ? ពីព្រោះនៅក្នុងសង្គមខ្មែរនាបច្ចុប្បន្នអំពើហិង្សាក្នុងគ្រួសារតែងតែកើតឡើងជាញឹកញាប់។

## ២.២ ពាក្យសុំលែងលះ

នៅក្នុងពាក្យសុំលែងលះដោយការព្រមព្រៀងភាគីណាម្ខាង ដែលមានគោលបំណងចង់ដាក់ពាក្យសុំលែងលះ អាចដាក់ពាក្យទៅតុលាការ ប៉ុន្តែត្រូវបំពេញទម្រង់បែបបទនៃការដាក់ពាក្យសុំទៅតាមបញ្ញត្តិច្បាប់ ស្ដីពីនីតិវិធីរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង ដែលបានកំណត់។

### ២.២.១ ពាក្យសុំជាលាយលក្ខណ៍អក្សរ

ពាក្យសុំលែងលះអាចត្រូវធ្វើឡើងដោយអ្នកដាក់ពាក្យសុំ ឬតាមរយៈអ្នកតំណាងដោយអាណត្តិរបស់ខ្លួនក៏បាន។ មួយវិញទៀត អ្នកដាក់ពាក្យសុំ ឬអ្នកតំណាងដោយអាណត្តិ ត្រូវរៀបចំលិខិតពាក្យសុំមុននឹងដាក់ទៅតុលាការ ត្រូវសរសេរបញ្ជាក់នូវចំណុចដូចខាងក្រោម ៖

-ឈ្មោះ និង អាសយដ្ឋាន របស់អ្នកដាក់ពាក្យសុំ៖ ប្តី ឬប្រពន្ធដែលបានយកពាក្យមកដាក់ត្រូវសរសេរ ឈ្មោះ ភេទ អាយុ សញ្ជាតិ និង សរសេរអាសយដ្ឋាន (ផ្ទះលេខ…ផ្លូវ…ក្រុម……ភូមិ…ឃុំ/សង្កាត់…ក្រុង/ស្រុក/ខណ្ឌ……ខេត្ត/រាជធានី………) នៅក្នុងពាក្យសុំ។ ប្រសិនបើមានអ្នកតំណាងដោយអាណត្តិដែលច្បាប់បានកំណត់ត្រូវសរសេរឈ្មោះនិងអាសយដ្ឋានរបស់អ្នកតំណាងដោយអាណត្តិនោះនៅក្នុងពាក្យសុំផងដែរ។

-ខ្លឹមសារនៃដីកាសម្រេចដែលអ្នកដាក់ពាក្យសុំទាមទារ៖ ជាការសរសេរនូវអ្វីដែលអ្នកដាក់ពាក្យសុំទាមទារ ហើយនឹងបញ្ជាក់ពីទំហំនៃរឿងក្តីដែលត្រូវឲ្យតុលាការលើកយកមកវិនិច្ឆ័យ និងសម្រេចសេចក្តីផងដែរ។ សម្រាប់ខ្លឹមសារទាក់ទងនឹងការសរសេរពាក្យសុំលែងលះដោយការព្រមព្រៀងចំណុចនេះ ត្រូវសរសេរឲ្យបានជាក់លាក់ថាស្នើឲ្យតុលាការចេញដីកាសម្រេចតាមពាក្យសុំ ដែលអ្នកដាក់ពាក្យសុំលែងលះជាមួយភាគីម្ខាងទៀត និងជាការទាមទារផ្សេងៗ ទៀតដូចជា ការបែកចែកសិទ្ធិអំណាចមេបាលើកូន ការចូលជួបប្រាស្រ័យទាក់ទងជាមួយកូនរបស់អ្នក ដែលមិនមានសិទ្ធិអំណាចមេបា ការទទួលបន្ទុកសោហ៊ុយចំណាយដើម្បីចិញ្ចឹមបីបាច់ថែរក្សាកូន ឬការបែងចែកទ្រព្យសម្បត្តិ (ការទាមទារបន្ទាប់បន្សំ) ជាដើម។

-អង្គហេតុជាមូលហេតុនៃការទាមទារ៖ នៅក្នុងរឿងក្តីលែងលះដោយការព្រមព្រៀងមូលដ្ឋានគតិយុត្តនៃការទាមទារ ដើម្បីលែងលះបាន គឺអង្គហេតុនៃការកើតឡើងនៃចំណងអាពាហ៍ពិពាហ៍ដែលបានបញ្ជាក់តាមសំបុត្រអាពាហ៍ពិពាហ៍ និងអង្គហេតុនៃការសម្តែងឆន្ទៈនៃការព្រមព្រៀងលែងលះគ្នា ដែលបញ្ជាក់ដោយកិច្ចព្រមព្រៀង ឬការអះអាងរបស់ភាគី។ ម្យ៉ាងទៀត ការចាត់ចែងកូន ក៏ជាអង្គហេតុដែលអាចទាមទារឲ្យតុលាការសម្រេចចាត់ចែងចំពោះកូន ។ លើសពីនេះទៅទៀត គឺជាអង្គហេតុដែលអាចទាមទារឲ្យមានការចាត់ចែងទ្រព្យសម្បត្តិ សំដៅលើអង្គហេតុដែលបញ្ជាក់ពីការមានទ្រព្យសម្បត្តិរួមគ្នា (ទ្រព្យសកម្ម និង ទ្រព្យអកម្ម) ដែលអង្គហេតុបញ្ជាក់ដោយឯកសារនានា ដូចជា ប័ណ្ណសម្គាល់សិទ្ធិម្ចាស់អចលនវត្ថុ ឬលិខិតសម្គាល់ម្ចាស់យានយន្តជាអាទិ៍។

### ២.២.២ ពាក្យសុំដោយផ្ទាល់មាត់

ក្នុងករណីដែលភាគីណាម្ខាងនៃអ្នកដាក់ពាក្យសុំ ដែលមានកិច្ចការចាំបាច់ណាមួយ ដែលមិនបានបំពេញទៅតាមលក្ខខណ្ឌទម្រង់ខាងលើ ដូចនេះពួកគាត់អាចធ្វើការដាក់ពាក្យសុំដោយផ្ទាល់មាត់ ដោយគ្រាន់តែអ្នកដាក់ពាក្យសុំត្រូវធ្វើតាមសេចក្តីថ្លែងការណ៍នូវចំណុច (១.២.១) ដែលបានរៀបរាប់ខាងលើនេះ នៅចំពោះក្រឡាបញ្ជីដែលទទួលពាក្យសុំ ហើយក្រឡាបញ្ជី ត្រូវធ្វើការកត់ត្រាទុកនៅក្នុងកំណត់ហេតុ។ កំណត់ហេតុនោះត្រូវចាត់ទុកជាលិខិតនៃពាក្យសុំ។ ពេលដាក់ពាក្យសុំ បើអ្នកដាក់ពាក្យសុំមានភស្តុតាង ជាឯកសារដូចជា

សំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ សំបុត្របញ្ជាក់កំណើតកូន ឬឯកសារនានាដែលបញ្ជាក់ពីទ្រព្យសម្បត្តិជាដើម គាត់ត្រូវដាក់ជូនតុលាការនូវឯកសារច្បាប់ដើម ឬឯកសារដែលមានសេចក្ដីបញ្ជាក់ដើម្បីឲ្យតុលាការងាយស្រួលក្នុងការពិនិត្យ និងឆាប់ទទួលស្គាល់អង្គហេតុ។

## ២.៣. សមត្ថកិច្ចដោះស្រាយ

### ២.៣.១ ក្រុមប្រឹក្សាឃុំ-សង្កាត់

ការដាក់ពាក្យសុំលែងលះទៅក្រុមប្រឹក្សាឃុំ-សង្កាត់ ជាជម្រើសរបស់គូភាគី ពោលគឺសហព័ទ្ធអាចដាក់ពាក្យសុំទៅតុលាការមានសមត្ថកិច្ចដោយផ្ទាល់ក៏បាន។ ប្រសិនបើភាគីណាម្ខាងបានសម្រេចដាក់ពាក្យសុំទៅក្រុមប្រឹក្សាឃុំ-សង្កាត់នាលំនៅឋានប្ដី ឬប្រពន្ធ ដូច្នេះក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវមានសមត្ថកិច្ចបឋមគឺ ជាអ្នកផ្សះផ្សាគូភាគីជាមុនសិន។ ក្នុងដំណាក់កាលនេះ ក្រុមប្រឹក្សាឃុំ-សង្កាត់ពុំមានសមត្ថកិច្ច ក្នុងការសម្រេចឲ្យគូភាគី លែងលះគ្នា ការបែងចែកទ្រព្យសម្បត្តិ កំណត់អ្នកមានអំណាចមេបាលើកូន និងការបង់អាហារកាតព្វកិច្ចឡើយ។ គោលបំណងនៃការផ្សះផ្សាគឺ ដើម្បីឲ្យបុគ្គលទាំងពីរត្រូវគ្នា ឬសះជាគ្នាវិញ ដើម្បីបន្តការរស់នៅក្នុងជីវភាពជាប្ដីប្រពន្ធសារជាថ្មី។ ដូចនេះក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវតែខិតខំធ្វើយ៉ាងណាបញ្ចុះបញ្ចូលគូភាគីឲ្យសះជាក្នុងអំឡុងពេល ១៥ ថ្ងៃ បន្ទាប់ពីបានទទួលពាក្យសុំនោះ[52]។ នៅពេលដែលគូភាគីត្រូវគ្នាវិញហើយ ក្រោយពីមានការផ្សះផ្សារបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ ក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវធ្វើកំណត់ហេតុអំពីអ្វីដែលគូភាគីបានសះជានឹងគ្នា និងធ្វើលិខិតកិច្ចសន្យាឲ្យគូភាគីទាំងពីរ ទទួលយកពីការផ្សះផ្សានេះ។ ប៉ុន្តែប្រសិនបើ ការខិតខំផ្សះផ្សារបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ពុំសម្រេចទេ ហើយគូភាគីនៅតែទទូចចង់ធ្វើការលែងលះ និងគ្មានសង្ឃឹមថាអាចសះជាគ្នាទេ ដូច្នេះក្រុមប្រឹក្សាឃុំ-សង្កាត់មានតែបញ្ជូនពាក្យសុំទៅតុលាការ ដើម្បីឲ្យតុលាការធ្វើចំណាត់ការបន្ត។

### ២.៣.២. សាលាដំបូងរាជធានី-ខេត្ត

បន្ទាប់ពីក្រុមប្រឹក្សាឃុំ-សង្កាត់ធ្វើការផ្សះផ្សាមិនបានសម្រេច ហើយពាក្យសុំត្រូវបញ្ជូនទៅតុលាការនៃលំនៅឋានរបស់ប្ដី ឬប្រពន្ធ ដូច្នេះតុលាការនឹងបន្តចំណាត់ការនេះ ព្រោះមានតែតុលាការទេ ដែលមានសមត្ថកិច្ចសម្រេចឲ្យគូភាគីលែងលះគ្នា ឬមិនអាចលែងលះគ្នាបានដោយការចេញដីកាសម្រេច។ មុននឹងឈានដល់ដំណើរការនីតិវិធីជំនុំជម្រះដោយចៅក្រម ពាក្យសុំត្រូវឆ្លងកាត់ការពិនិត្យជាមុនសិន។

-ការពិនិត្យពាក្យសុំ៖ នៅពេលដែលពាក្យសុំបានដាក់ជូនទៅតុលាការ អ្នកដែលមានសមត្ថកិច្ចទទួលពាក្យសុំ គឺមន្ត្រីរដ្ឋបាល ដែលទទួលបន្ទុកនៅការិយាល័យកិច្ចការរដ្ឋបាល និងបុគ្គលិកប្រចាំនៅតុលាការ។

[52] មាត្រា ៩៨២ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

បន្ទាប់មកពាក្យសុំត្រូវបញ្ជូនទៅក្រឡាបញ្ជី ហើយក្រឡាបញ្ជីត្រូវពិនិត្យនិងចុះលេខលើសំណុំរឿងដែលទទួលបាននោះ ប្រសិនបើពិនិត្យឃើញថាពាក្យសុំមិនត្រឹមត្រូវតាមទម្រង់ដែលច្បាប់បានកំណត់ទេនោះ ត្រូវរាយការណ៍ជូនចៅក្រមដើម្បីឲ្យចៅក្រមសម្រេច ថាត្រូវបង្គាប់ឲ្យកែតម្រូវ ឬលើកពាក្យសុំចោល។ ផ្ទុយមកវិញបើពិនិត្យឃើញថាពាក្យសុំត្រឹមត្រូវហើយ ក្រឡាបញ្ជីត្រូវបញ្ជូនពាក្យសុំទៅចៅក្រមដើម្បីសម្រេចបើកការជំនុំជម្រះ។ នៅក្នុងការដាក់ពាក្យ អ្នកដាក់ពាក្យសុំត្រូវបង់ពន្ធលើពាក្យសុំចំនួន ៥.០០០ (ប្រាំពាន់) រៀល[53] ឯប្រាក់ប្រដាប់ក្តីក្រៅពីពន្ធ គឺជាបន្ទុករបស់អ្នកដាក់ពាក្យសុំ[54]។

-ការកោះហៅគូភាគី៖ ក្រោយពីពិនិត្យពាក្យសុំឃើញថាត្រឹមត្រូវអស់ហើយតុលាការនឹងធ្វើការកំណត់កាលបរិច្ឆេទកោះហៅគូភាគីឲ្យចូលមកតុលាការ ដើម្បីដំណើរការនីតិវិធីរឿងក្តីលែងលះ ដោយភាគីមានករណីយកិច្ចចូលមកបង្ហាញខ្លួនក្នុងតុលាការតាមដីកាកោះហៅតាមកាលបរិច្ឆេទដែលកំណត់។ ប្រសិនបើភាគីមិនព្រមចូលខ្លួនដោយគ្មានមូលហេតុត្រឹមត្រូវទេ តុលាការអាចពិន័យជាប្រាក់ចំនួនមិនលើសពី មួយលាន រៀលបាន[55]។ ការកោះហៅ គឺដើម្បីឲ្យអ្នកដាក់ពាក្យសុំ ឬភាគីម្ខាងទៀត អះអាងជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ ឬដើម្បីប្រមូលព័ត៌មានអំពីអត្ថិភាព ឬនត្ថិភាពនៃអង្គហេតុពីអ្នកដាក់ពាក្យសុំ ភាគីម្ខាងទៀត ឬជនផ្សេងទៀត ហើយតុលាការក៏អាចកោះហៅបានបើយល់ឃើញថាចាំបាច់ និងដោយកំណត់កាលបរិច្ឆេទ។ នៅកាលបរិច្ឆេទឲ្យអ្នកដាក់ពាក្យសុំ ឬភាគីអះអាង សាមីខ្លួនអាចពឹងអ្នកតំណាងអាណត្តិរបស់ខ្លួនបង្ហាញជំនួសបានដោយពុំចាំបាច់បង្ហាញខ្លួនចំពោះមុខតុលាការផ្ទាល់ក៏បាន ប៉ុន្តែចំពោះកាលបរិច្ឆេទប្រមូលព័ត៌មានអំពីអត្ថិភាព ឬ នត្ថិភាពនៃអង្គហេតុពីអ្នកដាក់ពាក្យសុំ ភាគីម្ខាងទៀត ឬជនផ្សេងទៀតដែលតុលាការយល់ឃើញថាចាំបាច់ឲ្យសាមីដែលកោះហៅ បង្ហាញខ្លួនមកតុលាការ និងពន្យល់តុលាការពីកាលៈទេសៈដោយផ្ទាល់ ដើម្បីឲ្យតុលាការក្តោបអង្គហេតុពិតនៃរឿងក្តី ។

-ការផ្សះផ្សានៅតុលាការ ៖នៅពេលដែលភាគីបង្ហាញខ្លួនតាមការកោះហៅរបស់ចៅក្រម ហើយបានប្រមូលព័ត៌មានអំពីអត្ថិភាព ឬ នត្ថិភាពនៃអង្គហេតុពីអ្នកដាក់ពាក្យសុំ ភាគីម្ខាងទៀត ឬជនផ្សេងទៀតរួចហើយចៅក្រមដែលទទួលបន្ទុកលើសំណុំរឿងនោះ នឹងចាប់ផ្តើមដំណើរការរឿងក្តីតាមពាក្យសុំ របស់អ្នកដាក់ពាក្យសុំ ភាគីម្ខាងទៀត ឬជនផ្សេងទៀត។ ក្នុងដំណើរនៃនីតិវិធី ទោះបីរឿងក្តីនៃការលែងលះដោយការព្រមព្រៀង ដែលជា

[53] មាត្រា ២២ កថាខណ្ឌ១ នៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងឆ្នាំ ២០១០

[54] មាត្រា ២២ កថាខណ្ឌ៣ នៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងឆ្នាំ ២០១០

[55] មាត្រា ២៩ ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែននៃច្បាប់ជាបណ្តឹងឆ្នាំ ២០១០

ការសម្តែងឆន្ទៈរបស់គូភាគីក៏ដោយ ក៏តុលាការព្យាយាមធ្វើការផ្សះផ្សាភាគីឲ្យត្រូវគ្នាវិញប្រសិនបើចៅក្រមយល់ឃើញថាការលែងលះនោះអាចបង្កផលប៉ះពាល់ខ្លាំងដល់កូន។ ការផ្សះផ្សានេះ គឺដើម្បីឲ្យភាគីសះជាគ្នាវិញដោយលះបង់ការទាមទារ ឬទទួលស្គាល់ការទាមទារទេ តែគឺដើម្បីឲ្យភាគីដកពាក្យសុំលែងលះទៅវិញ ហើយរួមរស់នៅជាមួយគ្នាជាប្តីប្រពន្ធវិញ។ ប៉ុន្តែប្រសិនបើការផ្សះផ្សាម្តងហើយម្តងទៀតក្នុងដំណាក់កាលនីមួយៗនៅតែមិនបានសម្រេចទេនោះ ចៅក្រមនឹងបន្តសម្រេចសេចក្តីតាមឆន្ទៈរបស់គូភាគីនៃអ្នកដាក់ពាក្យសុំ ឬភាគីម្ខាងទៀត ឬជនផ្សេងទៀតនោះ។

-ការទាញហេតុផលដោយផ្ទាល់មាត់ និងការសាកសួរដោយឆន្ទានុសិទ្ធិ ៖ ដំណើរនៃនីតិវិធីនៃរឿងក្តីលែងលះដោយមានការព្រមព្រៀង តុលាការអាចធ្វើនីតិវិធីទាញហេតុផលផ្ទាល់មាត់ ឬមិនធ្វើបានដោយឆន្ទានុសិទ្ធិតាមការយល់ឃើញថាចាំបាច់ ឬមិនចាំបាច់។ ជាគោលការណ៍ការធ្វើនីតិវិធីទាញហេតុផលមាត់ត្រូវធ្វើនៅសវនាការ ចំណែកឯនីតិវិធីនៃការសាកសួរអាចធ្វើឡើងក្នុងបន្ទប់ផ្ទាល់ខ្លួនរបស់ចៅក្រម។ នីតិវិធីនៃការសាកសួរក្រៅពីការផ្តល់វេទិកាឲ្យភាគីបញ្ជាក់ឲ្យកាន់តែច្បាស់ អំពីឆន្ទៈព្រមព្រៀងរបស់ខ្លួនលើការទាមទារ ហើយតុលាការអាចធ្វើការស្រាវជ្រាវដោយឆន្ទានុសិទ្ធិ ឬពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិទៀតផង[56]។ នៅក្នុងការដឹកនាំនីតិវិធីតុលាការអាចលើកយកអង្គហេតុដែលភាគីមិនបានអះអាងមកធ្វើជាមូលដ្ឋាននៃដីកាសម្រេចបាន។

**២.៤. ការចេញដីកាសម្រេច**

ក្នុងការលែងលះដោយការព្រមព្រៀង ការសម្រេចសេចក្តីត្រូវចេញដីកាសម្រេចដើម្បីចេញដីកាសម្រេចតុលាការពុំចាំបាច់ឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់ឡើយ ព្រោះរឿងក្តីបែបនេះជារឿងក្តីមិនស្មុគស្មាញ គ្មានចំណុចវិវាទ ដោយសារភាគីបានព្រមព្រៀង ហើយការលែងលះ វាជាការសម្ងាត់របស់ភាគី ដូចនេះដើម្បីចេញដីកាសម្រេចឲ្យលែងលះតាមការព្រមព្រៀងមិនចាំបាច់ទាញហេតុផលជាសាធារណៈឡើយ។ ដីកាសម្រេចឲ្យលែងលះតាមការព្រមព្រៀង ជារឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ជាគោលការណ៍ធ្វើជាលាយលក្ខណ៍អក្សរ ត្រូវសរសេរសំអាងហេតុ និងសេចក្តីសម្រេចបញ្ចប់ហើយចៅក្រមត្រូវចុះហត្ថលេខាលើសេចក្តីសម្រេចនោះ[57]។

ក្នុងការសេចក្តីសម្រេច ចៅក្រមត្រូវយោងទៅលើមូលដ្ឋានជាច្រើនក្នុងការសម្រេច ចំណុចដំបូងចៅក្រមត្រូវពិចារណាទៅលើស្ថានភាពគតិយុត្តនៃទំនាក់ទំនងប្តីប្រពន្ធនៃការលែងលះ ថាតើចំណង

[56] មាត្រា ២៧ នៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងឆ្នាំ ២០១០

[57] មាត្រា ៣៥ នៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងឆ្នាំ ២០១០

អាពាហ៍ពិពាហ៍របស់គាត់ត្រឹមត្រូវស្របតាមច្បាប់ មានការទទួលស្គាល់ដោយច្បាប់ ឬអត់។ បន្ទាប់មកចៅក្រមពិចារណាលើឆន្ទៈពិតក្នុងការលែងលះ ប្រសិនបើចៅក្រមស្វែងរកឃើញថា ភាគីណាម្ខាងមិនមានឆន្ទៈព្រមព្រៀងពិតប្រាកដក្នុងការលែងលះទេ ចៅក្រមនឹងចេញដីកាសម្រេចលើកពាក្យសុំចោល ដើម្បីបញ្ចប់នីតិវិធីលែងលះ[58]។ ចៅក្រមក៏ធ្វើការពិចារណាទៅលើចំណុចនៃការទាមទារចម្បងរបស់ភាគីគឺការលែងលះ ព្រមទាំងចំណុចបន្ទាប់បន្សំផ្សេងទៀតដូចជា ការបែងចែកអំណាចមេបាលើកូន ការចូលជួបប្រាស្រ័យទាក់ទងជាមួយកូនរបស់អ្នកមិនមានសិទ្ធិអំណាចមេបា ការទទួលបន្ទុកសោហ៊ុយចំណាយដើម្បីចិញ្ចឹមបីបាច់ថែរក្សាកូន ឬការបែងចែកទ្រព្យសម្បត្តិ បំណុលជាដើម។

ដីកាសម្រេចលើពាក្យសុំលែងលះដោយព្រមព្រៀង ជាដីកាសម្រេចលើអង្គសេចក្តីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងដែលត្រូវធ្វើការជូនដំណឹងតាមរយៈការបញ្ជូន ឬការផ្ញើជូនឯកសារចម្លងយថាភូតនៃដីកាសម្រេច ទៅភាគីនៃការលែងលះដែលសាមីខ្លួនក្នុងរឿងលែងលះនេះតែម្តង[59]។ ការជូនដំណឹង មិនចាំបាច់ត្រូវធ្វើដោយក្រឡាបញ្ជីជាអ្នកបញ្ជូនដោយផ្ទាល់ទេ គឺអាចធ្វើឡើងតាមរយៈការផ្ញើតាមប្រៃសណីយ៍ក៏បាន។ ដីកាសម្រេចលើពាក្យសុំលែងលះតាមការព្រមព្រៀងក៏ដូចជា ដីកាសម្រេចលើអង្គសេចក្តីដែលមិនមែនជាបណ្តឹងមានលក្ខណៈខុសគ្នានឹងដីកាសម្រេចនៅក្នុងបណ្តឹងរដ្ឋប្បវេណីនៅត្រង់ថា ដីកាសម្រេចលើអង្គសេចក្តីនៃរឿងក្តីដែលមិនមែនជាបណ្តឹងមានអានុភាពចូលជាស្ថាពរ មិនមែនដោយការជូនដំណឹងទេ គឺថាដីកាសម្រេចលើពាក្យសុំលែងលះតាមការព្រមព្រៀង ក៏ដូចជាដីកាសម្រេចលើអង្គសេចក្តីនៃរឿងក្តីដែលមិនមែនជាបណ្តឹង ត្រូវបានចូលជាស្ថាពរមានអានុភាពអនុវត្តនៅពេលផុតរយៈពេលប្តឹងជំទាស់មានរយៈពេល ០២ សប្តាហ៍ គិតចាប់ពីបានទទួលការជូនដំណឹងអំពីដីកាសម្រេចនោះ[60]។

## ២.៥. អានុភាពនៃការលែងលះដោយការព្រមព្រៀង

### ២.៥.១ អានុភាពលើទ្រព្យសម្បត្តិ និងភាតព្វកិច្ច

#### ក. អានុភាពលើទ្រព្យសម្បត្តិ

នៅក្នុងករណីដែលប្តីប្រពន្ធលែងលះគ្នា ត្រូវបែងចែកទ្រព្យសម្បត្តិដោយយុត្តិធម៌ផ្អែកតាមការពិភាក្សារបស់ភាគីទាំងសងខាង [61] ហើយការលែងលះដោយការព្រមព្រៀង គឺគូភាគីតែងតែធ្វើការពិភាក្សាក្នុង

[58] មាត្រា ៣៩ នៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងឆ្នាំ ២០១០

[59] មាត្រា ៣៦ នៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងឆ្នាំ ២០១០

[60] មាត្រា៤០ នៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងឆ្នាំ ២០១០

[61] មាត្រា ៩៨០ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

ការបែងចែកទ្រព្យសម្បត្តិរួមដោយមាន ទាំងទ្រព្យសកម្ម និងទ្រព្យអកម្ម រីឯទ្រព្យដោយឡែកសហព័ទ្ធសហព័ទ្ធ មានសិទ្ធិទទួលយករៀងៗខ្លួន។

ខ. អានុភាពលើកាតព្វកិច្ច

-ការបញ្ចប់កាតព្វកិច្ចដែលទាមទារដោយច្បាប់៖ ការលែងលះបានធ្វើឲ្យអ្វីៗជាច្រើនត្រូវបញ្ចប់ កាតព្វកិច្ចរួមរស់នៅជាមួយគ្នា សហការ ជួយសង្គ្រោះគ្នាទៅវិញទៅមក ប្ដីប្រពន្ធដែលមានករណីយកិច្ច ស្រឡាញ់គ្នាទៅវិញទៅមក គោរពគ្នា ថែរក្សាគ្នា ដើម្បីឈានទៅការកសាងគ្រួសារមួយដែលមានសុភមង្គល ត្រូវ បានបញ្ចប់។

-កាតព្វកិច្ចបង់សោហ៊ុយចាំបាច់ចិញ្ចឹមកូន៖ នៅពេលដែលប្ដីប្រពន្ធបានលែងលះគ្នា ហើយមានកូន ក្រោយការលែងលះ គឺត្រូវមានភាគីម្ខាងជាអ្នកមានសិទ្ធិអំណាចមេបា ហៅថា អំណាចមេបានទោល។ ក្នុង ករណីដែលតុលាការកំណត់ម្ដាយជាអ្នកមានអំណាចមេបា ម្ដាយត្រូវចាត់ទុកថាអ្នកមានសិទ្ធិលើសោហ៊ុយ ចាំបាច់ដើម្បីចិញ្ចឹមកូន រីឯឪពុកត្រូវចាត់ទុកថា ជាអ្នកមានករណីយកិច្ចបង់សោហ៊ុយចាំបាច់ចិញ្ចឹមកូន។

**២.៥.២ អានុភាពលើស្ថានភាពគ្រួសារ**

+ការកំណត់អ្នកមានអំណាចមេបា៖ នៅពេលលែងលះ ត្រូវកំណត់យកឪពុកឬម្ដាយណាម្ខាង ជាអ្នក មានអំណាចមេបា តាមការពិភាក្សារបស់ឪពុកម្ដាយ ។ ក្នុងករណីដែលឪពុកម្ដាយបានលែងលះមុនកំណើត របស់កូន ម្ដាយជាអ្នកមានអំណាចមេបាលើកូនដែលកើតមកនោះ តែក្រោយកំណើតរបស់កូន អាចកំណត់យក ឪពុកជាអ្នកមានអំណាចមេបា តាមការពិភាក្សារបស់ឪពុកម្ដាយ[62]។ ក្នុងការលែងលះដោយការព្រមព្រៀង វា ងាយស្រួលក្នុងការសម្រេចដោយសារ គូភាគីតែងតែកំណត់ការជ្រើសរើសរួចជាស្រេច ប៉ុន្តែបើសហសព័ទ្ធពុំមាន ការយល់ព្រមតាមការពិភាក្សាទេ តុលាការនឹងធ្វើការពិចារណាពីផលប្រយោជន៍កូន។

+ការបញ្ចប់ទំនាក់ទំនងញាតិពន្ធ៖ ពេលដែលមានការរំលាយចំណងអាព៉ាពិពាហ៍ដោយការលែងលះ នោះទំនាក់នងញាតិពន្ធក៏ត្រូវបានបញ្ចប់រវាងសហព័ទ្ធទាំងសងខាងផងដែរ[63]។ ចំពោះករណីសហព័ទ្ធណាម្ខាង បានទទួលមរណភាព ហើយសហព័ទ្ធដែលនៅរស់ បានរៀបអាពាហ៍ពិពាហ៍ថ្មីទៀត ឬបានបង្ហាញឆន្ទៈបញ្ចប់ ទំនាក់ទំនងញាតិពន្ធ។

[62] មាត្រា ១០៣៧ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[63] មាត្រា ៩៤១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

+ការបញ្ចប់ឬការកែប្រែនូវការប្រើនាមត្រកូលរបស់សហព័ទ្ធ ៖ អានុភាពនៃការរំលាយចំណង អាពាហ៍ពិពាហ៍ដោយការលែងលះក៏ធ្វើឲ្យមានការបញ្ចប់ ឬប្រែប្រួលនូវការប្រើនាមត្រកូលរបស់សហព័ទ្ធម្ខាងទៀតផងដែរ។ ប្ដី ឬប្រពន្ធ ដែលបានប្ដូរនាមត្រកូលថ្មី ដោយអាពាហ៍ពិពាហ៍ អាចប្រើនាមត្រកូលដែលមាននៅមុនអាពាហ៍ពិពាហ៍មុនវិញបាន ឬអាចប្រើនាមត្រកូលដែលបានប្រើនៅពេលលែងលះគ្នាក៏បាន[64]។

[64] មាត្រា ៩៨១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

# ជំពូកទី៣

# ផលប៉ះពាល់ទូទៅនៃការ លែងលះ ឬការផ្ដាច់នីតិ

# សន្មាស

# ជំពូកទី៣
# ផលប៉ះពាល់ទូទៅនៃការលែងលះ ឬការផ្តាច់នីតិសង្វាស

## ផ្នែកទី១៖ ផលប៉ះពាល់ក្នុងគ្រួសារ

ការលែងលះគឺបណ្តាលឲ្យសហព័ទ្ធរងនូវភាពតានតឹងក្នុងចិត្ត មានអារម្មណ៍មិនល្អ មានការធ្លាក់ទឹកចិត្តនិងគេងមិនលក់ជាដើមដែលនាំឲ្យមានជម្ងឺផ្សេងៗប្រចាំកាយ។ ផលប៉ះពាល់ចំពោះសហព័ទ្ធបណ្តាលមកពីការលែងលះ ដែលគ្រប់គ្នាកំពុងមើលឃើញជាក់ស្តែងនោះគឺ ផលប៉ះពាល់ខ្ពស់ទៅលើកូនដែលកំពុងរស់នៅក្នុងបន្ទុកគ្រួសារផ្ទាល់តែម្តង។ ចំពោះការចែកទ្រព្យសម្បត្តិដែលសហព័ទ្ធបានរកស៊ីជាមួយគ្នាកន្លងមក ជាពិសេសអានុភាពលើកូនទាក់ទងនឹងអំណាចមេបាក៏មានផលលំបាកក្នុងការបែងចែក និងមានភាពស្មុគស្មាញផងដែរ។ ឯក្នុងករណីការលែងលះភាគច្រើនយើងមើលឃើញថា ភាគីខាងប្រពន្ធហាក់មានផលប៉ះពាល់ជាងភាគីខាងប្តី ព្រោះថា ស្ត្រីមានភាពទន់ខ្សោយជាងបុរសក្នុងការស្វែងរកប្រាក់កាសសម្រាប់ផ្គត់ផ្គង់ជីវភាពរស់នៅប្រចាំថ្ងៃ ជាពិសេសក្នុងសង្គមកម្ពុជាបច្ចុប្បន្នស្ត្រីហាក់ពឹងទៅលើចំណូលខាងប្តីច្រើនជាងខ្លួនចំណូលខ្លួនឯង។ ចំណែកផលប៉ះពាល់ចំពោះសាច់ញាតិទាំងសងខាងរបស់សហព័ទ្ធក៏មានតិចតួចផងដែរ។

### ១.១ ចំពោះកូន

#### ១.១.១ ផ្លូវចិត្ត

កូនតែងតែមានភាពឈឺចាប់ក្នុងចិត្ត ហើយអាចធ្លាក់ចូលទៅក្នុងភាពតក់ស្លុត នៅពេលឃើញឪពុកម្តាយបែកបាក់គ្នា ហើយអាចបាត់បង់ការចាប់អារម្មណ៍លើសកម្មភាពផ្សេងៗ មានភាពតានតឹង ឆាប់ខឹង ការខកចិត្ត និងទុក្ខព្រួយខ្លាំង ដោយសារតែពួកគេមិនមានការគាំទ្រផ្នែកស្មារតីដ៏ពេញលេញពីឪពុកម្តាយរបស់ពួកគេ។ ការលែងលះបង្កើតភាពរំជើបរំជួលអារម្មណ៍សម្រាប់ក្រុមគ្រួសារទាំងមូល ប៉ុន្តែសម្រាប់កូនៗ ស្ថានភាពបែបនេះគួរឲ្យព្រួយបារម្ភណ៍ និងភ័យខ្លាចជាងអ្វីដែលគ្រួសារកំពុងមើលឃើញផ្ទាល់ទៅទៀត[65]។ កុមារតូចៗជារឿយៗពួកគេប្រហែលជាបារម្ភថាបើឪពុកម្តាយរបស់ពួកគេបានឈប់ស្រឡាញ់គ្នាទៅវិញទៅមក ថ្ងៃណាមួយឪពុកម្តាយ ប្រហែលជាឈប់ស្រឡាញ់ខ្លួនផងដែរ។ ក្មេងៗនៅសាលារៀនប្រហែលជាបារម្ភថាការលែងលះគឺជាកំហុសរបស់ពួកគេ។ ពួកគេប្រហែលជាភ័យខ្លាចថាពួកគេមិនមានសីលធម៌ ឬពួកគេអាចសន្មត់ថាពួកគេបាន

[65] https://km.drafare.com

ធ្វើអ្វីខុស។ ក្មេងជំទង់អាចមានកំហឹងខ្លាំងចំពោះការលែងលះនិងការផ្លាស់ប្តូរដែលវាបង្កើត។ ពួកគេប្រហែលជាបន្ទោសទៅលើមាតាឬបិតាម្នាក់ចំពោះការរំលាយអាពាហ៍ពិពាហ៍ ឬពួកគេប្រហែលជាមិនសប្បាយចិត្តនឹងឪពុកម្តាយម្នាក់ឬទាំងពីរនាក់ចំពោះភាពចលាចលក្នុងគ្រួសារ។ បញ្ហាផ្លូវចិត្ត វាជាបញ្ហាមួយធ្ងន់ធ្ងរ បើពុំមានការមើកថែ យកចិត្តទុកដាក់នោះទេ វាអាចឈានទៅដល់ការកើតជាជំងឺស្រ្តេស ហើយក៏អាចវិវត្តន៍ទៅរកជំងឺធ្លាក់ទឹកចិត្តបាន។

### ១.១.២ សុខភាព

ចំពោះផលប៉ះពាល់ផ្នែកសុខភាពទៅលើកូនៗដែលឪពុកម្តាយមានការបែកបាក់គ្នា គឺធ្វើឲ្យកូនៗខ្វះអ្នកថែទាំអ្នកសុខភាព ខ្វះអាហារបំប៉នសម្រាប់ការលូតលាស់ និងខ្វះអ្នកគាំទ្រផ្លូវចិត្តផងដែរ។ ម៉្យាងទៀតពួកគេមិនមានប្រាក់ ដើម្បីទិញចំណីអាហារគ្រប់គ្រាន់ទាំងនោះទេ ហើយនៅពេលដែលមានជំងឺ ពួកគេមិនមានលទ្ធទៅរកគ្រូពេទ្យ ឬទិញថ្នាំព្យាបាលទេ ជាហេតុធ្វើឲ្យពួកគេធ្លាក់ទឹកចិត្ត និងរហូតឈានទៅដល់មានជម្ងឺប្រចាំកាយទៀតផង។ កុមារជាទូទៅគឺត្រូវការថែទាំ យកចិត្តទុកដាក់ ពីសំណាក់ឪពុកម្តាយ ប្រសិនបើឪពុកម្តាយលែងលះគ្នាកុមារពិតជារងការប៉ះទង្គិចជាច្រើនមិនថា ផ្លូវចិត្ត ឬផ្លូវកាយ វាសុទ្ធតែធ្វើឲ្យប៉ះពាល់ដល់សុខភាពទាំងអស់ កុមារអាចគ្មានស្មារតីស្រស់ថ្លា បាត់បង់នូវចំណង់អាហារ គ្មានភាពរស់រវើង ដែលជាហេតុនាំឲ្យកុមារមានជំងឺ។

### ១.១.៣ ការសិក្សាអប់រំ

ការលែងលះរបស់ឪពុកម្តាយធ្វើឲ្យកូនៗ មានការព្រួយបារម្ភនិងពិបាកក្នុងចិត្ត ជាពិសេសពិបាកក្នុងការផ្តោតអារម្មណ៍ទៅលើការសិក្សារបស់គាត់តែម្តង។ នៅពេលដែលម្តាយឪពុកលែងលះគ្នាជាលទ្ធផលការសិក្សារបស់ពួកគេតែងតែទទួលរងការប៉ះពាល់។ ក្នុងគ្រួសារមួយ នៅពេលគ្រួសារនោះមាន បញ្ហា មានជម្លោះ ឈានដល់ការលែងលះ កូនៗក៏ជួបប្រទះបញ្ហាជាច្រើនផងដែរ ក្នុងវ័យក្មេង កូនៗគឺត្រូវការការសិក្សាអប់រំជាសំខាន់ ប៉ុន្តែក្រោយជួបប្រទះនឹងបញ្ហាបែបនេះ វាប្រាកដជាជះឥទ្ធិពលខ្លាំងទៅលើការសិក្សារបស់ពួកគេ ពួកគេអាចបាត់បង់អារម្មណ៍សិក្សា ព្រោះក្នុងខ្លួនពួកគេកំពុងតែមានការលំបាកទាក់ទងនឹងបញ្ហាគ្រួសារ ហើយខ្លះទៀតអាចនឹងឈប់សិក្សា ។ ពួកគេមួយចំនួនបានឈប់សិក្សា ចំណែកឯមួយចំនួនផ្សេងទៀតចាប់ផ្តើមធ្វើការងារក្រៅម៉ោងសិក្សា ដើម្បីជួយផ្គត់ផ្គង់ជីវភាពគ្រួសារ។ មួយវិញទៀតពួកគេតែងតែប្តូរសាលារៀនជាញឹកញាប់ទៀតផង ដើម្បីទៅរស់នៅខាងណាម្នាក់ ជាឪពុកឬជាម្តាយដែលតុលាការបានផ្តល់សិទ្ធិលើអំណាចមេបា។ ចំពោះពួកគេដែលនៅបន្តសិក្សានៅសាលារៀនដដែលនោះវិញ ត្រូវបានរាយការណ៍ថា ពួកគេក៏ត្រូវបានគេមើលងាយ និងរើសអើងទៀតផង។

**១.១.៤ កិត្តិយស**

កូនៗដែលមានឪពុកម្តាយលែងលះគ្នា ពួកគេត្រូវបានរងការមើលងាយពីមនុស្សជុំវិញខ្លួនថាជាពូជពង្សមួយមិនល្អ ថែមទាំងហៅពួកគេថាជាកូនគ្មានម៉ែគ្មានឪពុកជាដើម ដែលធ្វើឲ្យពួកគេពិបាកក្នុងការរកការងារធ្វើ ក៏ដូចជាពិបាកក្នុងការរើសគូស្រករទៀតផង ក៏ព្រោះតែក្នុងសង្គមខ្មែរនាពេលបច្ចុប្បន្នមិនទាន់បោះបង់ចោលនៅឡើយទេពាក្យថា " ស្លឹកឈើជ្រុះមិនឆ្ងាយពីគល់" ដែលមានន័យថាប្រសិនបើឪពុកម្តាយរបស់ពួកគេជាមនុស្សប្រភេទណាកូនៗរបស់ពួកគាត់ ក៏ជាមនុស្សប្រភេទនោះដែរ។ នេះជាការគិតមួយដែលមិនល្អ ក៏ព្រោះតែពួកគេមិនប្រាកដថាជាមនុស្សដែលមិនល្អនោះដែរ។ ការស្ថិតនៅក្នុងគ្រួសារដែលបែកបាក់គ្នា វាពុំមែនជាកំហុសរបស់ពួកគេទេ។ ការដែលវាយតម្លៃពួកគេទៅលើស្ថានភាពគ្រួសារវាជាការគិតមួយដែលអគតិ វាធ្វើឲ្យប៉ះពាល់ដល់កិត្តិយសរបស់បុគ្គលទាំងដែលគេពុំបានធ្វើអ្វីខុស។

**១.១.៥ ការបំពានផ្លូវភេទ**

នៅពេលមានការលែងលះគ្នា កូនៗតែងតែទៅរស់នៅខាងម្តាយឬឪពុករបស់ពួកគេណាម្នាក់ជាក់ជាមិនខាន។ ការរស់នៅជាមេម៉ាយ ឬពោះម៉ាយមិនយូរមិនឆាប់ពួកគេនឹងចង់បានដៃគូថ្មីមួយទៀត ដើម្បីរស់នៅជាមួយគ្នានឹងមើលថែគ្នា។ យើងគ្រប់គ្នាតែងតែបានលឺបានដឹងតាមសារព័ត៌មានផ្សេងៗ ជាពិសេសតាមបណ្តាញសង្គមទំនាក់ទំនងនានា តែម្តងទៅលើ មានករណីរំលោភផ្លូវភេទជាច្រើន ដែលជនបង្កជាឪពុកចុងរបស់ក្មេងស្រីនោះជាអ្នករំលោភ។ មានករណីជាច្រើនតែងឃើញកើតមានឡើងជារឿយៗ ដែលឪពុកចុងធ្វើសកម្មភាពរំលោភទៅលើកូនចុង នៅពេលដែលម្តាយមិននៅ ព្រមទាំងបានគំរាមមិនឲ្យប្រាប់នរណា បើពុំដូចច្នោះគេនឹងវាយធ្វើបាប។ ករណីបែបនេះឃើញមានជាញឹកញាប់ ដែលវាគឺជាអំពើដែលស្មោគគ្រោក និងមិនអាចទទួលយកបាន ដែលសង្គមមិនចង់ឲ្យកើតមាន។

**១.២ ចំពោះប្រពន្ធ**

**១.២.១ សេដ្ឋកិច្ច**

នាពេលបច្ចុប្បន្នយើងសង្កេតឃើញថា ស្ត្រីមួយចំនួនធំហាក់នៅពឹងលើប្រាក់ចំណូលប្តីនៅឡើយ ប្រសិនបើមានការលែងលះ នឹងធ្វើប៉ះពាល់ការចាយវាយប្រចាំថ្ងៃរបស់នាងជាក់ជាមិនខាន។ អ្នកខ្លះក្រោយពីលែងលះ បើគាត់មានចំណេះជំនាញគាត់អាចទៅស្វែងរកការងារធ្វើបាន ប៉ុន្តែសម្រាប់អ្នកដែលគាត់គ្មានចំណេះជំនាញទេ វាពិតជាពិបាកសម្រាប់គាត់ខ្លាំងក្នុងការរកការងារធ្វើ។ អ្នកខ្លះគាត់ត្រូវបង្ខំចិត្តទៅធ្វើការងាររកស៊ីណាដែលពុំត្រូវការជំនាញខ្ពស់ទេ តែវាគឺប្រឈម និងទទួលរងនូវការរិះគន់ ឬត្មិះដៀលពីអ្នកដទៃ។

### ១.២.២ ការងារ

នៅពេលដែលមានការលែងលះគ្នា ស្ត្រីហាក់មានប៉ះពាល់ទៅលើការងាររបស់ពួកគេផងដែរ ប្រសិនបើស្ត្រីនោះមានកូននៅតូចហើយអំណាចមេបាបានមកលើស្ត្រីនោះ នឹងធ្វើឲ្យនាងពិបាកទៅធ្វើការរបស់នាងព្រោះជាប់មើលកូននៅតូច។ មិនមែនពិបាកចំពោះតែការមើលថែរក្សាកូនប៉ុណ្ណោះទេ គាត់អាចនឹងពិបាករកការងារធ្វើទៀតផង។ ព្រោះស្ត្រីខ្លះកាលនៅមានចំណងអាពាហ៍ពិពាហ៍ គាត់អាចឈប់ធ្វើការដើម្បីនៅផ្ទះមើលថែរក្សាកូន ថែរក្សាផ្ទះសម្បែងសុខចិត្តលះបង់ការងារ តែក្រោយពីលែងលះគ្នា ស្ត្រីគឺបាត់អ្នករកប្រាក់ដូចនេះគាត់ត្រូវរកប្រាក់ដោយខ្លួនឯង បើអ្នកមានចំណេះជំនាញគាត់អាចមានសមត្ថភាពរកការងារសមរម្យបាន តែចំពោះអ្នកដែលគ្មានចំណេះជំនាញគាត់អាចនឹងពិបាករកការងារធ្វើ។ អ្នកខ្លះគាត់ត្រូវទៅធ្វើការរោងចក្រ ខ្លះធ្វើការនៅក្នុងហាងនានាជាដើម ហើយទទួលប្រាក់ខែក៏មិនច្រើនដែលវាជាការលំបាកដល់ពួកគាត់។

### ១.២.៣ កិត្តិយស

នៅក្នុងសង្គមខ្មែរ តាំងតែពីអតីតកាល រហូតដល់បច្ចុប្បន្ន នៅមិនទាន់បានលះបង់នៅឡើយទេ ពាក្យថាឈ្មោះជាមេម៉ាយចំណាយមាត់អ្នកស្រុក ដែលន័យនេះសំដៅលើស្ត្រីដែលត្រូវបានលែងលះជាមួយស្វាមីហើយត្រូវបានគេមាក់ងាយ ឬពេបជ្រាយ ថាជាស្ត្រីមិនល្អ ថែមទាំងមិនឲ្យតម្លៃនៅក្នុងសង្គមនោះទេ។ ប្រាកដណាស់ការលែងលះជះផលអាក្រក់ដល់កិត្តិយសចំពោះស្ត្រីក្នុងសង្គមខ្មែរជាការពិតមែន តែអាចនឹងជះផលអាក្រក់ជាងនេះទៅទៀត បើការរស់នៅនោះ ជាការរស់នៅមួយមិនចុះសម្រុងនឹងគ្នា។ ដូច្នេះតើស្ត្រីនៅតែទ្រាំរស់នៅ ក្រោមសម្ពាធជាមួយស្វាមីបន្តទៀត រឺយ៉ាងណា? ដើម្បីបន្តរក្សាកិត្តិយសរបស់ខ្លួន។ សំណួរនេះមានតែស្ត្រីដែលធ្លាប់ឆ្លងកាត់ផ្ទាល់ទេដែលអាចឆ្លើយបាន។

### ១.២.៤ សុខភាព

ការលែងលះនឹងធ្វើស្ត្រីមានការប្រេះស្រាំក្នុងចិត្ត ឈឺផ្សា រហូតឈានដល់មានជម្ងឺប្រចាំកាយ។ នៅក្នុងដំណាក់កាលនៃការលែងលះគ្នា ភាគីសុទ្ធតែបានឆ្លងកាត់រួចមកហើយនូវការឈ្លោះប្រកែកគ្នា។ ការប៉ះទង្គិចទាំងអស់នេះសុទ្ធតែបានធ្វើឲ្យមានការឈឺចាប់ទាំងផ្លូវកាយ និងផ្លូវចិត្ត ហើយស្ត្រីគឺជាបុគ្គលដែលងាយរងគ្រោះព្រោះគាត់មានស្មារតីទន់ខ្សោយជាងបុរស។ ស្ត្រីគាត់អាចមានបញ្ហាផ្លូវចិត្តដោយសារមានអារម្មណ៍ថាខ្មាសគេព្រោះរងនូវសម្ពាធពីអ្នកនៅជុំវិញខ្លួន ពីសង្គម ដែលអាចបណ្តាលឲ្យគាត់មានបញ្ហាសុខភាពជាញឹកញាប់។

### ១.២.៥ ការបំពានលើផ្លូវភេទ

នៅពេលដែលស្ត្រីមានការលែងលះគ្នាជាមួយស្វាមីរបស់នាង នឹងនាំឲ្យមានការរំលោភបំពាកលើផ្លូវភេទរបស់នាងក្នុងរូបភាពណាមួយជាក់ជាមិនខាន។ ប្រុសៗមួយចំនួនដែលឃើញនាងថាជាស្ត្រីម៉េម៉ាយតែងតែលេបខាយ លេងសើចឡកឡើយជាមួយនាង ដោយមានការគិតថាស្ត្រីមេម៉ាយដែលធ្លាប់រៀបការហើយ បន្ទាប់មកក៏លែងលះគ្នា ជាស្ត្រីដែលពួកគេអាចលេងសើចបាន ងាយធ្វើបាប អាចចំអកបានតាមចិត្ត ហើយមានបុរសខ្លះមានគំនិតមិនល្អ ខ្លះមានបំណងអាក្រក់ដល់ថ្នាក់ធ្វើសកម្មភាពរំលោភបំពានផ្លូវភេទលើនាងទៀតផង

ដោយសារតែនាងរស់នៅម្នាក់ឯងគ្មានទីបង្អែក គ្មានបុរសនៅជិតដែលធ្វើជាទីពុំនាក់បាន ដូចនេះពួកគេក៏ធ្វើសកម្មភាពដ៏អាក្រក់នេះបាន។

### ១.២.៦ ទំនាក់ទំនងរវាងម្ដាយនិងកូន

ការលែងលះនឹងធ្វើឲ្យទំនាក់ទំនងម្ដាយនឹងកូនហាក់ឃ្លានគ្នា ប្រសិនបើឪពុកជាអ្នកមានអំណាចមេបាទៅលើកូននោះ ព្រោះម្ដាយមិនអាចទៅលេងបានញឹកញាប់បានទេ ដែលធ្វើឲ្យទំនាក់ទំនងរបស់ម្ដាយនិងកូនកាន់តែឆ្ងាយទៅៗ បើកូនស្ថិតនៅវ័យក្មេង វាគឺជាវ័យដែលត្រូវការការមើលថែទាំពីសំណាក់ឪពុកម្ដាយ កាលបើកូនត្រូវបែកពីម្ដាយ ឬឪពុកក្នុងវ័យក្មេង ក្មេងនឹងអាចភ្លេចមុខម្ដាយ ហើយមនោសញ្ចេតនាក៏បាត់ម្ដងបន្តិចៗរហូតដល់កូនភ្លេចម្ដាយក៏ថាបាន។

## ១.៣ ចំពោះប្ដី

### ១.៣.១ ការងារ

ការងារមួយចំនួនរបស់ប្ដី នឹងបាត់ដៃគូសហការជាក់ជាមិនខាននៅពេលដែលមានការលែងលះ ជាពិសេសទៅលើមុខជំនួញជួញដូរផ្សេងៗតែម្ដង ព្រោះដៃគូសហការមានការភ័យខ្លាចបរាជ័យបណ្ដាលមកពីការលែងលះ។

### ១.៣.២ សេដ្ឋកិច្ច

នៅពេលមានការលែងលះនឹងធ្វើឲ្យសេដ្ឋកិច្ចធ្លាក់ចុះជាក់ជាមិនខានព្រោះ ចំណូលដែលធ្លាប់បានទាំងអស់គ្នាត្រូវបានបែកជាពីរទៅហើយ ដែលធ្វើឲ្យការចាយវាយផ្សេងៗមានការពិបាកមែនទែន។ ការលែងលះបានធ្វើឲ្យប៉ះពាល់ដល់ការងាររបស់គាត់ និងការរកប្រាក់ចំណូលក៏ធ្លាក់ចុះទៅតាមនឹងដែរ។

### ១.៣.៣ កិត្តិយស

ជាធម្មតាបុរសគ្រប់គ្នា សុទ្ធតែមានកិត្តិយស និងសេចក្ដីថ្លៃថ្នូរ ដូច្នេះកាលណាមានការបែកបាក់គ្នា ឬមានការលែងលះតែងតែអាប់ឱនដល់កិត្តិយសខ្លួន និងមានការរើសអើងក្នុងសង្គមទៀតផង។ មួយវិញទៀតប្រសិនបើខ្លួនចង់រកគូស្រករថ្មីទៀត អាចជួបការលំបាក ដោយហេតុថាធ្លាប់លែងលះជាមួយដៃគូចាស់ពីមុនម្ដងរួចមកហើយ។ ចំពោះបុគ្គលខ្លះដែលមានមុខមាត់ ឬបុណ្យសក្ដិខ្ពស់ កាលណាមានការលែងលះវាតែងប៉ះពាល់ដល់កិត្តិយសគាត់ អាចនឹងពិបាកប្រឈមមុខនៅក្នុងសង្គម។

### ១.៣.៤ សុខភាព

នៅពេលមានការលែងលះ ខាងប្ដីភាគច្រើនតែងតែមានការឈឺចាប់ក្នុងចិត្ត ផឹកស្រាច្រើនហួសហេតុដែលបណ្ដាលឲ្យប៉ះពាល់ដល់សុខភាពផ្លូវកាយយ៉ាងធ្ងន់ធ្ងរ។ ចំពោះពាក្យថាលែងលះ ការបែកបាក់គ្នាមិនមែនជាបំណងប្រាថ្នារបស់មនុស្សគ្រប់គ្នានោះទេ ដូចនេះនៅពេលដែលគ្រួសារមួយបែកបាក់ភាគីទាំងសងខាងតែមានការលំបាករៀងខ្លួន បុរសអាចនឹងមិនបង្ហាញការលំបាក ឬការពិបាកនោះចេញមកខាងក្រៅដូចមនុស្សស្រីតែក៏មិនប្រាកដថាគាត់មិនពិបាកនោះដែរ ។

### ១.៣.៥ ទំនាក់ទំនងរវាងឪពុកនឹងកូន

ការលែងលះនឹងបណ្ដាលឲ្យទំនាក់ទំនងឪពុកនិងកូនហាក់ឃ្លាតឆ្ងាយពីគ្នាបន្តិចម្ដងៗ ប្រសិនកូននោះរស់នៅជាមួយម្ដាយហើយម្ដាយមិនឲ្យឪពុកមកលេងកូននោះទេ។ ជាការពិតណាស់ នៅពេលដែលការរស់នៅឃ្លាតឆ្ងាយពីគ្នា ទំនាក់ទំនងក៏មិនបានជិតដិតដូចមុនដែរ ហើយមនោសញ្ចេតនាក៏ពុំមានដូចកាលពីមុនដែរ។ កូនខ្លះពេលដែលធំឡើងសឹងតែមិនចង់ស្គាល់ឪពុកថែមទៀតផង ព្រោះខានជួបគ្នា និងប្រាស្រ័យទាក់ទងគ្នា។

### ១.៤ ចំពោះសាច់ញាតិសហព័ទ្ធទាំងសងខាង

ការលែងលះនឹងបណ្ដាលឲ្យសាច់ញាតិទាំងសងខាងមើលមុខគ្នាមិនត្រូវ ជាពិសេសដន្លងនិងដន្លងតែម្ដង។ ចំពោះសាច់ញាតិផ្សេងៗទៀតក៏មានផលប៉ះពាលផងដែរ។ ក្រោយពីការលែងលះ ឃើញថាទំនាក់ទំនងសាច់ញាតិសហព័ទ្ធទាំងសងខាងអាចមានការរកាំរកូសគ្នា បញ្ចប់ការទាក់ទងគ្នា ហើយខ្លះទៀតក៏បញ្ចប់ដោយភាពមិនស្រុះស្រួលគ្នា បានន័យថាពួកគាត់អាចកើតមានជម្លោះជាមួយគ្នា។

## ផ្នែកទី២៖ ផលប៉ះពាល់ក្នុងសង្គម

### ២.១ សង្គមពោរពេញដោយក្មេងកំព្រាច្រើន

នៅពេលដែលក្រុមគ្រួសារមួយបានបែកបាក់ បុគ្គលទាំងពីរបានចែកផ្លូវគ្នាដើររៀងៗខ្លួន វាមិនសូវពិបាកទេ ប្រសិនបើចំណងអាពាហ៍ពិពាហ៍របស់ពួកគេមិនមានកូន តែប្រសិនបើពួកគេមានកូនក្នុងចំណងអាពាហ៍ពិពាហ៍ បន្ទាប់ពីលែងលះគ្នា ថាតើកូនរបស់គេនឹងទៅជាយ៉ាងណា? ត្រូវទៅនៅជាមួយនរណា ខាងម្ដាយ ឬខាងឪពុក? ក្នុងករណីខ្លះពេលដែលម្ដាយ ឪពុកមានចំណងអាពាហ៍ពិពាហ៍ថ្មី ឬបង្កើតគ្រួសារថ្មីមួយទៀត ពួកគេអាចមានការធ្វេសប្រហែស ឬមិនបានយកចិត្តទុកដាក់ខ្លាំងលើកូនមុន បែបនេះវាក៏ជាហេតុនាំឲ្យក្មេងមានអារម្មណ៍ថាខ្វះក្ដីស្រលាញ់ហើយវាក៏ជាហេតុនាំឲ្យមានការប៉ះពាល់ដល់ផ្លូវចិត្តរបស់ក្មេង អាចឈានដល់ការមិនចង់រស់នៅក្នុងផ្ទះតទៅទៀត ខ្លះរត់ចេញពីផ្ទះ បែបនេះសង្គមក៏បាត់បង់នូវធនធានមនុស្សដែលជាទំពាំងស្នងឫស្សីនាថ្ងៃអនាគត ពួកគេអាចក្លាយជាក្មេងកំព្រា វាក៏ក្លាយជាបន្ទុកមួយសម្រាប់សង្គមក្នុងការជួយមើលថែរក្សាពួកគេ។

### ២.២ ស្ត្រីមេម៉ាយ និងពោះម៉ាយច្រើន

ក្រោយពេលលែងលះ អ្នកខ្លះអាចបង្កើតចំណងអាពាហ៍ពិពាហ៍ថ្មី រីឯអ្នកខ្លះទៀតពួកគេសុខចិត្តរស់នៅម្នាក់ឯងជារៀងរហូតដោយមិនព្រមសាងគ្រួសារថ្មីទេ។ ហេតុផលទាំងនេះ វាក៏ជាកត្តាមួយដែលធ្វើឲ្យសង្គមយើងសម្បូរទៅដោយស្ត្រីមេម៉ាយ និងពោះម៉ាយច្រើន ហើយចំនួនប្រជាជនក៏ពុំសូវមានការកើនឡើងកាលណាដែលអត្រានៃការលែងលះកាន់តែមានកម្រិតខ្ពស់។ ប្រសិនបើពុំមានការលែងលះ ក្រុមគ្រួសារមួយយ៉ាងតិចក៏

មានកូនពីរនាក់ដែរ មួយវិញទៀតបើការលែងលះបានសម្រេច ក្រុមគ្រួសារខ្លះមានកូនមួយឬពីរនាក់ក្រោយការបញ្ចប់ចំណងអាពាហ៍ពិពាហ៍ពួកគេគ្មានបំណងរៀបអាពាហ៍ពិពាហ៍ថ្មី ដោយនៅជាស្ត្រីមេម៉ាយ ឬពោះម៉ាយបែបនេះឃើញថាកំណើតប្រជាជនក៏គ្មានការកើនឡើង ហើយវាក៏បានជះផលប៉ះពាល់ខ្លះដល់សង្គមផងដែរ។

**២.៣ ជាបន្ទុកធ្ងន់សម្រាប់សង្គម**

នៅពេលមានការលែងលះគ្នា កាន់តែច្រើននឹងធ្វើឲ្យ សង្គមត្រូវប្រើកញ្ចប់ថវិកាជាតិជាច្រើន ដើម្បីទប់ទល់ទៅនឹងបញ្ហានៃការលែងលះនេះ មានដូចជាកញ្ចប់ថវិកាសម្រាប់ក្មេងដែលឪពុកម្តាយរបស់ពួកគេមានការបែកបាក់គ្នា កញ្ចប់ថវិកាសម្រាប់ស្ត្រីដែលត្រូវលែងលះគ្នា និងកញ្ចប់ថវិកាជាតិបម្រុងជាច្រើនទៀត ទុកសម្រាប់ទ្រទ្រង់សង្គមជាតិ ដែលបណ្តាលមកពីករណីនៃការលែងលះនេះ។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការស្រាវជ្រាវ និងបកស្រាយយ៉ាងលំអិតទាក់ទងនឹងប្រធានបទស្តីពី " ការលែងលះ និងផលប៉ះពាល់នៃការលែងលះ " រួចមកប្រធានបទនេះពិតជាបានឆ្លុះបញ្ចាំងយ៉ាងច្បាស់ថា ការបញ្ចប់ទំនាក់ទំនងអាពាហ៍ពិពាហ៍ដ៏ល្អបំផុត គឺការដោះស្រាយតាមប្រព័ន្ធតុលាការ ដោយអនុលោមទៅតាមច្បាប់ផ្សេងៗ ដែលពាក់ព័ន្ធទៅនឹងការផ្តាច់ចំណងអាពាហ៍ពិពាហ៍។ ការបង្កើតក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី គឺបានផ្តល់ប្រយោជន៍ជាច្រើន ដើម្បីងាយស្រួលដោះស្រាយ និងការពារភាពសុចរិតយុត្តិធម៌នូវរាល់វិវាទដែលកើតមានឡើងនៅក្នុងសង្គម រវាងភាគីប្តីប្រពន្ធ ដែលចង់រំលាយចំណងអាពាហ៍ពិពាហ៍។ ចំពោះប្តីប្រពន្ធណាដែលមានសំបុត្រអាពាហ៍ហ៍ពិពាហ៍ត្រឹមត្រូវ។ ប្រសិនបើភាគីណាមួយចង់លែងលះគ្នា ដោយហេតុផលណាមួយ មិនថាការលែងលះនោះជាការលែងលះដោយការព្រមព្រៀង ឬដោយគ្មានការព្រមព្រៀងនោះទេ ភាគីដែលចង់លែងលះអាចដាក់ពាក្យបណ្តឹងទាមទារលែងលះនេះ ទៅសាលាដំបូងរាជធានី/ខេត្តដែលខ្លួនកំពុងរស់នៅ។ នៅពេលតុលាការរកឃើញថាមានមូលហេតុ និងភស្តុតាងបញ្ជាក់យ៉ាងច្បាស់លាស់ថាភាគីទាំងពីរពិតជាមិនអាចរួមរស់នៅជាមួយគ្នាបានទៀតទេ នោះតុលាការត្រូវសម្រេចឲ្យភាគីទាំងពីរលែងលះគ្នាតាមរយៈអំណាច សាលក្រមនេះបើយោងតាមច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល។

ការលែងលះដែលគោរពទៅតាមនីតិវិធីច្បាប់បានត្រឹមត្រូវ នោះនឹងធ្វើឲ្យមានភាពងាយស្រួលក្នុងការបែងចែកទ្រព្យសម្បត្តិ និងអំណាចមេបាលើកូន ព្រោះច្បាប់មានលក្ខណៈចាប់បង្ខំឲ្យភាគីនីមួយៗត្រូវតែប្រតិបត្តិ។ ដូចនេះដើម្បីរក្សាផលប្រយោជន៍ទាំងសងខាងរបស់សហព័ទ្ធ ប្តីប្រពន្ធត្រូវតែចេះអធ្យាស្រ័យឲ្យគ្នាទៅវិញទៅមកគ្រប់ពេលវេលា មិនថាក្នុងគ្រាលំបាកយ៉ាងណាទេ ទើបគ្រួសារមានសុភមង្គល និងសេចក្តីសុខក្នុងរង្វង់គ្រួសារក៏ដូចជាសហគមន៍ទាំងមូល។ ព្រោះការលែងលះបានធ្វើឲ្យបាត់បង់ទាំងប្រាក់កាស ទាំងពេលវេលា និងកិត្តិយសរបស់សហព័ទ្ធទាំងសងខាងផងដែរ។

ជារួមមកដើម្បីរើសគូ ស្រករក្នុងការរស់នៅជាមួយគ្នាជាប្តីប្រពន្ធ ដៃគូទាំងសងខាងត្រូវតែស្វែងយល់និងសិក្សាពីគ្នាទៅវិញទៅឲ្យបានស៊ីជម្រៅជាមុនសិន មុននឹងឈានទៅដល់ថ្ងៃរៀបការ ទើបការរស់នៅជាមួយគ្នាប្រកបដោយសុភមង្គលពេញមួយជីវិត។

# អនុសាសន៍

# អនុសាសន៍

ជាចុងក្រោយបំផុត ក្នុងគោលបំណង និងឆន្ទៈ ដើម្បីធ្វើឲ្យស្នាដៃមួយនេះ អាចយកទៅអនុវត្តបានយ៉ាងត្រឹមត្រូវ សមស្របទៅនឹងស្ថានភាពនិងកាលៈទេសៈជាក់ស្តែង ក៏ដូចជាកាត់បន្ថយការលែងលះក្នុងសង្គម យើងខ្ញុំសូមការអនុញ្ញាតលើកឡើងនូវអនុសាសន៍មួយចំនួនដូចខាងក្រោមៈ

- ចំពោះរដ្ឋ ឬរដ្ឋាភិបាល

-សូមរាជរដ្ឋាភិបាលធ្វើការផ្សព្វផ្សាយច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះឱ្យបានយល់ដឹងគ្រប់ៗគ្នា ជាពិសេសដាក់ទណ្ឌកម្មដល់អ្នករំលោភបំពានច្បាប់នេះ និងអ្នកប្រើប្រាស់អំពើហិង្សាក្នុងគ្រួសារឲមានលក្ខណៈធ្ងន់ធ្ងរ

-សូមឲ្យមានការការពារផ្លូវច្បាប់ដោយតុលាការ នៅក្នុងករណីមានការលែងលះគ្នា

-សូមឲ្យស្ថាប័នដែលពាក់ព័ន្ធគួរតែបណ្តុះបណ្តាលដល់មន្ត្រីដែលធ្វើការផ្នែកអគ្រានុកូលដ្ឋានតាមមូលដ្ឋានឲ្យយល់ដឹងបានទូលំទូលាយពីសេវាសាធារណៈនេះ ដើម្បីឲ្យពួកគាត់មានសមត្ថភាពគ្រប់គ្រាន់ក្នុងការបំពេញការងារជូនប្រជាពលរដ្ឋ។

-សូមរាជរដ្ឋាភិបាលមេត្តាទប់ស្កាត់ការប្រើប្រាស់គ្រឿងស្រវឹងឲ្យមានប្រសិទ្ធភាពនិងស្របតាមពេលវេលាជាក់ស្តែង។

-សូមរាជរដ្ឋាភិបាលជួយទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀននៅក្នុងសង្គមឲ្យមានប្រសិទ្ធភាពខ្ពស់។

- ចំពោះមន្ត្រីអនុវត្តច្បាប់

-សូមឲ្យមន្ត្រីនៅថ្នាក់មូលដ្ឋាន ដែលពាក់ព័ន្ធទៅនឹងសំណុំរឿងនៃការលែងលះគួរតែជួយផ្សះផ្សាសហព័ទ្ធនោះឲ្យអស់លទ្ធភាពជាមុនសិន មុនពេលសម្រេចចិត្តឲ្យពួកគាត់លែងលះគ្នាតាមផ្លូវតុលាការ

-សូមឲ្យអាជ្ញាធរដែនដីធ្វើអន្តរាគមន៍ជាបន្ទាន់រាល់ពេលមានអំពើហិង្សាកើតឡើង ដើម្បីទប់ស្កាត់កុំឲ្យមានអំពើហិង្សាធ្ងន់ធ្ងររហូតឈានទៅដល់ការលែងលះគ្នា

-សូមឲ្យមន្ត្រីដែលពាក់ព័ទ្ធមេត្តាផ្តល់នូវជំនួយផ្លូវច្បាប់ណាមួយដែលសមស្របតាមរយៈកាលៈទេសៈជាក់ស្តែង និងធានាសុវត្ថិភាពដល់គូភាគីនៅពេលមានបណ្តឹងលែងលះកើតឡើង

-សូមមន្ត្រីនៅថ្នាក់មូលដ្ឋាន ចុះបណ្តុះបណ្តាលជូនពលរដ្ឋរបស់ខ្លួនពីផលប៉ះពាល់នៃការលែងលះ និងផលប៉ះពាល់នៃការប្រើប្រាស់អំពើហិង្សាក្នុងគ្រួសារ

❖ ចំពោះប្តីប្រពន្ធ

-សូមប្តីប្រពន្ធគិតឲ្យបានវែងឆ្ងាយ មុនសម្រេចចិត្តលែងលះគ្នា ព្រោះផលប៉ះពាល់ដែលបណ្តាលមកពីការលែងលះគ្នានឹងធ្លាក់ទៅលើកូនៗរបស់យើងខ្លាំងជាងគេ។

-សូមប្តីប្រពន្ធទាំងឡាយ រៀនតាំងចិត្តថែរក្សាទំនាក់ទំនងឲ្យមានភាពរឹងមាំ ព្រោះគ្មានអ្វីដែលថា ធ្វើមិនបាននោះទេ ប្រសិនបើមានការតាំងចិត្ត ។ ការតាំងចិត្តថែរក្សា នូវទំនាក់ទំនងប្តីប្រពន្ធ តម្រូវផងដែរឲដៃគូទាំងសងខាងមានការតាំងចិត្តខ្ពស់ ទើបអាចថែរក្សា នូវទំនាក់ទំនងប្តីប្រពន្ធ ឲ្យមានភាពរឹងមាំ និងមិនអាចប្រេះឆាគ្នាបាន ។

-សូមប្តីប្រពន្ធទាំងសងខាងរៀនគិតវិជ្ជមានអំពីគ្នាទៅវិញទៅមក ព្រោះវាមិនត្រឹមតែធ្វើឱ្យយើងរស់នៅយ៉ាងមានក្តីសុខនោះទេ វាក៏ជារឿងមួយដែលមានប្រយោជន៍ជាខ្លាំងសម្រាប់ទំនាក់ទំនងប្តីប្រពន្ធ ព្រោះថា នៅពេលដែលគិត អ្វីដែលល្អៗ អំពីគ្នាវាក៏ជាវិធីសាស្ត្រមួយ ដែលធ្វើឲ្យមនុស្សពីរនាក់ បង្កើននូវការទុកចិត្តគ្នា លើសពីនេះវាក៏ជួយឱ្យទំនាក់ទំនង រវាងប្តីប្រពន្ធរបស់មនុស្សពីរនាក់ជៀសផុតពីការឈ្លោះប្រកែកគ្នា។

-សូមប្តីប្រពន្ធចេះប្រើពាក្យ សុំទោស ដាក់គ្នា នៅពេលដែលធ្វើខុស។ ពិតណាស់ក្នុងការរក្សាជីវិតគូ ឱ្យមានសុភមង្គល គឺតម្រូវឱ្យមនុស្សពីរនាក់ ចេះប្រើនូវពាក្យសុំទោសនៅពេលដែលធ្វើខុស លើសពីនេះរៀនធ្វើជាចាញ់និងមិនចង់ឈ្នះគ្នា នោះហើយដែលជាវិធីមួយដែលអាចជួយឲ្យបញ្ហា របស់ប្តីប្រពន្ធកាន់តែមានភាពធូរស្រាល ពីបញ្ហាដែលបានកើតឡើងនោះ។

-សូមប្តីប្រពន្ធចេះជួយកែតម្រូវគ្នាទៅវិញទៅមក ព្រោះមនុស្សយើងកើតមក មិនមាននរណាម្នាក់ថា មិនចេះធ្វើខុសនោះទេ ដូច្នេះហើយ ជីវិតជាប្តីប្រពន្ធ ក៏រមែងតែង មានការធ្វើខុស ចំពោះគ្នាដោយមិនដឹងខ្លួនអញ្ចឹងហើយ វាក៏តម្រូវឱ្យមនុស្សពីរនាក់ មានការកែតម្រូវឲ្យគ្នា ទៅវិញទៅមក នូវចំណុចណាមួយដែលខ្វះខាត លើសពីនេះការធ្វើបែបនេះវាក៏ធ្វើឱ្យទំនាក់ទំនងប្តីប្រពន្ធ របស់មនុស្សពីរនាក់ កាន់តែមានភាពស្និទ្ធស្នាលនិងកាន់តែយល់ចិត្តគ្នាទៀតផង។

-សូមប្តីប្រពន្ធគ្រប់គូព្យាយាមមើលពីបញ្ហាគ្នាទៅវិញទៅមក ព្រោះគូស្នេហ៍ដែលរស់នៅជាមួយគ្នាយ៉ាងមានសុភមង្គលនោះ គឺពួកគេតែងតែព្យាយាមយល់នូវបញ្ហាដែលបានកើតឡើង ចំពោះជីវិតប្តីប្រពន្ធរបស់ពួកគេ។ ជាងនេះទៅទៀត ពួកគេមិនមែនខឹងគ្នា ឬបន្ទោសគ្នាទៅវិញទៅមកនោះទេគឺពួកគេ តែង

តែ ចំណាយពេលវេលា ដើម្បីពិភាក្សានិងរកដំណោះស្រាយជាមួយគ្នា ដូច្នេះហើយមិនថាបញ្ហាតូចឬធំខ្លាំងប៉ុណ្ណានោះទេ ក៏មិនអាចបំផ្លាញ សុភមង្គលប្ដីប្រពន្ធ របស់ពួកគេបាននោះទេ។

# ឯកសារយោង

# ឯកសារយោង

## ១. ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣
- ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧
- ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦
- ច្បាប់ស្តីពីឯកពន្ធភាពចុះថ្ងៃទី ០១ កញ្ញា ឆ្នាំ ២០០៦
- ច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងឆ្នាំ ២០១០
- ច្បាប់ស្តីពីនីតិវិធីបណ្តឹងពាក់ព័ន្ធនឹងឋានៈបុគ្គលឆ្នាំ ២០១០
- ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ ១៩៨៩
- ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០០៥

## ២. សៀវភៅ

- សៀវភៅសេចក្តីពន្យល់មាត្រានីមួយៗ ក្រមរដ្ឋប្បវេណី( គន្លីទី៧)
- សៀវភៅសេចក្តីពន្យល់មាត្រានីមួយៗ ក្រមនីតិវិធីរដ្ឋប្បវេណី
- សៀវភៅ និតិបេតិកភណ្ឌ និងគ្រួសារ របស់សាស្ត្រាចារ្យ អ្នកស្រី វណ្ណធី

## ៣. វចនានុក្រម

- វចនានុក្រមសម្តេចព្រះសង្ឃរាជ ជួន ណាត
- សទ្ទានុក្រមពាក្យច្បាប់ ខ្មែរ-បារាំង-អង់គ្លេស អនុម័តនៅឆ្នាំ ២០០៧ ដោយគណៈកម្មការបណ្ឌិតសភា ទទួលបន្ទុកអនុម័តពាក្យច្បាប់ នៃទីស្តីការគណៈរដ្ឋមន្ត្រី
- វាក្យស័ព្ទច្បាប់អេឡិចត្រូនិក online terminology របស់សមាគមសាលាត្រាជូ

## ៤. វេបសាយ

- https://salatraju.com/index.php/post?p=22
- https://km.warbletoncouncil.org/causas-divorcio-5432#menu-12
- https://km.drafare.com

# ឧបសម្ព័ន្ធ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

គំរូ
ពាក្យសុំលែងលះ
គ្មានការព្រមព្រៀង

# ពាក្យបណ្តឹងលែងលះ

**ដើមចោទ** ៖ ឈ្មោះ.................... ភេទ......... អាយុ....... កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
លេខ.............. មានទីលំនៅបច្ចុប្បន្ន...........................................................។

**ចុងចម្លើយ** ៖ ឈ្មោះ.................... ភេទ......... អាយុ....... កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
លេខ.............. មានទីលំនៅបច្ចុប្បន្ន...........................................................។

**សូមគោរពចូលមក**
**ឯកឧត្តមប្រធានសាលាដំបូង**..........................

**កម្មវត្ថុ** ៖ សុំឲ្យតុលាការចេញដីកាសម្រេច មានខ្លឹមសារដូចខាងក្រោម ៖
១- ឲ្យ ដើមចោទ និងចុងចម្លើយ ផ្តាច់សម្ពន្ធសង្វាស់ តាមផ្លូវច្បាប់ ។
២-សម្រេចឲ្យ (ដើមចោទ/ចុងចម្លើយ) ជាអ្នកមានអំណាចមេបាលើកូនឈ្មោះ..........
៣-សម្រេចឲ្យ (ដើមចោទ/ចុងចម្លើយ) បង់អាហារកាតព្វកិច្ច និងអាចចូលសួរសុខទុក្ខកូនតាមច្បាប់កំណត់ ។
៤-សម្រេចឲ្យ ដើមចោទ មានសិទ្ធិលើទ្រព្យសម្បត្តិដូចខាងក្រោម៖
..........................................................................................
៥-សម្រេចឲ្យ ចុងចម្លើយ មានសិទ្ធិលើទ្រព្យសម្បត្តិដូចខាងក្រោម៖
..........................................................................................
៦-សម្រេចឲ្យ ដើមចោទ សងបំណុលដូចខាងក្រោម៖
(បើមានសូមសរសេរ)...........................................................................
៧-សម្រេចឲ្យ ចុងចម្លើយ សងបំណុលដូចខាងក្រោម៖
(បើមានសូមសរសេរ)...........................................................................

**យោង** ៖ -សំបុត្រអាពាហ៍ពិពាហ៍លេខ.......ចុះថ្ងៃទី...................... របស់........................។
-..........................................................................................

កាលពីថ្ងៃទី.....ខែ.....ឆ្នាំ..... នាងខ្ញុំ/ខ្ញុំបាទ បាចអាពាហ៍ពិពាហ៍ ជាឈ្មោះ.......................... ។ ប៉ុន្តែក្នុងកំឡុងពេលអាពាហ៍ពិពាហ៍ ឈ្មោះនេះ (សរសេរពីមូលហេតុដែលនាំឲ្យមានការទាមទារ) ..........................................................................................................................។

អាស្រ័យហេតុនេះ សូម **ឯកឧត្តមប្រធាន** មេត្តាទទួល និងសម្រេចតាមការប្តឹងសុំខាងលើដោយក្តីអនុគ្រោះ ។

សូម **ឯកឧត្តមប្រធាន** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

ធ្វើនៅ................. ថ្ងៃទី......... ខែ......... ឆ្នាំ២០១.....

ស្នាមមេដៃស្តាំចុងចម្លើយ
(ស្នាមមេដៃស្តាំ)

ស្នាមមេដៃស្តាំដើមចោទ
(ស្នាមមេដៃស្តាំ)

Scanned with CamScanner

## ប្តឹងសុំលែងលះប្តី ប្រពន្ធ

### ព្រះរាជាណាចក្រកម្ពុជា
### ជាតិ សាសនា ព្រះមហាក្សត្រ

## ពាក្យបណ្តឹង

នាងខ្ញុំឈ្មោះ..........................អាយុ..................ឆ្នាំ ជាតិ...................មុខរបរ.........................

ទីលំនៅភូមិ.........................ឃុំ......................ស្រុក........................ខេត្ត..........................។

**សូមគោរពជូន**

**លោកប្រធានតុលាការខេត្ត**..........................

**កម្មវត្ថុ** ៖ សុំប្តឹងលែងលះប្តីឈ្មោះ.........................ភេទ..........អាយុ.........ឆ្នាំ សញ្ជាតិ..............

មុខរបរ.......................។

នាងខ្ញុំសូមជំរាបជូនលោកប្រធានតុលាការដូចតទៅ ៖

នាងខ្ញុំបានរៀបអាពាហ៍ពិពាហ៍ចំនួន...........ឆ្នាំកន្លងមកហើយ ដូចមានសំបុត្រអាពាហ៍ពិពាហ៍ចុះថ្ងៃទី..........ខែ..............ឆ្នាំ.............ធ្វើនៅសង្កាត់ភ្ជាប់មកជាមួយស្រាប់ ។ សព្វថ្ងៃនេះយើងខ្ញុំមានកូនចំនួន.......នាក់ និងមានទ្រព្យសម្បត្តិមួយចំនួន ។

ដោយប្តីរបស់នាងខ្ញុំចេះតែវាយដំលើរូបកាយរបស់នាងខ្ញុំ និងជេរប្រមាថមើលងាយលើញាតិមិត្តបងប្អូនរបស់នាងខ្ញុំ ធ្វើអោយនាងខ្ញុំមិនអាចទ្រាំរស់នៅជាមួយគាត់តទៅទៀតបាន ទើបនាងខ្ញុំសំរេចចិត្តសុំលែងលះគ្នា ចាប់តាំងពីពេលនេះតទៅ ។

ហេតុនេះ សូមលោកប្រធានតុលាការមេត្តាសំរេចចំពោះរឿងនេះអោយបានដាច់ស្រឡះ តាមសំណូមពរ ៖

. សុំផ្តាច់សមគ្គសង្វាស

www.budinst.gov.kh www.elibraryofcambodia.org



. សុំកូនចំនួន......នាក់ ឈ្មោះ.................និងឈ្មោះ......................

. សុំអោយឈ្មោះ.................ផ្តល់អាហារកិច្ចដល់កូនចំនួន......នាក់

. សុំចែកទ្រព្យសម្បត្តិ..............

. ផ្សេងៗ...........

សូមលោកប្រធានមេត្តាទទួលនូវការគោរពយ៉ាងជ្រាលជ្រៅអំពីនាងខ្ញុំ ។

ភ្នំពេញ, ថ្ងៃទី.........ខែ.............ឆ្នាំ...........

**ហត្ថលេខា ឬស្នាមមេដៃស្តាំអ្នកប្តឹង**

Scanned with CamScanner

*ទម្រង់នេះធ្វើឡើងដោយផ្អែកតាមទម្រង់នៅក្នុងតុលាការគ្រួសារប្រទេសជប៉ុន និងសម្របជាមួយបញ្ញត្តិច្បាប់របស់កម្ពុជា សម្រាប់ធ្វើជាឯកសារយោង។ BAKC-JFBA Seminar, March 15, 2018 (Miha Isoi)*

(តម្លៃ ៥០០០រៀល)

# ពាក្យសុំលែងលះតាមការព្រមព្រៀង

## គោរពជូន

ប្រធានសាលាដំបូងរាជធានីភ្នំពេញ

អ្នកដាក់ពាក្យសុំ B ៖ ផ្ទះលេខ ១២ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
ភាគីម្ខាងទៀត A ៖ ផ្ទះលេខ 34 សង្កាត់ផ្សារកណ្តាល ខណ្ឌដូនពេញ រាជធានីភ្នំពេញ

ផ្នែកទី១ ដីកាសម្រេចដែលអ្នកដាក់ពាក្យសុំទាមទារ
១. ការលែងលះរវាងអ្នកដាក់ពាក្យសុំ និងភាគីម្ខាងទៀត

ផ្នែកទី២ មូលហេតុនៃការដាក់ពាក្យសុំ
១. អ្នកដាក់ពាក្យសុំបានរៀបការជាមួយភាគីម្ខាងទៀតនៅថ្ងៃទី ១៥ ខែមីនាឆ្នាំ ២០០៥ ហើយកូនស្រី C បានកើតនៅថ្ងៃទី ២ ខែមេសាឆ្នាំ ២០០៧ ដែលមានអាយុ ១០ ឆ្នាំ។

២. អ្នកដាក់ពាក្យសុំ និងភាគីម្ខាងទៀត បានរស់នៅជាមួយគ្នាអស់រយៈពេល ១២ ឆ្នាំបន្ទាប់ពីរៀបការ។ ក្រោយមក ក្នុងអំឡុងពេលប៉ុន្មានឆ្នាំថ្មីៗនេះភាគីម្ខាងទៀតជារឿយៗផឹកស្រា យកលុយទៅផឹកហើយជួនកាលថែមទាំងប្រើអំពើហឹង្សាផង។ ដូច្នេះហើយ អ្នកដាក់ពាក្យសុំបានចាកចេញពីផ្ទះរបស់ខ្លួននៅដើមខែធ្នូ ឆ្នាំ 2017 ជាមួយកូនស្រី C ទៅរស់នៅជាមួយឪពុកម្តាយវិញ។ អ្នកដាក់ពាក្យសុំ ចង់លែងលះគ្នាជាមួយភាគីម្ខាងទៀត ។

៣. ភាគីម្ខាងទៀតក៏យល់ព្រមជាមួយអ្នកដាក់ពាក្យសុំដែរ។

៤. កូនស្រី C ចង់រស់នៅជាមួយអ្នកដាក់ពាក្យសុំ ហើយភាគីម្ខាងទៀតក៏យល់ព្រមដែរ។

៥. ភាគីម្ខាងទៀត បានព្រមព្រៀងបង់ប្រាក់ ៦០០.០០០ រៀលនៅរៀងរាល់ចុងខែ ចាប់ពីខែមេសាឆ្នាំ ២០១៨ ដល់ខែមេសា ឆ្នាំ ២០២២ និង ៩០០.០០០ រៀលពីខែឧសភា ឆ្នាំ ២០២២ ដល់ខែមេសា ឆ្នាំ ២០២៥ ទៅឲ្យអ្នកដាក់ពាក្យសុំសម្រាប់ការចំណាយសម្រាប់ការចិញ្ចឹមកូនស្រី C។

៦. ភាគីម្ខាងទៀតបានយល់ព្រមបង់ប្រាក់ចំនួន ៤0 លានរៀលដល់អ្នកដាក់ពាក្យសុំ សម្រាប់ការបែងចែកទ្រព្យសម្បត្តិរួម។

ភ្នំពេញថ្ងៃទី ១៥ ខែមីនាឆ្នាំ ២០១៨

(ស្នាមមេដៃ)

អ្នកដាក់ពាក្យសុំ B

(ហត្ថលេខា និង ត្រា)

អ្នកតំណាងនៃអ្នកដាក់ពាក្យសុំ B, មេធាវី D

ការិយាល័យច្បាប់ Orange

ជាន់ទី ២៤, អគារភ្នំពេញ, លេខ ៤៤៥, មហាវិថីព្រះមនីវង្ស, ខណ្ឌ ៧ មករា, រាជធានីភ្នំពេញ,

## ឯកសារភ្ជាប់

១. សំបុត្រអាពាហ៍ពិពាហ៍

២. សំបុត្រកំណើត C

# ការលែងលះដោយគ្មានកូនៈ អ្វីដែលត្រូវធ្វើជាមួយនឹងទម្រង់បែបបទតុលាការទាំងនេះ

ប្រសិនបើអ្នកកំពុងធ្វើការលែងលះដោយខ្លួនឯង សូមអានព័ត៌មាននេះ។ វានឹងជួយអ្នកឲ្យបានដឹងពី អ្វីដែលត្រូវធ្វើជាមួយនឹងទម្រង់បែបបទតុលាការ ទាំងនេះ។ នេះគឺជារបៀបមួយចំនួនក្នុងការបំពេញ ទម្រង់បែបបទទាំងឡាយៈ

- ត្រូវប្រើឈ្មោះពេញតាមច្បាប់ជានិច្ច មិនត្រូវ ប្រើឈ្មោះហៅក្រៅនោះទេ។
- វាយកុំព្យូទ័រ ឬ បោះពុម្ពឲ្យដោយមានរបៀប។ ទម្រង់ដែលអាចបំពេញបាន គឺមាននៅក្នុង គេហទំព័រៈ http://courts.maine.gov/fees_forms/forms។
- អ្នកនឹងដាក់ទម្រង់នីមួយៗទៅតុលាការ។ មុនពេលដាក់ទៅតុលាការ សូមថតចម្លងទម្រង់ បែបបទដែលបានបំពេញរួចយ៉ាងតិចពីរច្បាប់– មួយសម្រាប់ខ្លួនឯង និងមួយទៀតសម្រាប់ សហព័ទ្ធ (ប្ដី/ប្រពន្ធ) របស់អ្នក។ អ្នកនឹងត្រូវរក កន្លែងដើម្បីថតចម្លង (ដូចជានៅបណ្ណាល័យ)។ ក្រឡាបញ្ជីតុលាការមិនអាចថតចម្លងឯកសារ ឲ្យអ្នកនោះទេ។

## ជំហានទីមួយៈ បំពេញទម្រង់បែបបទ

### ពាក្យបណ្ដឹងសុំលែងលះ

ផ្នែកដែលនៅខាងលើបំផុតនៃទម្រង់បែបបទហៅ ថា "ចំណងជើង"។ សូមបំពេញទីតាំងរបស់ តុលាការមណ្ឌល (District Court) (ឧទាហរណ៍ៈ "Bangor")។ ក្រឡាបញ្ជីនឹងបំពេញលេខសំណុំរឿង (Docket Number) ពេលក្រោយ។ អ្នកជាដើមចោទ (Plaintiff) ហើយប្ដី/ប្រពន្ធរបស់អ្នកជាចុងចោទ (Defendant)។ សូមបំពេញឈ្មោះពេញតាមច្បាប់ ក្នុងចន្លោះពីមុខពាក្យ "ដើមចោទ"។ សូមសរសេរ ឈ្មោះពេញរបស់អ្នកនៅចន្លោះដែលនៅពីមុខ ពាក្យ "ចុងចោទ"។ ប្រសិនបើអ្នក ឬប្ដី/ប្រពន្ធរបស់ អ្នកមានផ្ទះ ឬ អចលទ្រព្យ ឬដីធ្លីជាកម្មសិទ្ធិ សូម គូសប្រអប់ជាប់នឹងឃ្លា "ប្លង់/ប័ណ្ណកម្មសិទ្ធិអចលន ទ្រព្យដែលពាក់ព័ន្ធ (Title to Real Estate Involved) "។ អ្នកគួរតែគូសប្រអប់នេះ **ទោះបីជា**ប័ណ្ណកម្មសិទ្ធិ អចលនទ្រព្យដាក់ឈ្មោះភាគីតែម្ខាងក៏ដោយ។ សូមបំពេញចន្លោះផ្សេងទៀតនៅក្នុងទម្រង់បែបបទ នេះ។ នៅជិតចុងបញ្ចប់ មានពាក្យថា "សំណើ របស់ដើមចោទ..." សូមគូសប្រអប់ទាំងឡាយណា ដែលត្រូវនឹងអ្នក។ (បើសិនអ្នកមិនប្រាកដទេនោះ សូមគូសប្រអប់។ អ្នកអាចដកសំណើនោះនៅពេល ក្រោយ។)

### ដីកាកោះស្ដីពីវិវាទគ្រួសារ និងអធិបញ្ញាបឋម

អ្នកត្រូវតែប្រើដីកាកោះសំណៅដើមដែលអ្នកបាន ទទួលពីក្រឡាបញ្ជី។ ដីកានោះមានហត្ថលេខា និង ត្រាដើមរបស់ក្រឡាបញ្ជី។ អ្នកមិនអាចប្រើសំណៅ ចម្លង ឬទម្រង់នេះដែលទាញយកពីអ៊ីនធឺណិតទេ។

សូមបំពេញ "ចំណងជើង" ដូចដែលបានបំពេញនៅ លើពាក្យបណ្ដឹង។

សូមបំពេញឈ្មោះ និងអាសយដ្ឋានតុលាការ។ សូមចុះកាលបរិច្ឆេទ និងហត្ថលេខានៅលើទម្រង់ បែបបទ។ សូមទុកចន្លោះនៅទំព័រទីពីរឲ្យនៅទំនេរ។

### ទម្រង់បែបបទលាតត្រដាងលេខសន្តិសុខសង្គម

អ្នកត្រូវបានតម្រូវដោយច្បាប់រដ្ឋ និងសហព័ន្ធ ក្នុង ការផ្ដល់លេខសន្តិសុខសង្គមរបស់អ្នក។ ព័ត៌មាន នេះត្រូវបានប្រមូលពីទម្រង់បែបបទលាតត្រដាង លេខសន្តិសុខសង្គម (Social Security Number Disclosure)។ បន្ទាប់ពីបំពេញរួច ទម្រង់បែបបទ នេះនឹងត្រូវដាក់ក្នុងស្រោមសំបុត្ររក្សាការសម្ងាត់ នៅក្នុងសំណុំឯកសាររបស់តុលាការ។

## ជំហានទីពីរៈ បញ្ជូនទម្រង់បែបបទ

ពេលនេះ អ្នកត្រូវតែផ្ដល់សំណៅចម្លងនានាទៅឲ្យ ប្ដី/ប្រពន្ធរបស់អ្នក។ ការធ្វើដូច្នេះហៅថា "ការបញ្ជូន" លិខិតស្នាមរបស់តុលាការ។ វិធានតុលាការចែងថា អ្នកអាចផ្ដល់លិខិតស្នាមតាមវិធីមួយក្នុងចំណោម វិធីចំនួនបីៈ (1) អ្នកអាចផ្ដល់ ឬ ផ្ញើលិខិតស្នាមតាម ប្រៃសណីយ៍ ដោយសុំឲ្យប្ដី/ប្រពន្ធរបស់អ្នកផ្ដល់ការ យល់ព្រមចំពោះ "ការផ្ដល់ឯកសារ" ហើយប្រសិន បើប្ដី/ប្រពន្ធរបស់អ្នកយល់ព្រមនឹងការផ្ដល់ឯកសារ តាមវិធីនេះ ប្ដី/ប្រពន្ធរបស់អ្នកនឹងត្រូវចុះហត្ថលេខា លើទម្រង់លិខិតទទួលស្គាល់ការទទួលបាន (Acknowledgment of Receipt) (2) អ្នកអាចផ្ញើ ក្រដាសស្នាមតាមលិខិតអនុសិដ្ឋ (certified mail) (3) អ្នកអាចបង់ប្រាក់ឲ្យនគរបាល (sheriff) ម្នាក់ ដើម្បីប្រគល់ឯកសារច្បាប់ចម្លងឲ្យប្ដី/ប្រពន្ធរបស់ អ្នក។

**ការផ្តល់ឯកសារដោយមានលិខិតទទួលស្គាល់**
សូមផ្ញើតាមប្រៃសណីយ៍ ឬប្រគល់ដោយផ្ទាល់ដៃនូវលិខិតស្នាមទាំងអស់នេះ ទៅឲ្យប្តី/ប្រពន្ធរបស់អ្នក៖

- សំណៅចម្លងនៃពាក្យបណ្តឹង
- សំណៅចម្លងនៃដីកា និងអធិបញ្ញាបឋម
- សំណៅចម្លងពីរច្បាប់នៃលិខិតបញ្ជាក់ការទទួលបានដីកា និងពាក្យបណ្តឹង (បន្ទាប់ពីអ្នកបានបំពេញ "ចំណងជើង" នៅលើសំណៅចម្លងទាំងពីររួច)
- ស្រោមសំបុត្រដែលមានបិតតែម និងអាសយដ្ឋានអ្នកផ្ញើរួចជាស្រេច

ទម្រង់បែបបទទទួលស្គាល់ការទទួលបាន ត្រូវចុះហត្ថលេខាដោយប្តី/ប្រពន្ធរបស់អ្នក ដោយទទួលស្គាល់ថាខ្លួនពិតជាបានទទួលលិខិតស្នាមទាំងនោះ ហើយត្រូវបញ្ជូនទៅឲ្យអ្នកវិញក្នុងរយៈពេល20ថ្ងៃ។

ប្រសិនបើអ្នកទទួលបានលិខិតទទួលស្គាល់ដែលចុះហត្ថលេខារួច ក្នុងរយៈពេល 20ថ្ងៃ សូមបន្តទៅជំហានទី 3។ បើពុំដូច្នេះទេ អ្នកនឹងត្រូវបញ្ជូនលិខិតស្នាមតាមវិធីមួយក្នុងចំណោមវិធីពីរផ្សេងទៀត។

**ការផ្តល់ឯកសារតាមលិខិតអនុសិដ្ឋ**
សូមយកលិខិតស្នាមទាំងនេះទៅកាន់ប៉ុស្តិ៍ប្រៃសណីយ៍ដោយដាក់ក្នុងស្រោមសំបុត្រ៖

- សំណៅចម្លងនៃពាក្យបណ្តឹង
- សំណៅចម្លងនៃដីកា និងអធិបញ្ញាបឋម

សូមប្រាប់បុគ្គលិកប្រៃសណីយ៍ថា អ្នកចង់ផ្ញើលិខិតស្នាមតាមលិខិតអនុសិដ្ឋ។ ត្រូវប្រាកដថា អ្នកសុំ "បង្កាន់ដៃបញ្ជាក់ការទទួលបានសំបុត្រ (Return Receipt)" និង "សេវាបញ្ជូនតឹងរឹង (Restricted Delivery)"។ វិធីនេះត្រូវចំណាយច្រើនជាង ហើយពាក់ព័ន្ធនឹងជំហានពីរបីបន្ថែមទៀត។ ទម្រង់លិខិតអនុសិដ្ឋគឺមាននៅប៉ុស្តិ៍ប្រៃសណីយ៍របស់អ្នក។ សូមដាក់ប័ណ្ណពណ៌បៃតងដែលអ្នកទទួលបានវិញពីប៉ុស្តិ៍ប្រៃសណីយ៍ ឲ្យទៅក្រឡាបញ្ជីតុលាការ ដើម្បីបញ្ជាក់ថាប្តី/ប្រពន្ធរបស់អ្នកបានទទួលលិខិតស្នាមរួចហើយ។

ប្រសិនបើអ្នកមិនបានទទួលប័ណ្ណពណ៌បៃតងដែលបញ្ជាក់ពីការទទួលបានឯកសារដែលបានផ្ញើ ពីប្តី/ប្រពន្ធរបស់អ្នកទេនោះ អ្នកនឹងត្រូវស្នើនគរបាលឲ្យប្រគល់ឯកសារដល់ប្តី/ប្រពន្ធរបស់អ្នក។

**ការប្រគល់ឯកសារតាមនគរបាល**
សូមផ្ញើតាមប៉ុស្តិ៍ប្រៃសណីយ៍ ឬ នាំយកទៅការិយាល័យនគរបាលខោនធីរបស់អ្នកនូវ៖

- សំណៅចម្លងនៃពាក្យបណ្តឹង
- សំណៅដើមនៃដីកា និងអធិបញ្ញាបឋម និងសំណៅចម្លងមួយច្បាប់។

នៅក្នុងលិខិត ឬ ការជួបផ្ទាល់ សូមស្នើសុំការិយាល័យនគរបាល ឲ្យបញ្ជូនលិខិតស្នាមបន្តទៅឲ្យប្តី/ប្រពន្ធរបស់អ្នក។ សូមផ្តល់អាសយដ្ឋានផ្ទះ និង/ឬ អាសយដ្ឋានកន្លែងធ្វើការរបស់ប្តី/ប្រពន្ធរបស់អ្នក។ ភ្នាក់ងារដែល "បញ្ជូន" លិខិតស្នាមទាំងឡាយ នឹងបំពេញទំព័រទីពីរនៃដីកា ហើយប្រគល់សំណៅដើមទៅឲ្យអ្នកវិញ។ នគរបាលនឹងគិតថ្លៃសេវានេះ។

**<u>ជំហានទីបី៖ ដាក់ទម្រង់បែបបទ</u>**

បំពេញទំព័រសង្ខេបអំពីវិវាទគ្រួសារ (Family Matter Summary Sheet) ដែលក្នុងនោះមានសេចក្តីណែនាំស្រាប់។ ក្រឡាបញ្ជីនឹងមិនទទួលយកលិខិតស្នាមរបស់អ្នកដោយគ្មានទម្រង់បែបបទនេះឡើយ។

ក្នុងរយៈពេល 20ថ្ងៃ បន្ទាប់ពីបញ្ជូនឯកសារឲ្យប្តី/ប្រពន្ធរបស់អ្នក សូមប្រគល់ដោយផ្ទាល់ ឬ ផ្ញើតាមប្រៃសណីយ៍ទៅឲ្យក្រឡាបញ្ជីតុលាការនូវសំណៅដើមនៃទម្រង់បែបបទទាំងនេះ៖

- ☐ **ទំព័រសង្ខេប**
- ☐ **ពាក្យបណ្តឹង**
- ☐ **ដីកា (ត្រូវការចាំបាច់** មិនថាប្រគល់តាមវិធីណានោះទេ និងគួរតែដាក់ដោយមានហត្ថលេខារបស់ភ្នាក់ងារ **ប្រសិនបើ**អ្នកប្រើសេវារបស់នគរបាល)
- ☐ **លិខិតទទួលស្គាល់ការទទួលបាន** (ប្រសិនបើអ្នកបានប្រើសេវាផ្ញើតាមប៉ុស្តិ៍ប្រៃសណីយ៍)
- ☐ **ប័ណ្ណពណ៌បៃតង** (ប្រសិនបើអ្នកប្រើសេវាលិខិតអនុសិដ្ឋ)

តុលាការគិតថ្លៃសេវាសម្រាប់ការដាក់លិខិតស្នាមរបស់អ្នក។ បន្ទាប់មកអ្នកអាចនឹងត្រូវបានគិតថ្លៃសេវាសម្រុះសម្រួល (បែងចែករវាងគូភាគី)។ សូមពិនិត្យជាមួយក្រឡាបញ្ជីតុលាការដើម្បីឲ្យដឹងពីចំនួនជាក់លាក់។ ប្រសិនបើអ្នកមិនមានលទ្ធភាពបង់ប្រាក់ប្រដាប់ក្តី អ្នកអាចសុំពីក្រឡាបញ្ជីនូវពាក្យសុំដំណើរការនីតិវិធីដោយពុំចាំបាច់បង់ប្រាក់ និងសេចក្តីអះអាងពីភាពខ្វះខាត (Application to Proceed Without Payment of Fees and Indigency Affidavit)។ បំពេញទម្រង់បែបបទទាំងនេះ ហើយចុះហត្ថលេខានៅចំពោះមុខសាការីសាធារណៈ។ បន្ទាប់មកដាក់ទម្រង់ទាំងនោះនៅក្រឡាបញ្ជី ព្រមជាមួយនឹងលិខិតស្នាមផ្សេងៗទៀត

របស់អ្នក។ ចៅក្រមម្នាក់នឹងពិនិត្យព័ត៌មានហិរញ្ញវត្ថុរបស់អ្នក ហើយសម្រេចថាតើអ្នកត្រូវនឹងលក្ខខណ្ឌដើម្បីទទួល "ការលើកលែងការបង់ប្រាក់" ដែរឬទេ។ ប្រសិនបើការលើកលែងត្រូវបានបដិសេធ អ្នកត្រូវតែបង់ថ្លៃដាក់ឯកសារក្នុងរយៈពេល 7ថ្ងៃ។ បើសិនអ្នកទទួលបានការលើកលែងអ្នកនឹងមិនចាំបាច់បង់ប្រាក់មួយចំនួន ឬទាំងអស់នោះទេ។

**របាយការណ៍ហិរញ្ញវត្ថុ៖** អ្នកត្រូវតែដាក់របាយការណ៍ហិរញ្ញវត្ថុ (Financial Statement) ប្រសិនបើអ្នក និងប្តី/ប្រពន្ធរបស់អ្នកមិនយល់ស្របចំពោះរបៀបបែងចែកទ្រព្យសម្បត្តិរបស់អ្នក ប្រាក់ឧបត្ថម្ភសហព័ទ្ធ (សោធនអាហារកិច្ច) ឬ ថ្លៃសេវាមេធាវី។ ទម្រង់បែបបទនេះគឺមាននៅលើគេហទំព័ររបស់ផ្នែកយុត្តិធម៌ (Judicial Branch) តាមរយៈ៖ http://courts.maine.gov/fees_forms/forms/index.shtml ឬ មាននៅការិយាល័យរបស់ក្រឡាបញ្ជីតុលាការមណ្ឌលណាមួយ។ បន្ទាប់ពីអ្នកបំពេញវារួច សូមដាក់សំណៅដើមទៅក្រឡាបញ្ជី និងផ្ញើសំណៅចម្លងទៅប្តី/ប្រពន្ធរបស់អ្នក។ អ្នកត្រូវតែធ្វើដូច្នេះតាមកាលបរិច្ឆេទដែលបញ្ជាក់នៅក្នុងសេចក្តីបង្គាប់ពីការកំណត់ពេល (Scheduling Order) (សូមមើលជំហានទីបួន)។ ប្តី/ប្រពន្ធរបស់អ្នកក៏ត្រូវតែដាក់ទម្រង់មួយក្នុងចំណោមទម្រង់ទាំងនេះ និងផ្តល់សំណៅចម្លងមួយច្បាប់ដល់អ្នក។

**លិខិតបញ្ជាក់ជំនួសឲ្យរបាយការណ៍ហិរញ្ញវត្ថុ៖** ប្រសិនបើមិនមានវិវាទអំពីទ្រព្យសម្បត្តិផ្ទាល់ខ្លួន អចលនទ្រព្យ ប្រាក់ឧបត្ថម្ភប្តី/ប្រពន្ធ ឬ ថ្លៃមេធាវីទេនោះ អ្នកគួរតែដាក់លិខិតបញ្ជាក់ជំនួសឲ្យរបាយការណ៍ហិរញ្ញវត្ថុ (Certificate in Lieu of Financial Statement)។ ទម្រង់បែបបទនេះមាននៅលើគេហទំព័រ៖ http://courts.maine.gov/fees_forms/forms/index.shtml ឬ មាននៅការិយាល័យរបស់ក្រឡាបញ្ជីតុលាការមណ្ឌលណាមួយ។បន្ទាប់ពីអ្នកបំពេញវារួច សូមដាក់សំណៅដើមទៅក្រឡាបញ្ជី និងសំណៅចម្លងទៅប្តី/ប្រពន្ធរបស់អ្នក។

**ជំហានទីបួន៖ កំណត់ពេល**

បន្ទាប់ពីប្តី/ប្រពន្ធរបស់អ្នកដាក់ពាក្យផ្តល់ចម្លើយការឆ្លើយតប ឬ ចូលមកបង្ហាញខ្លួន តុលាការនឹងចេញសេចក្តីបង្គាប់កំណត់ពេលដែលកំណត់ពីកាលបរិច្ឆេទសម្រាប់ដាក់ឯកសារនានា និងបញ្ចប់បញ្ហាមុនការជំនុំជំរះផ្សេងៗទៀត។ អ្នកនឹងទទួលបានសំណៅចម្លងនៃសេចក្តីបង្គាប់មួយច្បាប់ តាមប៉ុស្តិ៍ប្រៃសណីយ៍។ ការសម្រុះសម្រួលនឹងត្រូវបានកំណត់ពេល ហើយអ្នកនឹងត្រូវបានតម្រូវឲ្យបង់ថ្លៃសេវាសម្រុះសម្រួល ឬ ដាក់សំណើសុំការលើកលែងថ្លៃសេវានេះ។ ការប្រជុំអំពីការគ្រប់គ្រងការជំនុំជម្រះមួយនឹងត្រូវបានកំណត់ពេលបន្ទាប់ពីកាលបរិច្ឆេទនៃការសម្រុះសម្រួល។ (សូមមើលជំហានទីប្រាំ និងទីប្រាំមួយ)។

បើសិនប្តី/ប្រពន្ធរបស់អ្នកមិនដាក់ពាក្យផ្តល់ចម្លើយការឆ្លើយតប ឬ ចូលមកបង្ហាញខ្លួនទេ ក្រឡាបញ្ជីនឹងកំណត់ពេលសំណុំរឿងរបស់អ្នកសម្រាប់សវនាការគ្មានការជំទាស់ (uncontested hearing)។ (សូមមើលជំហានទីប្រាំមួយ)

ប្រសិនបើអ្នក និងប្តី/ប្រពន្ធរបស់អ្នកឈានដល់ការព្រមព្រៀងគ្នា អ្នកអាចស្នើសុំឲ្យមានការកំណត់ពេលសវនាការគ្មានការជំទាស់ តាមរយៈការបញ្ជូនលិខិតសំណើទៅកាន់ក្រឡាបញ្ជី។

**ជំហានទីប្រាំ៖ ការសម្រុះសម្រួល**

ប្រសិនបើអ្នក និងប្តី/ប្រពន្ធរបស់អ្នកមិនព្រមព្រៀងលើបញ្ហាទាំងអស់ទេ ជំហានបន្ទាប់របស់អ្នកគឺការសម្រុះសម្រួល។ អ្នកនឹងត្រូវបានតម្រូវឲ្យបង់ថ្លៃសេវាសម្រុះសម្រួល ហើយជាទូទៅត្រូវបែងចែករវាងអ្នក និងប្តី/ប្រពន្ធរបស់អ្នក។ ប្រសិនបើអ្នកមិនមានលទ្ធភាពបង់ថ្លៃសេវានេះ អ្នកអាចដាក់សំណើសុំលើកលែងបង់ថ្លៃសេវានេះ។ ទម្រង់សំណើសុំនេះគឺមាននៅក្រឡាបញ្ជីតុលាការ។

នៅក្នុងការសម្រុះសម្រួល អ្នកសម្រុះសម្រួលដែលបានទទួលការបណ្តុះបណ្តាលម្នាក់នឹងព្យាយាមជួយអ្នកទាំងពីរឲ្យយល់ពីចំណុចណាដែលអ្នកព្រម និងចំណុចណាដែលអ្នកមិនព្រម។ អ្នកត្រូវតែធ្វើការសម្រុះសម្រួលដោយសុចរិត។ នេះមានន័យថាអ្នកត្រូវតែចូលរួម និងខិតខំព្យាយាមដោយស្មោះត្រង់ក្នុងការដោះស្រាយបញ្ហានៃការខ្វែងគំនិតគ្នា។ ប្រសិនបើបញ្ហានៅតែមិនអាចដោះស្រាយបាន បន្ទាប់ពីការសម្រុះសម្រួល អ្នកអាចយល់ព្រមធ្វើការសម្រុះសម្រួលលើកទីពីរ ឬ ដោះស្រាយតាមសវនាការរបស់តុលាការ។

**ជំហានទីប្រាំមួយ៖ ការប្រជុំមុនការជំនុំជម្រះ និងសវនាការតុលាការ**

ប្រសិនបើអ្នក និងប្តី/ប្រពន្ធរបស់អ្នកមិនអាចឈានដល់ការព្រមព្រៀងគ្នាតាមការសម្រុះសម្រួលនោះទេ អ្នកនឹងត្រូវមានការប្រជុំអំពីគ្រប់គ្រងការជំនុំជម្រះ/ការប្រជុំមុនការជំនុំជម្រះ (Trial

Management/Pretrial Conference) ដើម្បីកំណត់ថាតើតុលាការត្រូវការពេលវេលាប៉ុន្មានដើម្បីធ្វើសវនការរឿងក្តីរបស់អ្នក។

ប្រសិនបើប្តី/ប្រពន្ធរបស់អ្នកមិនបានដាក់ពាក្យផ្តល់ចម្លើយតបចំពោះពាក្យបណ្តឹងរបស់អ្នក ឬអ្នកយល់ព្រមធ្វើការសម្រុះសម្រួល អ្នកអាចនឹងត្រូវបានកំណត់ពេលសម្រាប់ "សវនាការគ្មានការជំទាស់"។ សវនាការនេះ ត្រូវរៀបចំយ៉ាងយោចណាស់ 60 ថ្ងៃបន្ទាប់ពីប្តី/ប្រពន្ធរបស់អ្នកទទួលបានពាក្យបណ្តឹងសុំលែងលះ។ អ្នកត្រូវតែបំពេញទម្រង់បែបបទបញ្ជាក់អះអាងសហព័ន្ធ (Federal Affidavit) (អាចស្នើសុំបានពីក្រឡាបញ្ជី) និងដាក់ទម្រង់នោះនៅក្រឡាបញ្ជី។ ចៅក្រមនឹងមិនបើកសវនាការសំណុំរឿងរបស់អ្នកនោះទេ រហូតទាល់តែអ្នកដាក់សេចក្តីបញ្ជាក់អះអាងនេះ។ អ្នកត្រូវតែចុះហត្ថលេខាលើសេចក្តីបញ្ជាក់អះអាងនេះនៅចំពោះមុខសាការីសាធារណៈ។ នៅពេលសំណុំរឿងត្រូវបានកំណត់ពេលសម្រាប់សវនាការរួច សូមត្រៀមខ្លួនផ្តល់សក្ខីកម្ម និងផ្តល់ភស្តុតាងដើម្បីគាំទ្រជំហររបស់អ្នក។ បន្ទាប់ពីបើកសវនការសំណុំរឿងរបស់អ្នក ចៅក្រមនឹងសម្រេចពីលក្ខខណ្ឌនៃការលែងលះរបស់អ្នក។

## ប្រភពជំនួយនានា

**វីដេអូ៖** តុលាការភាគច្រើនមានវីដេអូដែលពន្យល់ពីដំណើរការតុលាការ ព្រមទាំងសិទ្ធិ និងទំនួលខុសត្រូវរបស់អ្នក។ ប្រសិនបើអ្នកចង់ទស្សនាវីដេអូនេះ សូមទាក់ទងក្រឡាបញ្ជី។

**ការសម្រុះសម្រួល៖** អ្នកសម្រុះសម្រួលអាចនឹងជួយអ្នក និងភាគីម្ខាងទៀតឲ្យឈានដល់ការព្រមព្រៀងគ្នាលើបញ្ហានានាទាក់ទងនឹងរឿងក្តីរបស់អ្នក។ តុលាការមានវីដេអូមួយដែលពន្យល់ថាអ្វីទៅដែលថាការសម្រុះសម្រួល។ ការសម្រុះសម្រួលអាចត្រូវបានរៀបចំឡើងតាមរយៈតុលាការ ឬ អ្នកសម្រុះសម្រួលឯកជន។

សម្រាប់ព័ត៌មានបន្ថែមអំពីប្រភពទាំងនេះ សូមទៅជួបក្រឡាបញ្ជីតុលាការ ឬ ចូលកាន់គេហទំព័រផ្នែកយុត្តិធម៌របស់រដ្ឋMaine ដែលមានអាសយដ្ឋាន៖ http://courts.maine.gov ។

# ការលែងលះ និង នីតិវិធីនៃការលែងលះ

ថ្ងៃទី១៥ ខែមិនា ឆ្នាំ២០១៨
Japan Federal Bar Associations
មេធាវី YOSHISAWA TOSHIYUKI

## I ដំណើរការនៅពេលទទួលរឿងក្ដីលែងលះ និង ចំណុចត្រូវប្រុងប្រយ័ត្ន

１．ការត្រៀមមុនពេលផ្ដល់ប្រឹក្សាផ្ទាល់

ដើម្បីក្ដាប់បានច្បាស់លាស់នូវទំនាក់ទំនងអង្គហេតុ និង ឆន្ទៈរបស់អ្នកទទួលប្រឹក្សា យើងត្រូវឲ្យអ្នកមកប្រឹក្សារៀបចំជាមុនដូចខាងក្រោម៖

❶ គំនូសបង្ហាញទំនាក់ទំនងគ្រួសារ（សរសេរដូចជា អាយុ និង ការងារ រស់នៅជាមួយគ្នា ឬ រស់នៅបែកគ្នា ជាដើម） ※សៀវភៅគ្រួសារ ជាអាទិ៍

❷ តារាងពេលវេលាធម្មតាៗ（ដំណើររឿងរហូតដល់ពេលលែងលះ→អង្គហេតុសម្រាលកូន ជាអាទិ៍→ដំណើររឿងដែលនាំឲ្យមានជម្លោះរវាងប្ដីប្រពន្ធ ជាអាទិ៍）

❸ ឯកសាផ្សេងៗដែលអាចដឹងអំពីដំណើររឿងមុននឹងឈានដល់ការពិភាក្សានេះ ដូចជា សំបុត្រ និង អ៊ីម៉ែល រូបថត និង ការថតសម្លេងជាដើម ※អាចជាភស្តុតាងនៅពេលលែងលះដោយការព្រមព្រៀង និង លែងលះដោយតុលាការ

❹ ក្រៅពីនេះ គម្រោងអំពីហេតុផលនៃការទាមទារឲ្យលែងលះ និងលក្ខខណ្ឌនៃការលែងលះដែលចង់បានជាដើម។

## 2. ចំណុចត្រូវប្រុងប្រយ័ត្នជាទូទៅនៅពេលប្រឹក្សាជាមួយអ្នកមកប្រឹក្សា

❶ សាកសួរទំនាក់ទំនងអង្គហេតុ ដោយផ្តោតលើចំណុចដូចជា មាន ឬ គ្មានមូលហេតុនៃការលែងលះ（ទំនាក់ទំនងអង្គហេតុដែលត្រូវនឹងក្រមរដ្ឋប្បវេណីមាត្រា៩៧៨ កថាខណ្ឌទី១ ចំណុច ក～ង）កត្តាដែលត្រូវពិចារណាលើការបែងចែកទ្រព្យសម្បត្តិ（ក្រមរដ្ឋប្បវេណី (ហៅថា «CC»)មាត្រា៩៨០ កថាខណ្ឌទី២ ចំណុច ខ និង កថាខណ្ឌទី៣）អំណាចមេបា（CC ចាប់ពីមាត្រា ១០៣៧）ជាដើម។

❷ ពិចារណាលើស្មេរភាពនៃអារម្មណ៍របស់អ្នកមកប្រឹក្សា។

មានករណីខ្លះអ្នកមកប្រឹក្សាអាចមានអារម្មណ៍តានតឹងខ្លាំង ហេតុនេះ យើងត្រូវព្យាយាមបង្កើតការជឿទុកចិត្តជាមួយអ្នកមកប្រឹក្សា ហើយសាកសួព័តមាន។

❸ ពិចារណាលើរឿងឯកជនរបស់អ្នកមកប្រឹក្សា។

## ៣. សាកសួរអំពីលក្ខខណ្ឌ និង គោលបំណងក្នុងករណីលែងលះ

សាកសួរជាមុនអំពី ស្ថានភាពនៃទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធម្នាក់ៗ ចំណូលទាំងសងខាង ស្ថានភាពនៃការចំណាយលើសោហ៊ុយអាពាហ៍ពិពាហ៍ និងស្ថានភាពកូន ជាអាទិ៍។

លើសពីនេះ យើងត្រូវសាកសួរអំពីការបែងចែកទ្រព្យសម្បត្តិ និង សំណងជម្ងឺចិត្តជាអាទិ៍ដែលអ្នកមកប្រឹក្សាចង់បាន អំណាចមេបាលើកូន (=សិទ្ធិបីបាច់រក្សាលើរាងកាយ + សិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិ) សិទ្ធិចូលជួប និង ប្រាស្រ័យទាក់ទងក្នុងករណីដែលគ្មានបំណងរស់នៅជាមួយកូន និងគោលបំណងទាមទារសោហ៊ុយចិញ្ចឹមបីបាច់កូន (សោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន) ក្នុងករណីរស់នៅជាមួយកូន ជាអាទិ៍។

## II ឧទាហរណ៍ជាក់ស្តែង អង្គហេតុជាមុន

១. ខ្លឹមសារសំខាន់នៃសម្តីរបស់ស្ត្រី B ដែលជាកូនក្តី

ប្តី A (អាយុ ៣៥ឆ្នាំ) ធ្វើការជាមន្ត្រីរាជការរយៈពេល ១៥ឆ្នាំហើយ។ ប្រពន្ធ B គ្មានការងារ បានរៀបការកាលពី ១២ឆ្នាំមុន និង រស់នៅភ្នំពេញតាំងពីដើមមក។ ពួកគេទាំង ២ មានកូនស្រី C អាយុ ១០ កំពុងរៀននៅសាលាបឋម។

A មានទំលាប់ចាយវាយខ្ជះខ្ជាយខ្លាំង ហើយចូលចិត្តផឹកស្រា នៅពេលថ្មីៗនេះ គាត់ញៀននឹងជាតិអាកុល ហើយរាល់ថ្ងៃត្រឡប់មកផ្ទះស្រវឹងជោគជាំ។ លើសពីនេះ ចាប់ពីប្រហែល ១ឆ្នាំមុន ពេលផឹកស្រានៅផ្ទះ គាត់បានប្រើអំពើហិង្សាលើ B។ ទាំង C ក៏មានការភ័យខ្លាចនឹងទង្វើរបស់ A ដែរ ។ B មិនអាចទ្រាំបាន ក៏បាននាំ C ត្រឡប់ទៅផ្ទះនៅទីក្រុងភ្នំពេញកាលពី ៣ខែមុន។ ម៉្យាងទៀត ឪពុកម្ដាយរបស់ B មិនសូវធូធារ ហើយមិនអាចទ្រទ្រង់ជីវភាពរបស់ B និង C បានទេ។ នៅក្នុងអំឡុងពេលរួមជីវភាពអាពាហ៍ពិពាហ៍ជាមួយ A B បានខំប្រឹងចាត់ចែងការចំណាយក្នុងផ្ទះ និង មើលថែកូន C ដើម្បីឲ្យប្ដី A អាចផ្ដោតតែលើការងារបាន។

## 2. ចំណុចដែលសាកសួរពី B និង គោលបំណងរបស់ B

❶ ចង់លែងលះជាមួយ A។

❷ គាត់មិនដែលនិយាយអំពីការលែងលះជាមួយ A ទេ។

→យើងមិនច្បាស់អំពីគំនិតរបស់ A។

❸ ទ្រព្យរួមរបស់ A និង B ព្រមទាំងស្ថានភាពចំណូលរបស់ម្នាក់ៗ ជាអាទិ៍

A ជាមន្ត្រីរាជការ មានប្រាក់ខែចំនួន ៣លាន រៀល។ ពួកគេមានប្រាក់សន្សំក្នុងគណនីចំនួន ៨០ លានរៀល ដែលជាទ្រព្យទទួលបានពីប្រាក់ខែក្នុងអំឡុងពេលអាពាហ៍ពិពាហ៍នៅធនាគារ X។ ប៉ុន្តែ ផ្ទះដែលរស់នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ជាផ្ទះជួល។

B គ្មានទ្រព្យដោយឡែកដូចជា ប្រាក់សន្សំក្នុងគណនី ឬ អចលនវត្ថុអ្វីនោះទេ ក្រៅពីរបស់ប្រើប្រាស់ប្រចាំថ្ងៃបន្តិចបន្តួច។

❹ B បានរួមចំណែកកាត់បន្ថយការចំណាយក្នុងផ្ទះ និងថែរក្សាទ្រព្យរួម ហើយយើងមិនច្បាស់ថានៅពេលអនាគត គាត់អាចធ្វើការបាននោះទេ (សូមយោងក្រមរដ្ឋប្បវេណីមាត្រា៩៨០ កថាខណ្ឌទី២ ចំណុចខ និង ការថាខណ្ឌទី៣)។

❺ ចង់បានអំណាចមេបាចំពោះ C (សិទ្ធិបីបាច់រក្សាលើរាងកាយ + សិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិ)។

❻ C ក៏ចង់រស់នៅជាមួយម្ដាយ B ដែរ។

❼ ចង់ទទួលបានការបង់សោហ៊ុយចិញ្ចឹមបីបាច់កូនC ពី A។

❽ គាត់បានទទួលរងការឈឺចាប់ដោយសារការលែងលះ ហេតុនេះ គាត់ចង់ទាមទារសំណងជម្ងឺចិត្តចំពោះ A ដែលធ្វើឲ្យមានមូលហេតុនៃការលែងលះ។

## 3. ការចចារជាមួយភាគីម្ខាងទៀត A

1. ជូនដំណឹងទៅ A អំពីការទទួលបានអណត្តិពី B និងក្លាយជាអ្នកតំណាងឲ្យB ព្រមទាំងការចចារទាក់ទងនឹងការលែងលះ ក្នុងនាមជាមេធាវីតំណាងឲ្យ B។

2. ចំណុចត្រូវចចារ

❶ បញ្ជាក់ឆន្ទៈរបស់ A អំពីការលែងលះ

* ករណីយល់ព្រមលែងលះ → ដាក់ពាក្យសុំលែងលះដោយការព្រមព្រៀង។
* ករណីមិនយល់ព្រមលែងលះ → ដាក់ពាក្យបណ្ដឹងលែងលះដោយតុលាការ។

❷ ចចារអំពីការបែងចែកទ្រព្យសម្បត្តិ (ករណីដែល A យល់ព្រមលែងលះ)

＊ក្រៅពីទ្រព្យរួម ៥0% យើងត្រូវចចារដោយពិចារណាលើ「ស្ថានភាពផ្សេងៗ」 ដូចជា ទំហំនៃការបរិច្ចាគដើម្បីលទ្ធកម្ម និង ថែរក្សាទ្រព្យរួម អំឡុងពេលអាពាហ៍ពិពាហ៍ និង ផលប្រយោជន៍របស់កូន ជាអាទិ៍។

❸ ចចារអំពីសិទ្ធិអំណាចមេបាចំពោះ C និង សោហ៊ុយចិញ្ចឹមបីបាច់កូន ព្រមទាំងការបង់ប្រាក់សំណងជម្ងឺចិត្ត

(ករណីដែល A យល់ព្រមលែងលះ)

## Ⅲ ការដាក់ពាក្យសុំលែងលះ (លែងលះដោយការព្រមព្រៀង)

※ករណីដែល A យល់ព្រមលែងលះ

**【យោង】 បញ្ញត្តិនៃក្រមរដ្ឋប្បវេណី និង ច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងទាក់ទងនឹងការលែងលះដោយការព្រមព្រៀង** (ហៅថា «NSCC»)

❶ CC មាត្រា៩៧៩ ការលែងលះដោយការព្រមព្រៀង

NSCC មាត្រា៣ កថាខណ្ឌទី១ តារាងឧបសម្ព័ន្ធ (ហៅថា «ឧប.») ផ្នែកទី៤ ចំណុចទី៥ ការលែងលះដោយការព្រមព្រៀង

❷ CC មាត្រា៩៧១ ចំណែកបន្ទុកនៃសោហ៊ុយអាពាហ៍ពិពាហ៍

NSCC មាត្រា៣ កថាខណ្ឌទី១ ឧប.ផ្នែកទី៤ ចំណុចទី២ ការចាត់ចែងទាក់ទងនឹងចំណែកបន្ទុកនៃសោហ៊ុយដែលកើតឡើងពីអាពាហ៍ពិពាហ៍ដោយយោងតាមបញ្ញត្តិនៃចំណែកបន្ទុកនៃសោហ៊ុយអាពាហ៍ពិពាហ៍

❸ CC មាត្រា៩៨០ ការបែងចែកទ្រព្យសម្បត្តិ

NSCCមាត្រា៣ កថាខណ្ឌទី១ ឧប. ផ្នែកទី៤ ចំណុចទី៦ ការបែងចែកទ្រព្យសម្បត្តិ

❹ CC មាត្រា១០៣៧ ការសម្រេចអំពីអ្នកមានអំណាចមេបា នៅពេលលែងលះគ្នា

❺ CC មាត្រា១០៤០ សិទ្ធិ និង ករណីយកិច្ចរបស់ឪពុកម្តាយដែលមិនរស់នៅជាមួយកូន

NSCC មាត្រា៣ កថាខណ្ឌទី១ ឧប. ផ្នែកទី៤ ចំណុចទី១៣ ការសម្រេចសេចក្តីអំពីរបៀបចូលជួបនិងប្រាស្រ័យទាក់ទង និងចំណែកបន្ទុកនៃសោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន

❻ CC មាត្រា១០៤១ សិទ្ធិទាមទារឲ្យរាយការណ៍អំពីស្ថានភាពរបស់កូន

NSCC មាត្រា៣ កថាខណ្ឌទី១ ឧប. ផ្នែកទី៤ ចំណុចទី១៤ សិទ្ធិទាមទារឲ្យរាយការណ៍អំពីស្ថានភាពរបស់កូន

## 1. ចំណុចដែលត្រូវសរសេរក្នុងពាក្យសុំក្នុងនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ជាអាទិ៍

(NSCC មាត្រា២៦ កថាខណ្ឌទី២~៤)

① ឈ្មោះ ឬ នាមករណ៍ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ និង ឈ្មោះ និង អាស័យដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់

② ខ្លឹមសារនៃដីកាសម្រេច ឬ សកម្មភាពផ្សេងទៀតរបស់តុលាការដែលអ្នកដាក់ពាក្យសុំទាមទារ និង

អង្គហេតុដែលជាមូលហេតុនៃការទាមទារនោះ

※「អង្គហេតុដែលជាមូលហេតុនៃការទាមទារ」គឺជាការអះអាងអង្គហេតុដែលជាមូលហេតុគាំទ្រដល់ខ្លឹមសារនៃដីកាសម្រេចដែលអ្នកដាក់ពាក្យសុំទាមទារ។

※ ក្រៅពីនេះ ត្រូវដាក់ឯកសារភស្តុតាង (មាត្រា២៦ កថាខណ្ឌទី៤)។

## 2. ពាក្យសុំលែងលះដោយការព្រមព្រៀង

(ក្រមរដ្ឋប្បវេណីមាត្រា៩៧៩ NSCC មាត្រា៣ កថាខណ្ឌទី១ ឧប. ផ្នែកទី៤ ចំណុចទី៥)

1. ខ្លឹមសារនៃដីកាសម្រេចដែលអ្នកដាក់ពាក្យសុំទាមទារ
   ទាមទារដីកាសម្រេច
   បង្គាប់ឲ្យអ្នកដាក់ពាក្យសុំលែងលះជាមួយភាគីម្ខាងទៀត
2. អង្គហេតុដែលជាមូលហេតុនៃការទាមទារ
   * អង្គហេតុដែលជាអត្ថិភាពនៃការព្រមព្រៀងអំពីការលែងលះរវាង A និង B។

## 3. ពាក្យសុំបែកចែកទ្រព្យសម្បត្តិ ※ករណីដែលប្តីប្រពន្ធមិនអាចពិភាក្សាគ្នាបាន ជាអាទិ៍

(CC មាត្រា៩៨០ NSCC មាត្រា៣ កថាខណ្ឌទី១ ឧប. ផ្នែកទី៤ ចំណុចទី៦)

1 . ខ្លឹមសារនៃដីកាសម្រេចដែលអ្នកដាក់ពាក្យសុំទាមទារ

ទាមទារដីកាសម្រេច បង្គាប់ឲ្យភាគីម្ខាងទៀតបង់ប្រាក់ចំនួន ៥០លាន រៀល ដែលជាទ្រព្យរួមទៅឲ្យអ្នកដាក់ពាក្យសុំ។

2. អង្គហេតុដែលជាមូលហេតុនៃការទាមទារ

* ការបរិច្ចាគរបស់ B ដើម្បីលទ្ធកម្ម និង ថែរក្សាទ្រព្យរួមមានទំហំធំ។
* អំឡុងពេលអាពាហ៍ពិពាហ៍មានរយៈពេលវែងដល់ ១២ឆ្នាំ។
* B គ្មានការងារ ហើយមានភាពលំបាកក្នុងការរកការងារ ក្រោយពេលលែងលះ។
* មូលហេតុនៃការលែងលះបណ្តាលមកពីការប្រើហិង្សារបស់ A ចំពោះ B ជាអាទិ៍(ចំណែកដែលជាសំណងជម្ងឺចិត្ត)។

※សរសេរអំពី កម្រិតបរិច្ចាគរបស់ B សម្រាប់ធ្វើលទ្ធកម្ម ថែរក្សា និង បង្កើនទ្រព្យរួម រយៈពេលអាពាហ៍ពិពាហ៍  និង កម្រិតជីវិភាពក្នុងអឡុងពេលអាពាហ៍ពិពាហ៍ អាយុ និង លទ្ធភាពធ្វើការក្រោយពេលលែងលះជាដើម ក្រៅពីនេះ ខ្លឹមសារ និង ទំហំនៃការងារផ្ទះរបស់ B (CC មាត្រា៩៨០ កថាខណ្ឌទី៣) ព្រមទាំងព័តមានទាំងអស់ដែលអាចជាប្រយោជន៍សម្រាប់ B។

## 4. ពាក្យសុំទាមទារចំណែកបន្ទុកចំណាយលើការគ្រប់គ្រងថែរក្សាកូន

※ករណីដែលប្តីប្រពន្ធមិនអាចពិភាក្សាគ្នាបាន ជាអាទិ៍

（CC មាត្រា១០៤០ កថាខណ្ឌទី១ NSCCមាត្រា៣ កថាខណ្ឌទី១ ឧប.ផ្នែកទី៤ ចំណុចទី១៣）

1． ខ្លឹមសារនៃដីកាសម្រេចដែលអ្នកដាក់ពាក្យសុំទាមទារ

ទាមទារដីកាសម្រេច បង្គាប់ឲ្យភាគីម្ខាងទៀតបង់ប្រាក់ចំនួន ១លាន រៀល រៀងរាល់ថ្ងៃចុងខែ ដែលជាថ្លៃចិញ្ចឹមបីបាច់កូន ចាប់ពីថ្ងៃទីXX ខែXX ឆ្នាំ២០XX ដល់ថ្ងៃទីXX ខែXX ឆ្នាំ២០XX។

2. អង្គហេតុដែលជាមូលហេតុនៃការទាមទារ

＊A ធ្វើជាមន្ត្រីរាជការ និងមានប្រាក់ខែ ៣លាន រៀល។

＊B គ្មានការងារ និង គ្មានប្រាក់ចំណូល ហើយមានភាពលំបាកក្នុងការរកការងារនាពេលអនាគត ហើយឪពុកម្តាយរបស់ B ដែល B ត្រូវចាប់ផ្តើមរស់នៅជាមួយក៏មានជីវភាពលំបាក ។

※សរសេរអំពីលទ្ធភាពធ្វើការរបស់ B ក្រោយពេលដែល B លែងលះ ក្រៅពីចំណូលរបស់ A ។

## Ⅳ ការដាក់ពាក្យបណ្ដឹងលែងលះ (ការលែងលះដោយតុលាការ)

※ ករណីដែល A មិនព្រមលែងលះ

【យោង】 បញ្ញត្តិនៃ CC និង ច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គលទាក់ទងនឹងការលែងលះដោយតុលាការ (ហៅថា «PSL»)

❶ CC មាត្រា ៩៧៨ មូលហេតុនៃការលែងលះ

PSL មាត្រា៣ ចំណុច គ (វិសាលភាពនៃច្បាប់នេះ)

បណ្ដឹងលែងលះតាមបញ្ញត្តិនៃ「មូលហេតុនៃការលែងលះ」ក្នុងក្រមរដ្ឋប្បវេណីមាត្រា៩៧៨

❷ CC មាត្រា ៩៨០ ការបែងចែកទ្រព្យសម្បត្តិ

PSL មាត្រា២២ កថាខណ្ឌទី១ សេចក្ដីសម្រេចស្ដីពីការចាត់ចែងបន្ទាប់បន្សំ ជាអាទិ៍

❸ CC មាត្រា១០៣៧ ការសម្រេចអំពីអ្នកមានអំណាចមេបា នៅពេលលែងលះ

PSL មាត្រា២២ កថាខណ្ឌទី១ ការកំណត់អ្នកមានអំណាចមេបា

❹ CC មាត្រា១០៤០ ការចូលជួប និង ប្រាស្រ័យទាក់ទង និង ចំណែកបន្ទុកនៃសោហ៊ុយនៃការគ្រប់គ្រងថែរក្សាកូន

PSL មាត្រា២២ កថាខណ្ឌទី១ ការចាត់ចែងអំពីការគ្រប់គ្រងថែរក្សាកូន

(កំណត់អំពីរបៀបចូលជួប និង ប្រាស្រ័យទាក់ទងកូន និង ចំណែកបន្ទុកចំណាយសម្រាប់ការគ្រប់គ្រងថែរក្សាកូន ជាអាទិ៍ )

❺ PSL មាត្រា២២ កថាខណ្ឌទី២ ការប្រគល់កូន ឬ ការបង់ប្រាក់ ឬ ការផ្តល់តាវកាលិកផ្សេងទៀត

❻ PSL មាត្រា២២ កថាខណ្ឌទី៤

ចំពោះការចាត់ចែងអំពីការកំណត់អំណាចមេបា និង ការគ្រប់គ្រងថែរក្សាកូន ត្រូវយកយោបល់របស់កូនមកពិចារណា

❼ PSL មាត្រា២៣

ត្រូវពិន័យជាប្រាក់ចំនួនមិនលើសពី ១លាន រៀល ក្នុងករណីធ្វេសប្រហែសមិនអនុវត្តដីកាសម្រេចឲ្យអនុវត្ត ការបង្គាប់ឲ្យអនុវត្ត ឬ ការបង្គាប់ឲ្យបង់ប្រាក់

❽ PSL មាត្រា១១ ការរួមបញ្ចូលការទាមទារដែលពាក់ព័ន្ធ

ការរួមបញ្ចូលការទាមទារសំណងជម្ងឺចិត្តជាមួយនឹងការលែងលះ

# 1. ពាក្យបណ្តឹង

1. ចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្តឹង

(ក្រមនីតិវិធីរដ្ឋប្បវេណី (ហៅថា «CCP») មាត្រា៧៥ កថាខណ្ឌទី២ និង ទី៣)

① ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់ភាគី ហើយនិង ឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់

② ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទាឲ្យតុលាការចេញ និង អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ

③ សរសេរឲ្យបានច្បាស់នូវអង្គហេតុដែលជាមូលហេតុនៃការទាមទារ និង អង្គហេតុពាក់ព័ន្ធ

④ សរសេរអំពីភស្តុតាង

2. ការដាក់ភស្តុតាង

※អង្គហេតុដែលទ្រទ្រង់ដល់មូលហេតុនៃការទាមទារ (លិខិត និង រូបថត ជាអាទិ៍)

# ការសរសេរខ្លឹមសារនៃសាលក្រមដែលទាមទារដោយដើមចោទ

ទាមទារសាលក្រម

1. បង្គាប់ឲ្យលែងលះដើមចោទ និង ចុងចម្លើយ។
2. កំណត់ឲ្យដើមចោទជាអ្នកមានសិទ្ធិអំណាចមេបាលើ C ដែលជាកូនរវាងដើមចោទ និង ចុងចម្លើយ។
3. បង្គាប់ឲ្យចុងចម្លើយបង់ប្រាក់ចំនួន ១លាន រៀល រៀងរាល់ថ្ងៃចុងខែ ចាប់ពីថ្ងៃទីXX ខែXX ឆ្នាំ២0XX ដល់ថ្ងៃទីXX ខែXX ឆ្នាំ២0XX ទៅឲ្យដើមចោទ។ ※1
4. បង្គាប់ឲ្យចុងចម្លើយបង់ប្រាក់ចំនួន ៥0លាន រៀល ទៅឲ្យដើមចោទ។ ※2
5. ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ។

※1 ថ្លៃចិញ្ចឹមបីបាច់

※2 ប្រាក់បែងចែកទ្រព្យ សំណងជម្ងឺចិត្ត

# ការសរសេរអង្គហេតុដែលជាមូលហេតុនៃការទាមទារ

1. ការអះអាងអង្គហេតុដែលជាមូលហេតុនៃការលៃងលះ

បង្ហាញអំពីភាពត្រូវគ្នានឹងមូលហេតុណាមួយក្នុងចំណុចទាំងអស់នៃ CC មាត្រា៩៧៨ កថាខណ្ឌទី១ ជាមួយនឹងការអះអាងអំពីទំនាក់ទំនងអង្គហេតុដែលត្រូវនឹងលក្ខខណ្ឌនៃចំណុចទាំងអស់នោះ (ដាក់ទាំងភស្តុតាងដែលគាំទ្រអង្គហេតុដែលបានអះអាង)។

※ ករណី CC មាត្រា៩៧៨ កថាខណ្ឌទី១ ចំណុច ង (ទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែងបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបាន)

① អង្គហេតុជាក់ស្តែង A ដែលជាមូលដ្ឋានគាំទ្រចំណុចដែលទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែងបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបាន

② អង្គហេតុជាក់ស្តែង B ...

③ អង្គហេតុជាក់ស្តែង C ...

(ការអះអាងអង្គហេតុដែលជាមូលហេតុនៃការលែងលះ)
នៅក្នុងករណីសិក្សានេះ យើងសរសេរនូវចំណុចខាងក្រោម
＊អង្គហេតុដែល A ចាយវាយខ្ជះខ្ជាយ និង ញៀនជាតិអាកុល។
＊អង្គហេតុដែល A ប្រើអំពើហិង្សាលើ B ជាអាទិ៍ (លក្ខណៈ និង ភាពញឹកញាប់នៃអំពើហិង្សានោះ ស្ថានភាពនៃកន្លែងដែលមានរបួស ជាអាទិ៍)។
＊អង្គហេតុស្នាក់នៅផ្សេងគ្នាដោយមូលហេតុនៃអំពើហិង្សារបស់ A។
＊ផ្អែកតាមស្ថានភាពខាងលើ ធ្វើឲ្យ B គ្មានឆន្ទៈបន្តអាពាហ៍ពិពាហ៍ជាមួយនឹង A។

## 2. ការចាត់ចែងបន្ទាប់បន្សំ (សោហ៊ុយចិញ្ចឹមបីបាច់ ប្រាក់នៃការបែងចែកទ្រព្យសម្បត្តិ) និង សំណងជម្ងឺចិត្ត

ការអះអាងអង្គហេតុដែលជាមូលហេតុនៃការទាមទារ

ចំពោះ「អង្គហេតុដែលជាមូលហេតុនៃការទាមទារ」 ត្រូវសរសេរអង្គហេតុដែលជាខ្លឹមសារមូលដ្ឋាននៃ「ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ」។

❶ ការទាមទារស្តីពីការបែងចែកទ្រព្យសម្បត្តិ (CC មាត្រា៩៨០ LPS មាត្រា២២ កថាខណ្ឌទី១)

* ការបរិច្ចាគរបស់ B ដើម្បីលទ្ធកម្ម និង ថែរក្សាទ្រព្យរួមមានទំហំធំ។
* អំឡុងពេលអាពាហ៍ពិពាហ៍មានរយៈពេលវែងដល់ ១២ឆ្នាំ។
* B គ្មានការងារ ហើយមានភាពលំបាកក្នុងការរកការងារ ក្រោយពេលលែងលះ។

❷ ការទាមទារអំពីការកំណត់អ្នកមានសិទ្ធិអំណាចមេបា (CC មាត្រា១០៣៧ LPS មាត្រា២២ កថាខណ្ឌទី១)

∗ មិនត្រឹមតែ B នោះទេ C ក៏ចង់រស់នៅជាមួយ B ដែរ (សូមយោង LPS មាត្រា២២ កថាខណ្ឌទី៤)។

∗ C កំពុងតែភ័យខ្លាចចំពោះការស្រវឹងកាចរបស់ A និង អំពើហិង្សាលើ B

∗ B ចិញ្ចឹមបីបាច់ និង ថែទាំ C ស្ទើរទាំងស្រុង ហើយស្ថានភាពថែទាំក៏គ្មានបញ្ហាអ្វីទាំងអស់។

∗ ការស្រវឹងកាច និង ការចាយវាយខ្ជះខ្ជាយ ជាអាទិ៍ ធ្វើឲ្យ A មិនសាកសមជាអ្នកមានអំណាចមេបា។

∗ C មានអាយុ ១០ឆ្នាំ និងជាអាយុអាចបង្ហាញឆន្ទៈរបស់ខ្លួនបាន។

❸ ការទាមទារសោហ៊ុយចិញ្ចឹមបីបាច់ (CC មាត្រា១០៤០ LPS មាត្រា ២២ កថាខណ្ឌទី១)

＊A ធ្វើជាមន្ត្រីរាជការ និងមានប្រាក់ខែ ៣លាន រៀល។

＊B គ្មានការងារ និង គ្មានប្រាក់ចំណូល ហើយមានភាពលំបាកក្នុងការរកការងារនាពេលអនាគត ហើយឪពុកម្តាយរបស់ B ដែល B ត្រូវចាប់ផ្តើមរស់នៅជាមួយក៏គ្មានជីវភាពធូធារដែរ។

※សរសេរអំពីលទ្ធភាពធ្វើការរបស់ B ក្រោយពេលដែល B លែងលះ ក្រៅពីចំណូលរបស់ A ។

❹ ការទាមទារសំណងជម្ងឺចិត្តដោយសារការលែងលះ (CC មាត្រា៧៥៤ LPS មាត្រា១១)

※ សរសេរអំពី ជីវភាពអាពាហ៍ពិពាហ៍រហូតដល់ទៅ ១២ឆ្នាំ ត្រូវបញ្ចប់ដោយសកម្មភាពដែលត្រូវនឹងមូលហេតុនៃការលែងលះរបស់ A និង អង្គហេតុនានាដែលធ្វើឲ្យមានការខូចខាតសតិអារម្មណ៍។

# 3. ចំណុចដែលត្រូវសរសេរក្នុងឯកសារចម្លើយ

ប៉ុន្តែ ឯកសារចម្លើយដែលដាក់ដោយអ្នកតំណាងចុងចម្លើយដែលបដិសេធការលែងលះ អាចសរសេរដូចខាងក្រោម និង ផ្តល់នូវភស្តុតាងដែលជាមូលហេតុនៃការអះអាងរបស់ចុងចម្លើយ។

## ទី 1. ការឆ្លើយតបចំពោះការទាមទាររបស់ដើមចោទ

1. ច្រានចោលការទាមទាររបស់ដើមចោទ។
2. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ។

## ទី 2. បដិសេធចំពោះអង្គហេតុដែលដើមចោទអះអាង

## ទី 3. ការអះអាងរបស់ចុងចម្លើយ

※ ករណី CC មាត្រា៩៧៨ កថាខណ្ឌទី១ ចំណុច ង (ទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែងបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបាន)

① អង្គហេតុជាក់ស្តែង A ដែលបដិសេធចំណុចដែលទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែងបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបាន

② អង្គហេតុជាក់ស្តែងB ...

③ អង្គហេតុជាក់ស្តែងC ...

## —អំពីសិទ្ធិចូលជួប និង ប្រាស្រ័យទាក់ទង—

CC មាត្រា១០៤០   NSCC មាត្រា ៣ កថាខណ្ឌទី១ ឧប.ផ្នែកទី៤ ចំណុចទី១៣   LPS មាត្រា២២ កថាខណ្ឌទី១

សិទ្ធិចូលជួប និង ប្រាស្រ័យទាក់ទង គឺជាសិទ្ធិទាមទារ ចូលជួប តេទូរស័ព្ទ និង ឆ្លើយឆ្លងសបុត្រជាមួយកូនរបស់ឪពុកម្តាយដែលមិនចិញ្ចឹមបីបាច់កូន (ឪពុកម្តាយដែលមិនមែនជាអ្នកមានអំណាចមេបា) ចំពោះឪពុកម្តាយដែលចិញ្ចឹមបីបាច់កូន។

CC មាត្រា១០៤០ បញ្ញត្តអំពីសញ្ញាណនៃសិទ្ធិចូលជួប និង ប្រាស្រ័យទាក់ទង ចំពោះឪពុកម្តាយដែលមិនរស់នៅជាមួយកូនដូចខាងក្រោម។

* ឪពុកម្តាយដែលមានបំណងលែងលះត្រូវពិភាក្សា និង កំណត់អំពីរបៀបចូលជួប និង ប្រាស្រ័យទាក់ទងជាមួយកូន (កថាខណ្ឌទី២)។

* បើការពិភាក្សាពុំបានសម្រេច ឬ បើពុំអាចធ្វើការពិភាក្សាបានទេ តុលាការត្រូវកំណត់អំពីរបៀបចូលជួប និង ប្រាស្រ័យទាក់ទងជាមួយកូន តាមការទាមទាររបស់ឪពុក ឬ ម្តាយ (កថាខណ្ឌទី៤)។

* តុលាការត្រូវកំណត់អំពីការចូលជួប និង ប្រាស្រ័យទាក់ទងជាមួយកូន ដោយយកផលប្រយោជន៍របស់កូនជាអាទិភាព (កថាខណ្ឌទី៦)។

## V ដីកាបង្គាប់ឲ្យអនុវត្ត និង ការអនុវត្តដោយបង្ខំ

### 1. ដីកាបង្គាប់ឲ្យអនុវត្ត (LPS មាត្រា២៣)

តុលាការអាចចេញដីកាបង្គាប់ឲ្យបង់ប្រាក់ ជាអាទិ៍ ដោយកំណត់អំឡុងពេលចំពោះបុគ្គលដែលត្រូវបានបង្គាប់ឲ្យអនុវត្តករណីយកិច្ចធ្វេសប្រហែសក្នុងការបង់ប្រាក់ និង ប្រគល់ទ្រព្យសម្បត្តិដែលបានទទួលស្គាល់តាម LPS មាត្រា២២ ទាក់ទងនឹងការចាត់ចែង (សោហ៊ុយចិញ្ចឹមបីបាច់ ជាអាទិ៍) អំពីការបែងចែកទ្រព្យសម្បត្តិ និង ការគ្រប់គ្រងថែទាំកូន។ ប្រសិនបើមិនធ្វើតាមបង្គាប់នោះដោយគ្មានមូលហេតុត្រឹមត្រូវ តុលាការអាចបង្គាប់ឲ្យពិន័យជាប្រាក់មិនលើសពី ១លានរៀល ហើយតាមរយៈនេះអាចបណ្តាលឲ្យបុគ្គលដែលត្រូវបានបង្គាប់ឲ្យអនុវត្តករណីយកិច្ចបង់ប្រាក់បាន។

## 2. ការអនុវត្តដោយបង្ខំ (CCP)

ក្រៅពីសាលក្រមតាម LPS ដីកាសម្រេចដែលចូលជាស្ថាពរតាម NSCC ទាក់ទងនឹងការបង់ប្រាក់ និង ការប្រគល់វត្ថុជា អាទិ៍ ក៏ត្រូវក្លាយជាលិខិតអនុវត្តដែលបញ្ញត្តក្នុង CCP មាត្រា៣៥០ និងទទួលបានអានុភាពអនុវត្ត (NSCC មាត្រា៣៨) ដែរ។ ក្នុងករណីបុគ្គលដែលត្រូវបានបង្គាប់ឲ្យអនុវត្តករណីយកិច្ចធ្វេសប្រហែសក្នុងការបង់ប្រាក់ ជាអាទិ៍ យើងអាចដោះស្រាយតាមរយៈការអនុវត្តដោយបង្ខំ (CCP គន្លឹះទី៦) បាន។

# VI សេចក្ដីសន្និដ្ឋាន

នៅប្រទេសជប៉ុនក៏ដោយ ក៏ចំនួននៃម្ដាយ (ឪពុក) ដែលចិញ្ចឹមកូនតែម្នាក់ឯង ក្រោយពេលលែងលះមានបញ្ហាលំបាកផ្នែកសេដ្ឋកិច្ច និង ជួបបញ្ហាលំបាកផ្នែកជីវភាពប្រចាំថ្ងៃ ព្រមទាំងមានការនឿយហត់ខ្លាំងក្នុងការចញ្ចឹមកូន មានកាន់តែច្រើនឡើងផងដែរ។ ហើយបញ្ហារបស់ឪពុកម្ដាយបណ្ដាលឲ្យកូនទៅពាក់ព័ន្ធជាមួយ និង ត្រូវឃ្លាតឆ្ងាយពីឪពុកម្ដាយណាម្ខាង ជាអាទិ៍ អាចធ្វើឲ្យមានរបួសផ្លូវចិត្តរបស់កូន នឹងប៉ះពាល់ដល់ការរីកលូតលាស់របស់កូន។ នៅពេលចូលរួមក្នុងរឿងក្ដីលែងលះ ក្នុងនាមជាមេធាវី ខ្ញុំយល់ថាត្រូវតែដោះស្រាយដោយប្រុងប្រយ័ត្ន ដោយមើលទៅលើការទ្រទ្រង់ជីវភាពរបស់ភាគី និង សុខមាលភាពរបស់កូនក្រោយពេលលែងលះ។